# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការសិក្សាអំពីមូលហេតុដែលនាំឲ្យមានអតិផរណា

**(ករណីប្រទេសកម្ពុជា ថៃ និង សិង្ហបុរី)**

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


គាត់តែងឡើងដោយ

និស្សិតឈ្មោះ: **ប៊ូ សុវណ្ណច័ន្ទស្សានី**

**ទិត្យ រដ្ឋា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឌុយ ចាន់ឌីណា**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ ឈ្មោះ **ម៉ូ សុវណ្ណច័ន្ទស្សានី** និង **ទិត្យ រដ្ឋា** ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្រ្ត សេដ្ឋកិច្ច ឆ្នាំទី ៤ ជំនាន់ទី១៦ ជំនាញគ្រប់គ្រងធុរកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់ចំពោះ

- **លោកអ្នកមានគុណទាំងពីរ** របស់យើងខ្ញុំ ដែលបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ ថែរក្សាយើងខ្ញុំតាំងពីតូចមកដោយគ្មានការត្អូញត្អែរ ព្រមទាំងខិតខំអប់រំទូន្មាននិងបានផ្តល់ ឱកាសឲ្យយើងខ្ញុំបានសិក្សារៀនសូត្រតាំងពីតូចរហូតដល់ធំនិងមានចំណេះដឹង។ លើសពី នេះ លោកទាំងពីរបានផ្តល់នូវក្តីស្រលាញ់ព្រមទាំងលះបង់នូវកម្លាំងកាយចិត្តយ៉ាងច្រើន ក្នុងការចិញ្ចឹមបីបាច់ថែរក្សា ក៏ដូចជាផ្គត់ផ្គង់នូវរាល់តម្រូវការទាំងផ្នែកហិរញ្ញវត្ថុនិងស្មារតី។
- **លោកគ្រូ អ្នកគ្រូ គ្រប់កម្រិត** ដែលបានខិតខំអប់រំ ប្រៀនប្រដៅ ព្រមទាំងផ្តល់ និងផ្ទេរនូវ ចំណេះដឹងយ៉ាងច្រើនតាំងពីកម្រិត បឋមសិក្សា រហូតដល់កម្រិតសាកលវិទ្យាល័យ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធាន និងអនុប្រធានការិយាល័យសិក្សា និងស្រាវជ្រាវ ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ** គ្រប់មុខវិជ្ជា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ រៀបចំ ស្រាវជ្រាវ បង្ហាត់បង្រៀន ក៏ដូចជាផ្ទេរនូចំណេះដឹងមកដល់ យើងខ្ញុំឲ្យទទួលបានជោគជ័យក្នុងការសិក្សារៀនសូត្រ។
- លោកសាស្រ្តាចារ្យ **បណ្ឌិត ឌុយ ចាន់ឌីណា** ដែលជាសាស្រ្តាចារ្យណែនាំដល់ក្រុមយើង ខ្ញុំ ដោយលោកបានចំណាយពេលរបស់លោកក្នុងការបង្ហាត់បង្ហាញពីរបៀបនៃការសិក្សា ស្រាវជ្រាវឲ្យទទួលបានប្រសិទ្ធភាពល្អ។ លើសពីនេះ លោកបានផ្តល់នូវអនុសាសន៍យ៉ាង ល្អប្រសើរ ព្រមទាំងមិនប្រកាន់នូវកំហុសរបស់ក្រុមយើងខ្ញុំ ដោយបានកែលំអរចំណុចខ្វះ ខាត និងកំហុសទាំងនោះឲ្យមានភាពល្អប្រសើរឡើងវិញដោយក្តីរីករាយ។
- មិត្តភ័ក្តទាំងឡាយដែលជានិច្ចកាល បានផ្តល់នូវកម្លាំងចិត្ត ព្រមទាំងគំនិតយោបល់ ផ្សេងៗ។

ជាចុងក្រោយ យើងខ្ញុំ សូមជូនពរឲ្យលោកមានគុណទាំងពីរ ឯកឧត្តម លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ គ្រប់កម្រិតទាំងអស់ និងមិត្តរួមថ្នាក់ ព្រមទាំងមិត្តនិស្សិតទាំងអស់ ឲ្យទទួលបាននូវ សុភមង្គល និងជោគជ័យក្នុងជីវិត។

# អារម្ភកថា

នាពេលបច្ចុប្បន្នប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍន៍ មានសន្តិភាព ស្ថិរភាព នយោបាយ ដែលជាហេតុធ្វើឲ្យមានកំណើនអ្នកវិនិយោគជាច្រើន មកធ្វើការវិនិយោគទុននៅក្នុងប្រទេស។ បើគិតចាប់ពីឆ្នាំ ២០១០ ដល់២០១៦ ប្រទេសកម្ពុជាមានបម្រែបម្រួលសេដ្ឋកិច្ចឥតឈប់ឈរ តួយ៉ាងនៅក្នុងឆ្នាំ២០១០ កម្ពុជានៅតែទទួលរងនូវកំណើនសេដ្ឋកិច្ចទាបដោយសារកម្រិតនៃវិបត្តិសេដ្ឋកិច្ចពិភពលោកដែលនៅមានឥទ្ធិពលនៅឡើយ។ ក្នុងនោះផងដែរ មានកត្តាជាច្រើនដែលជម្រុញឲ្យសេដ្ឋកិច្ចមានការប្រែប្រួលទាំងការកើនឡើង និងការធ្លាក់ចុះពីមួយខែទៅមួយខែ និងពីមួយឆ្នាំទៅមួយឆ្នាំ ដោយមូលហេតុទាំងនោះគឺ រាប់បញ្ចូលទាំងគោលនយោបាយរបស់រដ្ឋ ឥទ្ធិពលពីក្រៅប្រទេស និងក្នុងប្រទេសដែលវាជាចំណុចបញ្ឆាក់ផ្ដើមនៃមូលហេតុដែលនាំឲ្យមានអតិផរណា។ ពាក់ព័ន្ធទៅនិងបរិបថនៃសេដ្ឋកិច្ចនេះដែរ អតិផរណា គឺជាចំណុចសំខាន់មួយដែលពាក់ព័ន្ធទៅនឹងស្ថានភាពនៃសេដ្ឋកិច្ចរបស់ប្រទេសមួយ ឬសេដ្ឋកិច្ចសកលលោក។ គួរបញ្ជាក់ផងដែរថា អតិផរណា គឺជាកត្តាប្រឈមមួយដល់សំខាន់ ដែលធ្វើឲ្យមានផលប៉ះពាល់ទៅដល់សេដ្ឋកិច្ចជាតិ និងអន្តរជាតិ។

ដោយឃើញថា អតិផរណា មានសារៈសំខាន់ក្នុងសេដ្ឋកិច្ចដូចដែលបានលើកឡើងខាងលើនេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចកំណត់ជ្រើសយកប្រធានបទមួយ មកធ្វើការស្រាវជ្រាវដែលមានចំណងជើងថា ″ការសិក្សាអំពីមូលហេតុដែលឲ្យមានអតិរណា (ករណីប្រទេសកម្ពុជា ថៃ និងសឹង្ហបុរី) ដោយបានលើកយកនូវប្រទេស ថៃ និងសឹង្ហបុរី ដែលសុទ្ធតែជាប្រទេសដែលមានខឿនសេដ្ឋិច្ចរឹងមាំ យកមកធ្វើការសិក្សា និងប្រៀបធៀបប្រទេសទាំងពីរនេះ ជាមួយនិងប្រទេស កម្ពុជាជាគោល ដោយសិក្សាទៅលើកត្តាទូទៅដែលជាប្រភពនៃមូលហេតុដែលនាំឲ្យកើនមាននូវវត្តមាននៃអតិផរណា។

ជាចុងក្រោយ បើទោះបីជាក្រុមយើងខ្ញុំបានខិតខំធ្វើការសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រធានបទខាងលើយ៉ាងយកចិត្តទុកដាក់យ៉ាងណាក្ដី ក៏របាយការណ៍នៃសារណានេះ នៅតែមានចំណុចខ្វះខាតជាច្រើន ទាំងការប្រើប្រាស់ពាក្យពេចន៍ ឃ្លាប្រយោគ ទំហំនៃការសិក្សា ក៏ដូចជាការរៀបចំនៃរបាយការណ៍សារណា។ បើទោះយ៉ាងនេះក្ដី ក្រុមយើងខ្ញុំសង្ឃឹមថារបាយការណ៍សារណានៃប្រធានបទខាងលើនេះ នឹងបានចូលរួមចំណែកក្នុងការទុកជាឯកសារ សម្រាប់សិស្ស និស្សិត និងមិត្តអ្នកអានទាំងឡាយដែលចង់ស្វែងយល់ពាក់ព័ន្ធនឹងប្រធានបទនេះ និងសូមជូនពរឲ្យ សិស្ស និស្សិតទាំងអស់ទទួលបានជោគជ័យក្នុងការសិក្សា។

# មាតិកា


អក្សរកាត់........................................................................................................v
បញ្ជីតារាង.......................................................................................................vi
បញ្ជីក្រាប........................................................................................................vii


## សេចក្ដីផ្ដើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................................................ ១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ...................................................................... ១
៣. គោលបំណងនៃការស្រាវជ្រាវ......................................................................... ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............................................................. ២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ.............................................................................៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ...........................................................................៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................... ៤


## ជំពូកទី ១៖ រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងអតិផរណា


១.១ និយមន័យនៃអតិផរណា................................................................................ ៥
១.២ ទ្រឹស្តីអតិផរណារបស់លោក Keynesian.......................................................... ៥
១.៣ ឥទ្ធិពលនៃអតិផរណារ................................................................................... ៦
១.៣.២ ផលអវិជ្ជមាន.......................................................................................... ៦
១.៣.៣ ផលវិជ្ជមាន............................................................................................ ៨
១.៤ ការគណនាអត្រាអតិផរណា ............................................................................ ៩
១.៤.១ ការគណនាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ & អត្រាអតិផរណា (Consumer Price Index ( CPI ) & Inflation Rate ) .............................................................. ៩
១.៤.១.១ ការកំណត់កន្ត្រកនៃសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ .......................... ៩
១.៤.១.២. ស្វែងរកតម្លៃ (Find the Price ).......................................................១០
១.៤.១.៣. គណនាថ្លៃកន្ត្រកទំនិញ ( Compute the basket's cost )..................១០
១.៤.១.៤. ជ្រើសរើសឆ្នាំគោល និងគណនាសន្ទស្សន៍ថ្លៃ (Choose a base year and compute the price index ) .....................................................១១
១.៤.១.៥. គណនាអត្រាអតិផរណា (Compute the Inflation Rate)....................១២

## ជំពូកទី ២៖ ករណីសិក្សាលើស្ថានភាពអតិផរណានៃប្រទេសជិតខាង


២.១ ស្ថានភាពអតិផរណានៃប្រទេសថៃ ........ ១៤

២.១.១ ស្ថានភាពទូទៅនៃប្រទេសថៃ ........ ១៤

២.១.២ អត្រាអតិផរណាប្រចាំឆ្នាំ ........ ១៤

២.១.៣ មូលហេតុបណ្តាលឲ្យមានអតិផរណា ........ ១៥

២.១.៣.១ ថ្លៃក្នុងកត្តាផលិតកម្ម ........ ១៥

២.១.៣.២ Pass-through Cost ........ ១៦

២.១.៤ បញ្ហាប្រឈម ........ ១៧

២.១.៥ ដំណោះស្រាយរបស់រដ្ឋាភិបាលលើបញ្ហាអតិផរណា ........ ១៨

២.២. ស្ថានភាពអតិផរណានៃប្រទេសសឹង្ហបុរី ........ ២០

២.២.១. ស្ថានភាពទូទៅនៃប្រទេសសឹង្ហបុរី ........ ២០

២.២.២. អត្រាអតិផរណាប្រចាំខែ និង ប្រចាំឆ្នាំ ........ ២១

២.២.៣ មូលហេតុដែលបណ្តាលឲ្យមានអតិផរណា ........ ២២

២.២.៣.១. ថ្លៃមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ........ ២២

២.២.៣.២.. ការកើនឡើងថ្លៃឈ្នួលផ្ទះ ........ ២៣

២.២.៣.៣.. ថ្លៃពលកម្ម ........ ២៣

២.២.៤ បញ្ហាប្រឈម ........ ២៤

២.២.៥ ដំណោះស្រាយរបស់រដ្ឋាភិបាលសឹង្ហបុរីលើបញ្ហាអតិផរណា ........ ២៥

២.២.៥.១.. ដំណោះស្រាយអតិផរណាលើទំនិញនាំចូល៖ ........ ២៦

២.២.៥.២. ដំណោះស្រាយលើអតិផរណានៃទំនិញក្នុងស្រុក ........ ២៦


## ជំពូកទី ៣៖ ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា


៣.១ ស្ថានភាពទូទៅនៃប្រទេសកម្ពុជា ........ ២៨

៣.២. អត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ ........ ២៨

៣.៣. ស្ថានភាពអតិផរណាប្រចាំឆ្នាំ ........ ៣០

៣.៣.១ ស្ថានភាពអតិផរណាប្រចាំឆ្នាំក្នុងឆ្នាំ ២០១០ ........ ៣០

៣.៣.២. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១១ ........ ៣១

៣.៣.៣. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១២ ........ ៣២

៣.៣.៤. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៣ ........ ៣៣

៣.៣.៥. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៤ .......... ៣៤
៣.៣.៦. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៥ .......... ៣៥
៣.៣.៧. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៦ .......... ៣៧
៣.៤. កត្តាជះឥទ្ធិពលមកលើអតិផរណាក្នុងប្រទេសកម្ពុជា .......... ៣៨
៣.៤.១ កត្តាខាងក្រៅដែលជះឥទ្ធិពលមកលើអតិផរណាកម្ពុជា .......... ៣៨
៣.៤.១.១. ថ្លៃប្រេងនៅពិភពលោក .......... ៣៨
៣.៤.១.២.. អតិផរណានៃប្រទេសនាំចូលទំនិញមកកម្ពុជា .......... ៣៩
៣.៤.២. កត្តាក្នុងស្រុកដែលជះឥទ្ធិពលមកលើអតិផរណាកម្ពុជា .......... ៤០
៣.៤.២.១.កត្តាធម្មជាតិ .......... ៤០
៣.៤.២.២.កត្តាតម្រូវការនិងរូបិយវត្ថុ .......... ៤១
៣.៥. ផលប៉ះពាល់នៃអតិផរណា .......... ៤១
៣.៥.១.ផលប៉ះពាល់ទៅលើបុគ្គលិកធ្វើការតាមរោងចក្រ .......... ៤១
៣.៥.២.ផលប៉ះពាល់ទៅលើកុមារ សិស្ស និស្សិត .......... ៤២
៣.៥.៣.ផលប៉ះពាល់ទៅលើមន្ត្រីរាជការដែលមានប្រាក់បៀវត្ស .......... ៤២
៣.៦. ដំណោះស្រាយរបស់រដ្ឋាភិបាលលើបញ្ហាអតិផរណា .......... ៤២

**ជំពូកទី ៤៖ ការពិភាក្សា វិភាគទៅលើលទ្ធផលនៃរបកគំហើញ**

៤.១. អំពីសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ .......... ៤៤
៤.១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៃក្រុមនីមួយៗក្នុងប្រទេសសឹង្ហបុរី .......... ៤៤
៤.១.១.១. សន្ទស្សន៍ថ្លៃម្ហូបអាហារ .......... ៤៤
៤.១.១.២.សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គីសនី ឥន្ធនៈ .......... ៤៤
៤.១.១.៣. សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និង ស្បែកជើង .......... ៤៥
៤.១.១.៤. សន្ទស្សន៍ថ្លៃដឹកជញ្ជូន .......... ៤៦
៤.១.១.៥.. សន្ទស្សន៍ថ្លៃគមនាគមន៍ .......... ៤៦
៤.១.១.៦. សន្ទស្សន៍ថ្លៃអប់រំ .......... ៤៧
៤.១.១.៧.សន្ទស្សន៍ថ្លៃសុខាភិបាល .......... ៤៧
៤.១.១.៨.ទំនិញ ឬ សេវាកម្មផ្សេងៗ .......... ៤៨
៤.១.២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៃក្រុមនីមួយៗក្នុងប្រទេសកម្ពុជា .......... ៤៩
៤.១.២.១. សន្ទស្សន៍ថ្លៃម្ហូបអាហាមិនមានជាតិស្រវឹង .......... ៤៩

៤.១.២.២.សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ ..................................៤៩
៤.១.២.៣.សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និងស្បែកជើង......................................៥០
៤.១.២.៤.សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គិសនី ឥន្ទនៈ.....................................៥០
៤.១.២.៥.សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ..........................................................................................៥១
៤.១.២.៦.សន្ទស្សន៍ថ្លៃសុខាភិបាល ...........................................................៥១
៤.១.២.៧.សន្ទស្សន៍ថ្លៃដឹកជញ្ជូន...............................................................៥២
៤.១.២.៨.សន្ទស្សន៍ថ្លៃគមនាគមន៍.............................................................៥៣
៤.១.២.៩.សន្ទស្សន៍ថ្លៃការកម្សាន្ត នឹងវប្បធម៌ ...............................................៥៣
៤.១.២.១០.សន្ទស្សន៍ថ្លៃអប់រំ....................................................................៥៤
៤.១.២.១១ សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន ........................................................៥៤
៤.១.២.១២ សន្ទស្សន៍ថ្លៃទំនិញ ឬសេវាកម្មផ្សេងៗ ...........................................៥៥
៤.២. ការវិវត្តនៃអត្រាអតិផរណា .............................................................................៥៥
៤.២.១. ការវិវត្តអត្រាអតិផរណានៃប្រទេសថៃ.................................................៥៦
៤.២.២. ការវិវត្តអត្រាអតិផរណានៃប្រទេសសឹង្ហបុរី..............................................៥៦
៤.២.៣. ការវិវត្តអត្រាអតិផរណានៃប្រទេសកម្ពុជា..............................................៥៦
៤.៣. ការប្រៀបធៀបអតិផរណារវាងប្រទេសកម្ពុជា និង ប្រទេសដ៏ទៃ ...................................៥៧
៤.៣.១. ការប្រៀបធៀបអតិផរណារវាងប្រទេសកម្ពុជា និង ប្រទេសថៃ និង ប្រទេសសឹង្ហបុរី .................................................................................................... ៥៧
៤.៣.២ កាប្រៀបធៀបមូលហេតុដែលនាំឲ្យមានអតិផរណារវាងប្រទេសកម្ពុជា និង ប្រទេសដទៃ.................................................................................. ៥៧
៤.៤ បញ្ហាប្រឈមចម្បងនៃអតិផរណា ......................................................................៥៩
៤.៥ ដំណោះស្រាយរបស់រាជរដ្ឋាភិបាលទៅលើអតិផរណា.............................................៦០

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

១.សេចក្តីសន្និដ្ឋាន.................................................................................................៦២
២.ការផ្តល់អនុសាសន៍ .............................................................................................៦៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | | |
|---|---|---|
| **ASEAN** | : Association of Southeast Asian Nations | សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CPI** | : Consumer Price Index | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| **COE** | : Certificate of Entitlement | លិខិតអនុញ្ញាតិ សម្រាប់ទិញរថយន្ត |
| **IMF** | : International Monetary Fund | មូលនិធិរបស់រូបិយវត្ថុអន្តរជាតិ |
| **LFPR** | : Labor Force Participation Rate | អត្រាពលកម្មនៃប្រជាជនក្នុងស្រុក |
| **M2** | : M2 | រូបិយវត្ថុទូទៅ |
| **MAS** | : Monetary Authority of Singapore | ក្រុមទេសាភិបាលសឹង្ហបុរី(ធនាគារជាតិ) |
| **NEA** | : The National Environment Agency | ភ្នាក់ងារបរិស្ថានជាតិ |
| **RPWG** | : Retail Price Watch Group | អង្គភាពត្រួតពិនិត្យថ្លៃទំនិញ |
| **PIC** | : Productivity and Innovation Credit | ការលើកទឹកចិត្តឲ្យសហគ្រិនមានការ វិនិយោគបន្ថែមក្នុងសកម្មភាពផលិតកម្ម |

# បញ្ជីតារាង

១. តារាង ១.១៖ ការគណនាថ្លៃកន្ត្រកទំនិញ ........ ១១
២. តារាង ២.១៖ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសថៃ ........ ១៤
៣. តារាង ២.២៖ អតិផរណាប្រចាំខែ និង ប្រចាំឆ្នាំរបស់ប្រទេសសឹង្ហបុរី ........ ២១
៤. តារាង ៣.១៖ អត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ ........ ២៨

# បញ្ជីក្រាហ្វិក


១. ក្រាហ្វិក ៤.១ ៖ សន្ទស្សន៍ថ្លៃម្ហូបអារហារ ........ ៤៤
២. ក្រាហ្វិក ៤.២ ៖ សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គសនី ឥន្ធនៈ ........ ៤៥
៣. ក្រាហ្វិក ៤.៣៖ សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និង ស្បែកជើង ........ ៤៥
៤. ក្រាហ្វិក ៤.៤៖ សន្ទស្សន៍ថ្លៃដឹកជញ្ជូន ........ ៤៦
៥. ក្រាហ្វិក ៤.៥៖ សន្ទស្សន៍ថ្លៃគមនាគមន៍ ........ ៤៦
៦. ក្រាហ្វិក ៤.៦៖ សន្ទស្សន៍ថ្លៃអប់រំ ........ ៤៧
៧. ក្រាហ្វិក ៤.៧៖ សន្ទស្សន៍ថ្លៃសុខាភិបាល ........ ៤៨
៨. ក្រាហ្វិក ៤.៨៖ សន្ទស្សន៍ថ្លៃទំនិញ ឬ សេវាកម្មផ្សេង ........ ៤៨
៩. ក្រាហ្វិក ៤.៩៖ សន្ទស្សន៍ថ្លៃម្ហូបអាហារមិនមានជាតិស្រវឹង ........ ៤៩
១០. ក្រាហ្វិក ៤.១០៖ សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ ........ ៥០
១១. ក្រាហ្វិក ៤.១១៖ សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និងស្បែកជើង ........ ៥០
១២. ក្រាហ្វិក ៤.១២៖ សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គិសនី ឥន្ធនៈ ........ ៥១
១៣. ក្រាហ្វិក ៤.១៣៖ សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ ........ ៥១
១៤. ក្រាហ្វិក ៤.១៤៖ សន្ទស្សន៍ថ្លៃសុខាភិបាល ........ ៥២
១៥. ក្រាហ្វិក ៤.១៥៖ សន្ទស្សន៍ថ្លៃដឹកជញ្ជូន ........ ៥២
១៦. ក្រាហ្វិក ៤.១៦៖ សន្ទស្សន៍ថ្លៃគមនាគមន៍ ........ ៥៣
១៧. ក្រាហ្វិក ៤.១៧៖ សន្ទស្សន៍ថ្លៃការកម្សាន្ត នឹងវប្បធម៌ ........ ៥៣
១៨. ក្រាហ្វិក ៤.១៨៖ សន្ទស្សន៍ថ្លៃអប់រំ ........ ៥៤
១៩. ក្រាហ្វិក ៤.១៩៖ សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន ........ ៥៤
២០. ក្រាហ្វិក ៤.២០៖ សន្ទស្សន៍ថ្លៃទំនិញ ឬសេវាកម្មផ្សេង ........ ៥៥
២១.ក្រាហ្វិក ៤.២១៖ ការវិវត្តនៃអត្រាអតិផរណា ........ ៥៥

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

កម្ពុជា ជាប្រទេសមួយដែលស្ថិតក្នុងចំណោមប្រទេសទាំង១០នៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ាន ( ASEAN) ដែលបានចូលជាសមាជិកនៅថ្ងៃទី ៣០ មេសា ឆ្នាំ១៩៩៩ ។ ចាប់តាំងពីអតីតកាលមក កម្ពុជាបានទទួលរងនូវការខូចខាតដោយសារសង្គ្រាមឥតឈប់ឈរ ជាពិសេសនៅក្នុងរបបប្រល័យពូជសាសន៍ដែលត្រូវបានបញ្ចប់នៅក្នុងកំឡុងទស្សវត្សទី ៩០។ ចាប់ពីពេលនោះមក ដើម្បីធ្វើឲ្យវិស័យសេដ្ឋកិច្ចមានការរីកចម្រើនខាងរាជរដ្ឋាភិបាលកម្ពុជាបានកំណត់យករបបទីផ្សារសេរី ដែលជានយោបាយបើកចំហរជើងមេឃ ដោយបានផ្ដល់សិទ្ធពេញលេញដល់ក្រុមហ៊ុនឯកជននានា ទាំងក្នុងនិងក្រៅប្រទេសធ្វើការវិនិយោគរួមគ្នា ដើម្បីធ្វើយ៉ាងណាឲ្យមានការអភិវឌ្ឍន៍ដោយមានរដ្ឋាភិបាលជាអ្នក ត្រួតពិនិត្យ តាមដាន និងមានតួនាទីជាអ្នកសម្របសម្រួលលើវិស័យនេះ។

រហូតមកដល់ឆ្នាំ ២០០៨ និងដើមឆ្នាំ ២០០៩ ប្រទេសកម្ពុជា បានប្រឈមមុខទៅនឹងវិបត្តិសេដ្ឋកិច្ចដោយសារតែផលប៉ះពាល់នោះ គឺកើតឡើងមកពីផលប៉ះពាល់នៃសេដ្ឋកិច្ចពិភពលោក។ ចូលមកដល់ឆ្នាំ ២០១០ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា មានភាពធូរស្រាល ដែលការងើបឡើងវិញនៃសេដ្ឋកិច្ច គឺដោយសារតែការកើនឡើងនៃសកម្មភាពពាណិជ្ជកម្ម ដូចជាវិស័យកាត់ដេរសម្លៀកបំពាក់ ក៏ដូចជាមានការកើនឡើងនៃវិស័យទេសចរណ៍ និងវិស័យផ្សេងៗជាដើម ។ ទន្ទឹមពេលនោះដែរ អត្រាអតិផរណាក៏ចាប់ផ្ដើមមានការកើនឡើងបន្តិចម្ដងៗផងដែរ ហើយវាក៏បានជះឥទ្ធិពលមកដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចជាតិផងដែរ។

គួរបញ្ជាក់ផងដែរថា អតិផរណា គឺជាកត្តាប្រឈមមួយដល់សំខាន់ ដែលធ្វើឲ្យមានផលប៉ះពាល់ទៅដល់ សេដ្ឋកិច្ច និងអាចឈានទៅដល់ការកើតមាននូវវិបត្តិសេដ្ឋកិច្ចជាតិ និងអន្តរជាតិ។ អត្រាអតិផរណា ក៏មានការថយចុះមកត្រឹម១,២ភាគរយ នៅដើមឆ្នាំ ២០១៥ បើធៀបនឹង ឆ្នាំ ២០១៤។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយយើងឃើញថា អតិផរណា គឺជាបញ្ហាចាំបាច់មួយដែលត្រូវដោះស្រាយ និងមានការយកចិត្តទុកដាក់ ព្រោះវាជាកត្តាមួយដែលធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូល និងជាកត្តារាំងស្ទះធ្វើឲ្យសេដ្ឋកិច្ចធ្លាក់ចុះ ព្រមទាំងមានទំនាក់ទំនងយ៉ាងខ្លាំងទៅលើមុខវិជ្ជាដែលបានសិក្សាកន្លងមកនេះហើយ ទើបធ្វើឲ្យក្រុមយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទ **ការសិក្សាអំពីមូលហេតុដែល**

**នាំឲ្យមានអតិផរណា (ករណីប្រទេស កម្ពុជា ថៃ និង ប្រទេសសឹង្ហបុរី)** យកមកធ្វើការសិក្សាស្រាវជ្រាវឲ្យកាន់តែច្បាស់ពីអតិផរណា ព្រមទាំងយុទ្ធសាស្ត្រ ក៏ដូចជាវិធានការណ៍ មួយចំនួនរបស់រដ្ឋាភិបាលដែលបានអនុវត្តន៍ក្នុងការស្វែងរកដំណោះស្រាយពាក់ព័ន្ធនឹងអតិផរណានេះ។ ដូច្នេះហើយ ក្រុមយើងខ្ញុំក៏បានលើកយកនូវបញ្ហាអតិផរណានៅប្រទេសសឹង្ហបុរី និងប្រទេសថៃ ដែលជាប្រទេសដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនយកមកសិក្សា និងវិធីស្វែងរកដំណោះស្រាយរបស់ប្រទេសទាំងពីរនេះទាក់ទងទៅនឹងប្រធានបទខាងលើនេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយយើងសង្កេតឃើញថា ការស្រាវជ្រាវមុនៗពុំសូវបានបកស្រាយពីបញ្ហាអតិផរណាបានលំអិតក្បោះក្បាយ ហើយវាក៏ជាបញ្ហាសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ ទើបក្រុមយើងខ្ញុំយល់ឃើញថា ការដែលជ្រើសរើសប្រធានបទខាងលើនេះយកមកសិក្សាស្រាវជ្រាវ គឺវាមានសារៈសំខាន់សម្រាប់សិស្សនិស្សិត ពលរដ្ឋ និងរដ្ឋាភិបាលរបស់យើងក្នុងការការពារផលប្រយោជន៍ជាតិ និងជួយជម្រុញឲ្យសេដ្ឋកិច្ចយើង មានដំណើរការរីកចម្រើនទៅមុខយ៉ាងរលូនដល់កូនចៅយើងជំនាន់ក្រោយ។ ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃកម្មវត្ថុ ដែលសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើនេះគឺផ្តោតសំខាន់ទៅលើចំនុចដូចខាងក្រោម៖

- សិក្សាអំពីកត្តាដែលពាក់ព័ន្ធទៅនឹងមូលហេតុដែលបណ្តាលឲ្យមានអតិផរណា
- វិធីសាស្ត្រក្នុងការគណនា អត្រាអតិផរណា
- សិក្សាទៅលើឥទ្ធិពលនៃអតិផរណាដែលកើតមាននៅក្នុងសេដ្ឋកិច្ច
- សិក្សាស្វែងយល់ពីបទពិសោធន៍ផ្សេងៗរបស់ប្រទេសថៃ និងប្រទេសសឹង្ហបុរី ក្នុងការគ្រប់គ្រងអតិផរណា ក៏ដូចជាវិធានការ និងយុទ្ធសាស្ត្រ មួយចំនួនរបស់រដ្ឋាភិបាលប្រទេសទាំងពីរនេះ ជាមួយនិងប្រទេសកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើនោះ គឺមានការពាក់ព័ន្ធទៅមូលហេតុដែលនាំឲ្យមានអតិផរណា ដោយលើកយកស្ថានភាពអតិផរណារបស់ប្រទេសកម្ពុជាទាំងមូល ព្រមទាំងលើកយកប្រទេសពីរផ្សេងទៀត គឺប្រទេសសឹង្ហបុរី នឹងប្រទេសថៃ ដែលសុទ្ធតែជាប្រទេសដែលមានខឿនសេដ្ឋកិច្ចមានភាពរឹងមាំ ក្នុងបណ្តាប្រទេសទាំង១០របស់អាស៊ានមកបកស្រាយ។ ការលើកយកបញ្ហាអតិផរណារបស់ប្រទេសទាំងពីរមកធ្វើការសិក្សាគឺដើម្បីធ្វើការបង្ហាញ និងប្រៀបធៀបពីអតិផរណារបស់ប្រទេសទាំងពីរជាមួយប្រទេសកម្ពុជា និងវិធីសាស្ត្រក្នុង

ការដោះស្រាយរាល់បញ្ហានៃអតិផរណានានាដែលប្រទេសទាំងពីរបានអនុវត្តន៍កន្លងមក។

ពាក់ព័ន្ធនឹងវិសាលភាពក្នុងការសិក្សាស្រាវជ្រាវនេះដែរ គឺក្រុមយើងខ្ញុំសូមលើកយកតែចំណុចដែលពាក់ព័ន្ធមកសិក្សាតែប៉ុណ្ណោះរួមមាន៖

- ការសិក្សាអំពីរបាយការណ៍នៃអតិផរណារបស់ប្រទេសកម្ពុជា ជាមួយប្រទេសសឹង្ហបុរី និងប្រទេសថៃ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៦
- ប្រៀបធៀប ប្រទេសទាំងពីរ ទៅនឹងប្រទេសកម្ពុជាលើបញ្ហានៃអតិផរណា
- មូលហេតុដែលនាំឲ្យមានអតិផរណា ព្រមទាំងដំណោះស្រាយនានារបស់រាជរដ្ឋាភិបាល

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះកាសិក្សាស្រាវជ្រាវប្រធានបទនេះ គឺផ្តោតសំខាន់ទៅលើទ្រឹស្តី បទពិសោធន៍ជាក់ស្តែងក្នុងការដោះស្រាយវិបត្តិអតិផរណា ការគ្រប់គ្រងអតិផរណា ទាំងនៅក្នុងប្រទេសកម្ពុជា និងក្នុងប្រទេសថៃ និងសឹង្ហបុរី។ ដូច្នេះ រាល់ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ គឺផ្អែកទៅលើទិន្នន័យបន្ទាប់បន្សំ( Secondary Data ) ដែលយើងបានដកស្រង់ចេញពីឯកសារជាច្រើនដែលពាក់ព័ន្ធ ព្រមទាំងរបាយការណ៍នានាដែលមានដូចជា៖

- របាយការណ៍ពីគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃប្រទេសថៃ និងប្រទេសសឹង្ហបុរី ព្រមទាំងបណ្តារគេហទំព័ររបស់បណ្តារក្រសួងដែលពាក់ព័ន្ធ
- សៀវភៅម៉ាក្រូសេដ្ឋកិច្ចដែលស្តីអំពីអតិផរណា
- ឯកសារដែលមានស្រាប់ ដូចជាសៀវភៅរបាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា សៀវភៅរបាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំរបស់ World Bank Group និងកម្រងឯកសារនានាដែលពាក់ព័ន្ធ។
- ប្រព័ន្ធសង្គមផ្សព្វផ្សាយផ្សេងៗ ដូចជាប្រព័ន្ធអ៊ីនធើណេត កាសែត ទស្សនាវដ្តីផ្សេងៗ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវប្រធានបទនេះគឺបានផ្តល់សារៈសំខាន់ជាច្រើនទៅដល់សិស្ស និស្សិត និងមិត្តទាំងឡាយដូចជា៖

- ទុកជាឯកសារសម្រាប់ជាចំណេះដឹងបន្ថែម សម្រាប់សិស្សនិស្សិត ដែលមានបំណងចង់សិក្សាស្វែងយល់ពី អតិផរណា ក៏ដូចជាចំណុចណាមួយពាក់ព័ន្ធទៅនឹងប្រធានបទខាងលើនេះ ។

- បង្កើតជាស្នាដៃសម្រាប់ជាគំរូដល់ប្អូនៗ និស្សិតជំនាន់ក្រោយក្នុងការខិតខំសិក្សាស្វែងយល់ និង ស្រាវជ្រាវពាក់ពន្ធ័ទៅនឹងប្រធានបទខាងលើ។
- បង្ហាញអំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗក្នុងកំឡុងឆ្នាំដែលធ្វើការស្រាវជ្រាវ
- បង្ហាញពីវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហា នៃអតិផរណារបស់ប្រទេសទាំងបី ព្រមទាំងវិធានការទប់ស្កាត់ដើម្បីជៀសវាងការកើនមានបញ្ហាអតិផរណា។
- ធ្វើឲ្យក្រុមយើងខ្ញុំទទួលបានចំណេះដឹងបន្ថែម និងកាន់តែយល់ច្បាស់ពីប្រធានបទនេះ ព្រមទាំងជួយពង្រឹងដល់សមត្ថភាពផ្ទាល់ខ្លួនបានមួយកម្រិតទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានរៀបចំណុចនីមួយៗជា ៤ ជំពូកដូចដែលបានរៀបរាប់ដូចខាងក្រោមដូចជា៖

- មាតិការរាយ និង មាតិការសង្ខេប
- ពាក្យកាត់
- សេចក្តីផ្តើមប្រធានបទ

ជំពូកទី ១៖ រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងអតិផរណា

ជំពូកទី ២៖ ករណីសិក្សាលើស្ថានភាពអតិផរណារបស់ប្រទេសដទៃ

ជំពូកទី ៣៖ ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា

ជំពូកទី ៤៖ ការពិភាក្សា វិភាគនៅលើលទ្ធផលនៃរបកគំហើញពាក់ព័ន្ធនឹងប្រធានបទ

- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១
# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹង
# អតិផរណា

# ជំពូកទី ១៖ រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងអតិផរណា

## ១.១ និយមន័យនៃអតិផរណា

អតិផរណា គឺជាការកើនឡើងនៃកម្រិតថ្លៃរួមនៃទំនិញ ឬសេវាកម្មក្នុងគ្រាណាមួយនៃខួបសេដ្ឋកិច្ច ឬជាការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុក្នុងសេដ្ឋកិច្ច។ វាបណ្តាលឲ្យអំណាចទិញរបស់អ្នកប្រើប្រាស់ថយចុះផងដែរ។ នៅពេលដែលគេនិយាយអំពីអតិផរណា គេត្រូវផ្តោតសំខាន់ទៅលើតម្លៃរូបិយវត្ថុ។ នៅពេលអតិផរណាកើតមាន គឺមានន័យថាតម្លៃរូបិយវត្ថុធ្លាក់ចុះ ហើយទំនិញគ្រប់មុខនៅលើទីផ្សារឡើងថ្លៃព្រមៗគ្នា។ បើសិនជាទំនិញឡើងថ្លៃដោយផ្នែក ដោយតំបន់ និងដោយពេលវេលា នោះគេមិនហៅថា អតិផរណានោះទេ។ ឧទាហរណ៍៖ ក្នុងឱកាសចូលឆ្នាំខ្មែរក្នុងឆ្នាំនេះ គេសង្កេតឃើញថា ចេកណាំវ៉ាបានកើនឡើងទៅដល់ ប្រាំបីពាន់រៀលក្នុងមួយស្និត ដែលថ្ងៃធម្មតាគឺតម្លៃត្រឹមតែ បីពាន់រៀលតែប៉ុណ្ណោះ ព្រោះទេវតាឆ្នាំនេះទ្រង់សោយចេកណាំវ៉ា ដូច្នេះប្រជាជនខ្មែរគ្រប់រូបត្រូវតែទិញចេកណាំវ៉ា ដើម្បីសែនទទួលទេវតាឆ្នាំថ្មី។ ដូច្នេះគេមិនរាប់បញ្ចូលថា វាជាអតិផរណានោះទេ។ រាល់ប្រទេសនានាលើពិភពលោក គឺសុទ្ធតែមានអតិផរណាកើតមានឡើងគ្រប់ទាំងអស់ ដូចនេះគេត្រូវធ្វើការវាស់វែងអតិផរណាដើម្បីតាមដានន្ទវដំណើរការសេដ្ឋកិច្ច តាមរយៈការគណនារកអត្រាអតិផរណា ដែលគិតជាភាគរយនៃការផ្លាស់ប្តូរនៅក្នុងកម្រិតថ្លៃនារយៈពេលមួយ (ជាទូទៅមួយឆ្នាំ)។

## ១.២ ទ្រឹស្តីអតិផរណារបស់លោក Keynesian

យោងទៅតាមទ្រឹស្តីរបស់លោក គេន ( Keynesians )[1] មូលហេតុដែលនាំឲ្យមានអតិផរណា គឺមាន៣យ៉ាងដូចខាងក្រោម៖

- **អតិផរណាបណ្តាលមកពីតម្រូវការ ( Demand Pull Inflation )** ៖ គឺសំដៅទៅលើអតិផរណាដែលបណ្តាលមកពីកំណើនខាងតម្រូវការសរុប ដោយសារតែការចំណាយថវិការបស់រដ្ឋ និង វិស័យឯកជនកើនឡើង។ ដូច្នេះ ការកើនឡើងខ្លាំងនៃតម្រូវការម្ហូបអាហារ និងសេវាកម្មទូទៅ( តម្រូវការសរុប)បាន " ទាញ" ថ្លៃទំនិញផ្សេងៗទៀតឲ្យកើនឡើងថ្លៃខ្ពស់ជាពិសេស នៅពេលដែលការផ្គត់ផ្គង់សរុបមិនអាចកើនឡើងបានដោយកំហិតសមត្ថភាពនោះ។ គេឃើញមានទំនាក់ទំនងយ៉ាងខ្លាំងក្លា រវាងកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ និង អតិផរណា។ យោងតាមទស្សនះរបស់លោក Milton Friedman " អតិផរណានៅគ្រប់ពេល

[1] ដក់ស្រង់ពីគហទំព័រhttp://inflationmatters.com/keynesian-inflation-theory/ និងសៀវភៅសេដ្ឋកិច្ចរបស់លោក ហង់ជួនណារ៉ុង

និងគ្រប់ទីកន្លែង គឺជាបាតុភូតរូបិយវត្ថុ" ។ ប្រការនេះត្រូវបានគេហៅថា អតិផរណាបណ្តាលមកពីតម្រូវការ។

- **អតិផរណាបណ្តាលមកពីថ្លៃដើម** ( Cost Push Inflation ) ៖ គឺសំដៅទៅលើអតិផរណាដែលបណ្តាលមកពីការធ្លាក់ចុះនៃការផ្គត់ផ្គង់សរុប ដោយសារតែថ្លៃទុនធាតុចូលកើនឡើងក្នុងចង្វាក់ផលិតកម្ម។ កត្តាដែលបណ្តាលមកពីថ្លៃដើមនេះរួមមាន ការកើនឡើងនៃថ្លៃទំនិញដូចជាប្រេង និងម្ហូបអាហារ ការកំណត់ថ្លៃផ្តាច់មុខដោយសហគ្រាស និងប្រាក់បៀវត្សរ៍។ ផលិតករដែលត្រូវចំណាយលើធាតុចូលកាន់តែខ្ពស់ បានបន្តតម្លើងថ្លៃទំនិញដោយផ្ទេរទៅឲ្យអ្នកប្រើប្រាស់ ក្នុងទម្រង់ជាថ្លៃនៃធាតុចេញដែលកើនឡើង។
- **អតិផរណាដោយស្វ័យប្រវត្តិ** ( Built in Inflation) ៖ គឺសំដៅទៅលើអតិផរណាដែលកើតឡើងដោយសារ ការរំពឹងទុក ដែលជាប់ទាក់ទងជាមួយនឹង "វដ្តនៃការឡើងថ្លៃទំនិញ/ប្រាក់បៀវត្ស" ដោយសារតែកម្មករតែងតែសុំឡើងប្រាក់បៀវត្សរបស់ខ្លួន ដើម្បីឲ្យតាមទាន់ថ្លៃទំនិញដែលឡើងកាន់តែខ្ពស់ (បៀវត្សដុលត្រូវតែកើនឡើងលើសសន្ទស្សន៍ថ្លៃ CPI ប្រសិនបើគេមិនចង់ឲ្យប្រាក់ចំណូលពិតធ្លាក់ចុះ ក្រោយពេលតម្លើងប្រាក់បៀវត្សរ៍ ) ហើយបន្ទាប់មកនិយោជិកនឹងបញ្ចូលថ្លៃដើមកើនឡើងនេះ ទៅក្នុងថ្លៃដើមទំនិញ ដែលជាយន្តការផ្ទេរចំណាយកាន់តែខ្ពស់ទៅឲ្យអ្នកប្រើប្រាស់។ ដូច្នេះ ប្រការនេះបានបង្កើតឡើងនូវវដ្តនៃអន្ទាក់វិលវល់មួយ រវាងការឡើងប្រាក់បៀវត្សរ៍ និងថ្លៃទំនិញ។ អតិផរណាដោយស្វ័យប្រវត្តិឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍នានាកាលពីអតីតកាលដែលបង្កើតឲ្យមានអតិផរណានេះផងដែរ។

## ១.៣ ឥទ្ធិពលនៃអតិផរណា

### ១.៣.២ ផលអវិជ្ជមាន

ជាការពិតណាស់ ការកើនឡើងនៃអតិផរណាពិតជាមានផលអវិជ្ជមានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចនៃប្រទេសមួយ។ ខាងក្រោមនេះ គឺជាផលប៉ះពាល់នៃអតិផរណា៖

- ប៉ះពាល់ដល់ម្ចាស់បំណុល ៖ គ្រប់គ្នាសុទ្ធតែដឹងដែរថា កូនបំណុលទទួលបានផលប្រយោជន៍ពីការខ្ចីនៅពេលដែលមានអតិផរណា។ អតិផរណាបានធ្វើឲ្យតម្លៃលុយពិតធ្លាក់ចុះ ដូច្នេះវាបានធ្វើឲ្យមានការខាតបង់ដល់ម្ចាស់បំណុល។ ឧទាហរណ៍៖ ម្ចាស់បំណុលបានផ្តល់លុយឲ្យកូនបំណុលខ្ចី ១០,០០០ រៀល ដោយត្រូវសងវិញក្នុងរយៈពេលមួយឆ្នាំទៀត។ បើថ្លៃកើនឡើង១០% ក្នុងចន្លោះពេលនោះ នាំឲ្យ

លុយរបស់ម្ចាស់បំណុលដែលទទួលបានមកវិញមានតម្លៃតិចជាងមុន។ មូលហេតុនេះហើយដែលគេតែងតែឃើញថារាល់កម្ចីផ្សេងៗ តែងតែមានការកំណត់ការប្រាក់គឺដើម្បីជៀសវាងការខាតបង់នៅពេលដែលមានអតិផរណាកើនឡើង។

- ប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋ៖ នៅពេលដែលអតិផរណាមានការកើនឡើង ពេលនោះហើយដែលធ្វើឲ្យអំណាចទិញរបស់ប្រជាជនមានការថយចុះ ពីព្រោះចំនួនលុយដដែលនោះទិញបានទំនិញបានតិចជាងមុន។ ម្យ៉ាងទៀត អ្នកដែលរងការប៉ះពាល់ខ្លាំងនៅពេលដែលមានអតិផរណា គឺក្រុមប្រជាជនដែលមានចំណូលថេរ ដូចជាមនុស្សចាស់ដែលចូលនិវត្តន៍ជាដើម។ ជាការពិតណាស់ ប្រសិនបើចំណូលរបស់ពលរដ្ឋថេរ ហើយថ្លៃចេះតែកើនឡើងនោះអំណាចទិញទំនិញ និងសេវារបស់ពលរដ្ឋនឹងធ្លាក់ចុះ ហើយធ្វើឲ្យជីវភាពរស់នៅរបស់ពួកគេជួបប្រទះទៅនឹងការលំបាក។
- ប៉ះពាល់ដល់សេដ្ឋកិច្ច៖ ជាធម្មតា អ្នកវិនិយោគតែងតែប្រាថ្នានឹងទទួលបានប្រាក់ចំណេញទៅលើការវិនិយោគរបស់ពួកគេ។ ពួកគេតែងតែធ្វើការប៉ាន់ស្មានទៅលើការចំណាយ និងផលចំណេញនៃការវិនិយោគទៅលើអាជីវកម្មរបស់ពួកគេ។ នៅពេលដែលអតិផរណាកើនឡើង នោះនាំឲ្យមានការប្រថុយប្រថានខ្លាំងចំពោះការវិនិយោគរបស់ពួកគេក្នុងសេដ្ឋកិច្ច។ ដោយសារតែការប្រែប្រួលនៃអតិផរណានេះបានក្លាយជាមូលហេតុនាំឲ្យវិនិយោគគិននឹងមានភាពស្ទាក់ស្ទើរ ក្នុងការបណ្តាក់ទុនវិនិយោគអាជីវកម្ម និងការធ្វើកិច្ចសន្យា ឬគម្រោងធ្វើអ្វីមួយក្នុងរយៈពេលវែង។ បើ កម្រិតវិនិយោគធ្លាក់ចុះ នោះវាអាចនឹងធ្វើឲ្យកំណើនសេដ្ឋកិច្ចរយៈពេលវែងក៏មានការថយចុះផងដែរ។
- ធ្លាក់ចុះភាពប្រកួតប្រជែងនៃទំនិញលើទីផ្សារ៖ ក្នុងពេលបច្ចុប្បន្ន រាល់ទំនិញនៅលើទីផ្សារតែងតែមានការប្រកួតប្រជែងគ្នា ដើម្បីដណ្តើមយកចំណែកទីផ្សាររៀងៗខ្លួន។ ការប្រកួតប្រជែងទាំងនោះ សុទ្ធតែរួមបញ្ចូលគុណភាព និងថ្លៃ។ ប្រសិនបើសេដ្ឋកិច្ចរបស់ប្រទេសមួយមានអតិផរណា នោះថ្លៃទំនិញរបស់ប្រទេសនឹងមានការកើនឡើង ជាហេតុនាំឲ្យពួកគេពិបាកក្នុងនាំចេញផលិតផលយកទៅប្រកួតប្រជែងទៅនឹងផលិតផលទាំងនោះថយចុះ វានឹងធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសនោះមានការធ្លាក់ចុះ។

- ប៉ះពាល់ដល់ការគ្រប់គ្រងអាជីវកម្ម៖ អតិផរណាគឺពាក់ព័ន្ធទៅនឹងការប្រែប្រួលនៃថ្លៃ។ ក្នុងអំឡុងពេលដែលមានអតិផរណាកើនឡើងយ៉ាងឆាប់រហ័ស ម្ចាស់ហាងត្រូវគិតថ្លៃឡើងវិញអោយបានញឹកញាប់ និងត្រូវកែប្រែតារាងតម្លៃនៃទំនិញរបស់សេវាកម្មរបស់ពួកគេទាន់ពេល ដើម្បីចៀសវាងការខាតបង់នានា។ វាទាមទារឲ្យម្ចាស់ហាងមានការតាមដានខ្ពស់ និងមានការគ្រប់គ្រងល្អឲ្យទាន់ពេលវេលា។ ប្រសិនបើម្ចាស់ហាងមិនទទួលបានពត៌មានទាក់ទងនឹងអតិផរណាទាន់ពេលនោះទេ នោះគេនឹងជួបបញ្ហាក្នុងជំនួញរបស់គេជាពុំខាន។

### ១.៣.៣ ផលវិជ្ជមាន

ជាការពិតណាស់ បើទោះបីអតិផរណាបានផ្តល់ផលអវិជ្ជមានយ៉ាងនេះក៏ដោយ ក៏មានចំណុចមួយចំនួនទៀតបង្ហាញពីភាពវិជ្ជមានផងដែរ ដែលភាពវិជ្ជមានទាំងនោះមានដូចខាងក្រោម៖

- ជួយឲ្យសេដ្ឋកិច្ចរីកចម្រើន ៖ ទាក់ទងទៅនឹងចំណុចនេះគឺក្នុងចំនោមមូលហេតុដែលនាំឲ្យអតិផរណាកើនមាន គឺនៅពេលដែលបរិមាណតម្រូវការកាន់តែច្រើនឡើងជាងការផ្គត់ផ្គង់ មូលហេតុនោះហើយទើបមានការជម្រុញឲ្យមានការផលិតកាន់តែច្រើនឡើង និងគុណភាពកាន់តែខ្ពស់ដែលធ្វើឲ្យទំនិញលក់បានច្រើនស្របទៅតាមតម្រូវការ។ ការកើនឡើងនៃបរិមាណទំនិញនេះហើយបានធ្វើឲ្យវិនិយោគគិនទទួលបានប្រាក់ចំណេញច្រើន និងអ្នកវិនិយោគបន្តផលិតទំនិញកាន់តែច្រើន ហើយរដ្ឋក៏អាចប្រមូលពន្ធបានច្រើនជាងមុន ផ្អែកទៅលើការកើនឡើងបរិមាណទំនិញផងដែរ។ ដូចនេះហើយសេដ្ឋកិច្ចរបស់ប្រទេសនឹងមានដំណើរការរលូនទៅមុខបានយ៉ាងល្អ។
- បង្កើនការវិនិយោគ៖ នៅពេលដែលអត្រាអតិផរណាកើនឡើងក៏នាំឲ្យកម្រិតនៃសេដ្ឋកិច្ចមានកំណើន ហើយបានធ្វើឲ្យអត្រានៃការបណ្តាក់ទុនវិនិយោគក៏មានការកើនឡើងដែរ នោះដោយសាតែអ្នកវិនិយោគទាំងនោះបានឃើញនូវឪកាសទទួលបានផលចំណេញពីការបណ្តាក់ទុនទាំងនោះ។ ចំណុចនេះគឺមានន័យថា នៅពេលអ្នកវិនិយោគលក់ទំនិញ ឬសេវាទៅឲ្យអតិថិជនក្នុងតម្លៃមួយខ្ពស់ជាងធម្មតា នោះគេឃើញថាឪកាស នៃការទទួលបានប្រាក់ចំណេញរបស់អ្នកវិនិយោគគឺមានការកើនឡើងខ្ពស់ ដែលជាហេតុក្នុងការលើកទឹកចិត្តពួកគេក្នុងការវិនិយោគក្នុង

ប្រទេសនោះ។

- ផ្តល់ការងារទៅឲ្យប្រជាជន៖ ទាក់ទងនឹងចំណុចខាងលើនេះដែរ នៅពេលដែលមានការកើនឡើងនៃចំនួននៃអ្នកវិនិយោគ នោះធ្វើឲ្យមានការស្រូបយកចំនួនបុគ្គលិកមកបំពេញការងារទៅតាមតម្រូវការការងារទាំងនោះ ដែលធ្វើឲ្យពួកគេទទួលបាននូវប្រាក់ចំណូលទៅតាមនោះដែរ និងមានប្រាក់ចំណូល និងមានជីវភាពប្រសើរជាងមុន។ កំណើនកម្រិតចំណូលនេះហើយបានធ្វើឲ្យមានការកើនឡើងនូវតម្រូវការកាន់តែច្រើន ដែលទាមទារឲ្យមានការផលិត ឬការផ្គត់ផ្គង់កាន់តែកើនស្របតាមតម្រូវការ។

## ១.៤ ការគណនាអត្រាអតិផរណា

អតិផរណាគឺតែងតែកើតឡើងគ្រប់ប្រទេសទាំងអស់នៅលើសកលលោក ហើយក៏ជាបញ្ហាចម្បងមួយដែលគេតែងតែយកចិត្តទុកដាក់ ព្រោះវាក៏ជាចំណែកនៃដំណើរការសេដ្ឋកិច្ចរបស់ប្រទេសមួយដែរ។ ដូច្នេះហើយគេត្រូវធ្វើការវាស់វែងអតិផរណា ដើម្បីតាមដាន និង គ្រប់គ្រងវា។ ជាទូទៅ អតិផរណា ត្រូវបានគេធ្វើការវាស់វែងដោយការគណនាអត្រាអតិផរណា តាមរយៈសន្ទស្សន៍ថ្លៃទំនិញ អត្រាអតិផរណា គឺជាភាគរយនៃការផ្លាស់ប្តូរនៅក្នុងកម្រិតថ្លៃនារយៈពេលណាមួយ (ជាទូទៅមួយឆ្នាំ)។

### ១.៤.១ ការគណនាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ & អត្រាអតិផរណា ( Consumer Price Index ( CPI ) & Inflation Rate )

ដើម្បីឈានទៅដល់ការគណនាអត្រាអតិផរណាបាន គឺគេត្រូវយល់ពីសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ និងរបៀបគណនារកសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់។ សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ ដែលហៅកាត់ថា ( CPI : សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ ) គឺជារង្វាស់នៃថ្លៃទូទៅនៃទំនិញ និង សេវាកម្មដែលត្រូវបានទិញដោយអ្នកប្រើប្រាស់។ ដើម្បីធ្វើការគណនារកសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ គឺគេត្រូវកំណត់រកកន្ត្រកទំនិញ និងសេវាកម្មដែលអ្នកប្រើប្រាស់ទិញ។ ខាងក្រោមនេះគឺជាជំហ៊ានសំខាន់ៗក្នុងការគណនារកសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់៖

#### ១.៤.១.១ ការកំណត់កន្ត្រកនៃសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់

គេត្រូវកំណត់ថា ប្រភេទទំនិញណាខ្លះដែលត្រូវដាក់បញ្ចូលទៅក្នុងកន្ត្រកនៃសន្ទស្សន៍ថ្លៃទំនិញ។ ជាក់ស្តែងនៅប្រទេសកម្ពុជាមានការបែងចែកប្រភេទទំនិញចំនួន ១២ ក្រុមក្នុងកន្ត្រកនៃ

សន្ទស្សន៍ថ្លៃទំនិញ[2]ដូចខាងក្រោម៖

១. អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង

២. ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់

៣. សម្លៀកបំពាក់ និងស្បែកជើង

៤. ផ្ទះសម្បែង ទឹក អគ្គីសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត

៥. គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ

៦. សុខាភិបាល

៧. ការដឹកជញ្ជូន

៨. គមនាគមន៍

៩. ការកម្សាន្ត និងវប្បធម៌

១០. ការសិក្សា

១១. ភោជនីយដ្ឋាន

១២. ទំនិញ និងសេវាកម្មផ្សេងៗ

**១.៤.១.២. ស្វែងរកតម្លៃ** ( Find the Price )

កំណត់ស្វែងរកថ្លៃនៃទំនិញ និង សេវាកម្មនៅក្នុងកន្ត្រកសម្រាប់ចំណុចនីមួយៗក្នុងពេលវេលាណាមួយ។ បើយើងក្រលេកមើលមកប្រទេសកម្ពុជាវិញ គឺគេប្រមូលទិន្នន័យថ្លៃទំនិញ និង សេវាកម្មទាំង ១២ ក្រុមជាប្រចាំខែ ហើយគណនារកសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ជាប្រចាំខែដូចគ្នា។

**១.៤.១.៣. គណនាថ្លៃកន្ត្រកទំនិញ** ( Compute the basket's cost )

គេត្រូវប្រើប្រាស់ទិន្នន័យថ្លៃទំនិញ ដើម្បីគណនាថ្លៃកន្ត្រកទំនិញ និងសេវាកម្មនៅត្រង់កាលវេលាផ្សេងៗគ្នា។ គេធ្វើការគណនាទៅបានដោយត្រូវដឹងពីថ្លៃទំនិញ និងបរិមាណទំនិញទៅតាមប្រភេទទំនិញនីមួយៗ និងធ្វើការបូកសរុបថ្លៃទំនិញទាំង១២ ក្រុមទាំងអស់ក្នុងគ្រាណាមួយ។ ឧទាហរណ៍៖ ការគណនាថ្លៃកន្ត្រកទំនិញ ( តារាង១.១ )

[2] ប្រភព៖ របាយការណ៍ស្ថានភាពអតិផរណារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

(ក) **តម្លៃគោលនៃកន្ត្រកថ្លៃទំនិញ ក្នុងខែ ធ្នូ ២០១៥**

| ថ្លៃកន្ត្រកទំនិញ | | | តម្លៃសរុបនៃកន្ត្រកថ្លៃទំនិញ |
|---|---|---|---|
| **មុខទំនិញ** | **បរិមាណ** | **ថ្លៃក្នុងមួយឯកតា** | |
| អង្ករសូម៉ាលី | ៥ | ៣,៥០០៛ | ១៧,៥០០៛ |
| ត្រីរ៉ស់ | ៤ | ១៦,៨០០៛ | ៦៧,២០០៛ |
| ស្ពីក្តោប | ១០ | ២,១៦០៛ | ២,១៦០០៛ |
| ត្រសក់ | ៥ | ២,១០០៛ | ១០,៥០០៛ |
| **តម្លៃគោលនៃកន្ត្រកថ្លៃទំនិញ** | | | **១១៦,៨០០៛** |

(ខ) **តម្លៃគ្រាណាមួយ( បច្ចុប្បន្ន )នៃកន្ត្រកថ្លៃទំនិញ ក្នុងខែ ធ្នូ ២០១៦**

| ថ្លៃកន្ត្រកទំនិញ | | | តម្លៃសរុបនៃកន្ត្រកថ្លៃទំនិញ |
|---|---|---|---|
| **មុខទំនិញ** | **បរិមាណ** | **ថ្លៃក្នុងមួយឯកតា** | |
| អង្ករសូម៉ាលី | ៥ | ៣,៦០០៛ | ១៨,០០០៛ |
| ត្រីរ៉ស់ | ៤ | ១៩,២៤០៛ | ៧៦,៩៦០៛ |
| ស្ពីក្តោប | ១០ | ២,៤៦០៛ | ២៤,៦០០៛ |
| ត្រសក់ | ៥ | ២,៤០០៛ | ១២,០០០៛ |
| **តម្លៃគោលនៃកន្ត្រកថ្លៃទំនិញ** | | | **១៣១,៥៦០៛** |

### ១.៤.១.៤. ជ្រើសរើសឆ្នាំគោល និងគណនាសន្ទស្សន៍ថ្លៃ (Choose a base year and compute the price index )

ដើម្បីគណនាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ទៅបាន គឺត្រូវគណនារកថ្លៃកន្ត្រកទំនិញក្នុងឆ្នាំគោល ( CPI basket at base period prices) និងគណនារកថ្លៃកន្ត្រកទំនិញបច្ចុប្បន្ន ( CPI basket at current period prices) ជាមុនសិន។ ដូច្នេះហើយ គេត្រូវកំណត់ឆ្នាំណាមួយជាឆ្នាំគោលដែលជាគោលទល់នឹងឆ្នាំផ្សេងទៀតដែលនឹងត្រូវយកមកប្រៀបធៀប។ ( ការជ្រើសរើសឆ្នាំគោលគឺធ្វើដោយតាមទំនើងចិត្ត ដោយសារតែសន្ទស្សន៍នេះត្រូវប្រើប្រាស់ដើម្បីវាស់អំពីបម្រែបម្រួលនៅ

ក្នុងថ្លៃទ្រទ្រង់នៃការរស់នៅ)។ នៅពេលដែលឆ្នាំគោលត្រូវបានជ្រើសរើសរួច នោះសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់នឹងត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$\textbf{Consumer Price Index ( CPI )}^{3} = \frac{\textit{Cost of CPI basket at current period prices}}{\textit{Cost of CPI basket at based period prices}} \times \textbf{100}$$

ពោលគឺ ថ្លៃនៃកន្រ្តកទំនិញ និងសេវាកម្មនៅក្នុងឆ្នាំនីមួយៗត្រូវចែកជាមួយនឹងថ្លៃនៃកន្រ្តកទំនិញនៅក្នុងឆ្នាំគោល ហើយបន្ទាប់មកអនុបាតនេះត្រូវគុណនឹង ១០០។ លេខដែលទទួលបាននឹងហើយ គឺជាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់។

ក្រឡេកមើលតារាង១.១ ថ្លៃកន្រ្តកទំនិញក្នុងឆ្នាំ ២០១៥ គឺមានតម្លៃស្មើរ ១១៦,៨០០៛នៃថ្លៃកន្រ្តកទំនិញ។ ក្នុងឆ្នាំ ២០១៦ គឺមានតម្លៃស្មើរ ១៣១,៥៦០៛។ គេអាចយកតម្លៃខាងលើមកគណនាសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងឆ្នាំ២០១៥ និង ឆ្នាំ២០១៦ បានដូចខាងក្រោម៖

- សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងខែ ធ្នូ ឆ្នាំ២០១៥៖

  CPI ក្នុងឆ្នាំ ២០១៥: $\frac{១១៦,៨០០}{១១៦,៨០០} \times ១០០ = ១០០$

- សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងខែ ធ្នូ ឆ្នាំ២០១៦៖

  CPI ក្នុងឆ្នាំ ២០១៦: $\frac{១៣១,៥៦០}{១១៦,៨០០} \times ១០០ = ១១២.៦៧$

#### ១.៤.១.៥. គណនាអត្រាអតិផរណា ( Compute the Inflation Rate )

ការប្រើប្រាស់សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ ដើម្បីគណនាអត្រាអតិផរណាដែលជាបម្រែបម្រួលជាភាគរយនៅក្នុងសន្ទស្សន៍ថ្លៃ ចេញពីរយៈពេលមួយទៅរយៈពេលមួយទៀត។ ដើម្បីគណនារកអត្រាអតិផរណាបាន គេត្រូវប្រើប្រាស់រូបមន្តដូចខាងក្រោម៖

$$\textbf{Inflation Rate}^{4} = \frac{(\textit{CPI in current year} - \textit{CPI in previous year})}{\textit{CPI in previous year}} \times \textbf{100}$$

[3] សៀវភៅ Foundations of Macroeconomics, Chapter 7, The CPI and the Cost of Living, Pg.155 និពន្ធដោយលោក Robin Bade និងលោក Michael Parkin

[4] សៀវភៅ Foundations of Macroeconomics, Chapter 7, The CPI and the Cost of Living, Pg.155 និពន្ធដោយលោក Robin Bade និងលោក Michael Parkin

ឧទាហរណ៍៖ ការគណនា អត្រាអតិផរណា

ដើម្បីគណនារកអត្រាអតិផរណាបាន គេអាចយកតម្លៃសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងឆ្នាំ២០១៥ និង ឆ្នាំ២០១៦ ដែលទើបតែគណនាខាងលើមកប្រើប្រាស់ ដោយសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ក្នុងឆ្នាំ២០១៦ ស្មើរ ១១២.៦៤ ហើយក្នុងឆ្នាំ២០១៥ ស្មើរ ១០០។ ដូច្នេះអត្រាអតិផរណាក្នុងឆ្នាំ ២០១៦ គឺ៖

$$\text{អត្រាអតិផរណា} = \frac{(១១២.៦៤ - ១០០)}{១០០} \times ១០០ = ១២.៦៤\%$$

# ជំពូកទី២
# ការណើសិក្សាលើស្ថានភាព
# អតិផរណានៃប្រទេសដនៃ

# ជំពូកទី ២៖ ករណីសិក្សាលើស្ថានភាពអតិផរណានៃប្រទេសថៃ

## ២.១ ស្ថានភាពអតិផរណានៃប្រទេសថៃ

### ២.១.១ ស្ថានភាពទូទៅនៃប្រទេសថៃ

ព្រះរាជាណាចក្រថៃ គឺជាប្រទេសមួយដែលស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាសមាជិករបស់សមាគមន៍អាស៊ានផងដែរ។ ប្រទេសថៃគឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនក្នុងចំណោមប្រទេសផ្សេងៗទៀតនៅក្នុងសមាគមន៍អាស៊ាន។ ប្រទេសថៃនៅតែបន្តកំណើនសេដ្ឋកិច្ចរឹងមាំ ទោះបីជាធ្លាប់ជួបប្រទះនូវបញ្ហាវិបត្តិសេដ្ឋកិច្ចពីមុនក្តី។ នៅក្នុងឆ្នាំ ២០១៦ នេះ សេដ្ឋកិច្ចរបស់ប្រទេសថៃបានកើនឡើង ៣.២ភាគរយ បើធៀបនឹងឆ្នាំ ២០១៥។ ការប្រសើរឡើងនៃសេដ្ឋកិច្ចនេះគឺបណ្តាលមកពីការកើនឡើងការប្រើប្រាស់ផ្ទាល់ខ្លួន តាមរយៈការកើនឡើងចំណូលរបស់កសិករ វិធានការណ៍ជម្រុញរបស់រដ្ឋាភិបាល គម្រោងកញ្ចប់ថវិការសារពើពន្ធ និងការលូតលាស់ឡើងវិញក្នុងការនាំចេញទំនិញ។ ទន្ទឹមនឹងការលូតលាស់នៃសេដ្ឋកិច្ចរបស់គេ ប្រទេសថៃតែងតែយកចិត្តទុកដាក់លើបញ្ហាអតិផរណាផងដែរ ព្រោះវាក៏ជាកត្តាប្រឈមមួយដ៏សំខាន់ ដែលជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចជាតិផងដែរ។

ចាប់តាំងពីឆ្នាំ ២០១០ រហូតមកដល់ ២០១៦ អត្រាអតិផរណារបស់ប្រទេសថៃក្នុងឆ្នាំ ២០១១ គឺបានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងកម្រិត ៣.៨ភាគរយ ដែលក្នុងរយៈពេលនោះស្ថានភាពសេដ្ឋកិច្ចថៃកំពុងតែជួបប្រទះភាពតានតឹងដែលទទួលរងឥទ្ធិពលទាំងខាងក្រៅ និងខាងក្នុងប្រទេស។ រហូតដល់ឆ្នាំ ២០១៦ នេះសេដ្ឋកិច្ចរបស់ថៃចាប់ផ្តើមប្រសើរឡើងសន្សឹមៗ បើក្រឡេកមើលអត្រាអតិផរណាវិញ គឺចាប់ផ្តើមថយចុះបន្តិចម្តងៗ ចាប់តាំងពីឆ្នាំ ២០១២ ដែលធ្លាក់ចុះពីឆ្នាំ ២០១១ ក្នុងអត្រា ០.៨ភាគរយ ហើយនៅក្នុងឆ្នាំ ២០១៦ នេះគឺនៅសល់តែ ០.២ភាគរយតែប៉ុណ្ណោះ។ ខាងធនាគារជាតិថៃតែងតែធ្វើការព្យាករណ៍អត្រាអតិផរណារបស់ខ្លួននាត្រីមាសខាងមុខជាមុន ដើម្បីគ្រប់គ្រងអតិផរណាឲ្យបានប្រសើរឡើង។

### ២.១.២ អត្រាអតិផរណាប្រចាំឆ្នាំ

**តារាង២.១ ៖ អតិផរណាប្រចាំឆ្នាំ**

| ឆ្នាំ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|---|---|
| អត្រាអតិផរណា គិតជា (%) | ៣.៣ | ៣.៨ | ៣.០ | ២.២ | ១.៩ | ០.៩ | ០.២ |

(ប្រភព: ដកស្រង់របាយការណ៍អតិផរណារបស់ធនាគារជាតិប្រទេសថៃចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៦)

តាមរយៈតារាងអតិផរណាប្រចាំឆ្នាំរបស់ថៃ ឃើញថាអត្រាអតិផរណាក្នុងឆ្នាំ ២០១១ បានកើនឡើងខ្ពស់ជាងគេរហូតដល់ ៣.៨ភាគរយ ហើយចុះនៅសល់ត្រឹម ៣.០ភាគរយក្នុងឆ្នាំ ២០១២ ហើយនៅតែបន្តធ្លាក់ចុះសន្សឹមៗ រហូតនៅត្រឹមតែ ០.២ភាគរយនៅក្នុងឆ្នាំ ២០១៦ នេះ។

### ២.១.៣ មូលហេតុបណ្តាលឲ្យមានអតិផរណា

តាមរយៈការសិក្សាទៅលើអតិផរណារបស់ប្រទេសថៃចាប់តាំងពីឆ្នាំ ២០១០ រហូតដល់ឆ្នាំ ២០១៦ យើងសង្កេតឃើញថា អត្រាអតិផរណាក្នុងឆ្នាំ ២០១១ គឺមានអត្រាខ្ពស់ជាងឆ្នាំណាណាទាំងអស់។ វាមានកត្តាជាច្រើនដែលជាសម្ពាធក្នុងការជម្រុញអត្រាអតិផរណាកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ ២០១០ ដែលជាកម្រិតអតិបរមា ចន្លោះពីឆ្នាំ ២០១០-២០១៦។

តាមរយៈការសិក្សាស្រាវជ្រាវ បញ្ហាអតិផរណា គឺចាប់ផ្តើមកំរើកឡើងចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០១០ ខណៈពេលដែលសេដ្ឋកិច្ចកំពុងតែចាប់ផ្តើមរីកលូតលាស់ដែលនាំឲ្យតម្រូវការកើនឡើង។ ម្យ៉ាងវិញទៀត ផលប៉ះពាល់ដល់វិធានការណ៍របស់រដ្ឋាភិបាល និងបញ្ហាផ្សេងៗនៅលើពិភពលោក ក៏បានជះឥទ្ធិពលដល់សេដ្ឋកិច្ចរបស់ប្រទេសថៃរហូតធ្វើឲ្យអតិផរណាក្នុងឆ្នាំ ២០១១ មានការកើនឡើងគួរឲ្យព្រួយបារម្ភ។ ដូចដែលបានដឹងស្រាប់ហើយថា ការកើនឡើងនៃ អត្រាអតិផរណាក្នុងកម្រិតខុសគ្នាពីធម្មតា គឺជាបញ្ហាដែលគួរឲ្យមានការព្រួយបារម្ភដល់សេដ្ឋកិច្ច និង ត្រូវគិតគូរស្វែងរកដំណោះស្រាយវាឲ្យបានប្រសើរឡើង។ ដើម្បីឈានទៅដល់ការដោះស្រាយលើបញ្ហាអតិផរណា គឺត្រូវកំណត់ឲ្យច្បាស់ពីឬសគល់នៃបញ្ហាដែលនាំឲ្យមានអតិផរណាកើនឡើង។ ដូច្នេះហើយ សូមលើកយកនូវប្រភពបញ្ហាដែលនាំឲ្យមានការកើនឡើងអតិផរណាចន្លោះឆ្នាំ ២០១០-២០១១។

#### ២.១.៣.១ ថ្លៃក្នុងកត្តាផលិតកម្ម

ថ្លៃដើមក្នុងកត្តាផលិតកម្មគឺជាកត្តាចម្បងក្នុងការកំណត់ថ្លៃទំនិញ ឬ សេវាកម្ម។ ដូច្នេះថ្លៃទំនិញ ឬ សេវាកម្មមានការឡើងចុះគឺអាស្រ័យទៅលើថ្លៃដើមក្នុងកត្តាផលិតកម្ម មានដូចជា វត្ថុធាតុដើម និងកំលាំងពលកម្ម។ ប្រសិនបើថ្លៃណាមួយក្នុងចំណោម កត្តាទាំងពីរនេះមានការប្រែប្រួលវានឹងជះឥទ្ធិពលដល់ថ្លៃផលិតកម្ម។ ជាការពិតណាស់ចាប់តាំងពីឆ្នាំ ២០១០ ការប្រែប្រួលនៃសេដ្ឋកិច្ចខាងក្រៅ បញ្ហាអាកាសធាតុបានជម្រុញឲ្យកត្តាទាំងពីរខាងលើមានការប្រែប្រួលម្តងបន្តិចៗ។

- ថ្លៃវត្ថុធាតុដើមៈ រាល់ទំនិញវត្ថុធាតុដើមជាច្រើនបានបន្តឡើងថ្លៃព្រមគ្នាស្របពេលដែលថ្លៃទំនិញពិភពលោកនិងប្រេងពិភពលោកបានបន្តកើនឡើង។មិនត្រឹមតែប៉ុណ្ណោះផលិតផល

កសិកម្មនៅតែបន្តឡើងថ្លៃ ដោយសារតែអាកាសធាតុក្នុងប្រទេសមិនអំណោយផលគឺតែងតែមានគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលធ្វើឲ្យការប្រមូលទិន្នផលកសិកម្មនៅតែបន្តក្នុងកម្រិតទាបរយៈពេលច្រើនឆ្នាំមកហើយ។ ជាពិសេសដំណាំសំខាន់ៗដូចជា ដំណាំកៅស៊ូ ដូងប្រេង ប្រេងសណ្តែក និង ដំឡូងមីនៅតែបន្តឡើងថ្លៃ ក៏ព្រោះតែកង្វះខាតក្នុងការផ្គត់ផ្គង់ ដែលកើតឡើងព្រោះតែគ្រោះធម្មជាតិទាំងនោះ ខណៈពេលដែលតម្រូវការពិភពលោកនៅតែបន្តកើនឡើង។

- ថ្លៃពលកម្មៈ ថ្លៃពលកម្មនៅតែបន្តកើនឡើងទៅតាមការកើនឡើងតម្រូវការពលកម្ម និងគោលនយោបាយកែប្រែកម្រិតប្រាក់ឈ្នួលអប្បបរិមារបស់រដ្ឋាភិបាល។ ទិន្នន័យទីផ្សារពលកម្មក្នុងឆ្នាំ ២០១១ ក្នុងត្រីមាសទី១ បានបង្ហាញថាការប្រសើរឡើងនៃសេដ្ឋកិច្ច វាពិតជាបង្កើននូវតម្រូវការពលកម្មដែលធ្វើឲ្យថ្លៃពលកម្មកើនឡើង។ ម៉្យាងទៀតបើក្រឡេកមើល អត្រានិកម្មភាព ក្នុងខែ មេសា ឆ្នាំ ២០១១ គឺស្ថិតនៅអត្រា ០.៦ ភាគរយ ជាអត្រាទាបបំផុតចាប់ពីឆ្នាំ ២០០១។

### ២.១.៣.២ Pass-through Cost[5]

ជាការពិតណាស់ រាល់ថ្លៃទំនិញត្រូវបានគេកំណត់ គឺយោងទៅតាមថ្លៃដើមផលិតកម្មដោយមានការបូកបញ្ចូលគ្នាទៅតាមថ្លៃវត្ថុធាតុដើម ប្រាក់ឈ្នួលពលកម្ម ការបូកបញ្ចូលប្រាក់ចំណេញ រៀងៗខ្លួនទៅតាមការប្រកួតប្រជែងនៅលើទីផ្សារ។ ប៉ុន្តែនៅពេលដែលថ្លៃដើមផលិតកម្មមានការកើនឡើងគ្រប់សហគ្រាសរោងចក្រទាំងអស់ នោះនឹងក្លាយជាសម្ពាធដែលនាំឲ្យថ្លៃទំនិញកើនឡើងថ្លៃព្រមៗគ្នា ដែលជាហេតុនាំឲ្យមានអតិផរណា។ នៅពេលដែលថ្លៃដើមផលិតកម្មបានកើនឡើងក្នុង រយៈពេលខ្លី ជាធម្មតាផលិតករអាចទ្រាំទ្រក្នុងការរក្សាតម្លៃទំនិញមិនឲ្យឡើងថ្លៃបាន តាមរយៈកាត់បន្ថយប្រាក់ចំណេញរបស់ខ្លួន។ ប៉ុន្តែបើការកើនឡើងដល់កម្រិតមួយដែលមិនអាចទ្រាំទ្ររួច ហើយមានការកើនឡើងក្នុងរយៈពេលយូរផងទៀតនោះ ផលិករត្រូវតែកែប្រែតម្លៃទំនិញរបស់ខ្លួនបន្ថែមតាមការឡើងថ្លៃផលិតកម្មក្នុងពេលបច្ចុប្បន្ន បូកជាមួយការរំពឹងទុកនៃការកើនឡើងនៃអតិផរណានាពេលខាងមុខ ដើម្បីឲ្យពួកគេអាចជៀសផុតពីការខាតបង់ និងអាចបន្តនូវអាជីវកម្មរបស់ពួកគេទៅមុខបាន។ ចាប់តាំងពីឆ្នាំ ២០១០ មក Pass through Cost បានបន្តកើនឡើងគួរឲ្យកត់សម្គាល់។ ការកើនឡើងនេះគឺដោយសារតែ ថ្លៃពលកម្ម ថ្លៃប្រេង

[5] Pass through Cost គឺជាថ្លៃទំនិញ ឬ សេវាកម្ម វត្ថុធាតុដើម សហគ្រាស ចំណាយបានកើនឡើងបន្តគ្នារហូតដល់ផលិតផលចុងក្រោយ។

និងថ្លៃប្រតិបត្តិការនានានៅតែបន្តកើនឡើងជាងមុន និង ការរីកលូតលាស់ខាងផ្នែកតម្រូវការដែលបណ្ដាលមកពីគោលនយោបាយរបស់រដ្ឋាភិបាលថ្មី មានដូចជាការកើនឡើងថ្លៃប្រាក់ឈ្នួលអប្បបរិមា គម្រោង Agriculture product pleading scheme[6] និង គោលនយោបាយផ្សេងៗទៀត។

នៅពាក់កណ្ដាលឆ្នាំ ២០១០ ខាងសហគ្រាសទាំងអស់មិនមានលទ្ធភាពក្នុងការរក្សាថ្លៃទំនិញឲ្យនៅកម្រិតទាបដូចដែលបានសន្យារជាមួយនឹងអាជ្ញាធរបានឡើយ ។ ម៉្យាងវិញទៀង ការឡើងថ្លៃទំនិញក៏ឃើញថាកើតមាននៅក្នុងប្រទេសដ៏ទៃ នៅក្នុងអាស៊ីតាមរយៈការបន្តដំណើររីកលូតលាស់នៃដំណើរសេដ្ឋកិច្ច និងការកើនឡើងថ្លៃទំនិញពិភពលោក ដែលជាហេតុជម្រុញថ្លៃទំនិញក្នុងស្រុកកើនឡើងតាមរយៈការកើនឡើងថ្លៃទំនិញនាំចូល។ លើសពីនេះទៅទៀត ការឡើងថ្លៃដើមផលិតកម្មរបស់សហគ្រាស និងការរំពឹងទុកអតិផរណានាពេលខាងមុខរបស់ពួកគេ គឺកាន់តែធ្វើឲ្យ Pass through Cost ងាយស្រួលផ្ទេរទៅដល់ផលិតផលចុងក្រោយឡើងថ្លៃនៅពេលខាងមុខ។

### ២.១.៤ បញ្ហាប្រឈម

ជុំវិញបញ្ហាអតិផរណានៅក្នុងប្រទេសថៃគឺមានការគំរាមគំហែងពីកត្តាខាងក្រៅ និងខាងក្នុងប្រទេសដែលជាហេតុជះឥទ្ធិពលដល់អតិផរណាឲ្យមានការកើនឡើង។ បញ្ហាប្រឈមទាំងនោះរួមមាន៖

- ការកើនឡើងថ្លៃប្រេងនិងទំនិញក្នុងទីផ្សារសកលលោក៖ ការកើនឡើងនេះកើតឡើងពីកត្តាខាងក្រៅដែលជះឥទ្ធិពលដល់សេដ្ឋកិច្ចក្នុងប្រទេស ក៏ព្រោះតែការប្រមើលមើលឃើញថាសេដ្ឋកិច្ចមានការរីកលូតលាស់ដែលជាហេតុ ធ្វើឲ្យមានតម្រូវការទំនិញកើនឡើងខ្ពស់ជាងមុនខណៈពេល ការផ្គត់ផ្គង់ប្រេងនៅលើពិភពលោកកំពុងតែមានបញ្ហាដោយសារតែ អស្ថេរភាពនយោបាយ ក្នុងប្រទេសនាំចេញប្រេង។ កត្តានេះគឺហេតុដែលជះឥទ្ធិពលដល់ថ្លៃផលិតកម្មក្នុងស្រុកកើនឡើង តាមរយៈការកើនឡើងទំនិញនាំចូល និង ការប្រើប្រាស់ប្រេងក្នុងកត្តាផលិតកម្មផងដែរ។
- វិធានការណ៍របស់រដ្ឋាភិបាល៖ ជាការពិតណាស់ដែលគោលនយោបាយរបស់រដ្ឋាភិបាលដែលបានបង្កើតឡើង គឺដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋ ប៉ុន្តែស្របគ្នានោះដែរ ផលប៉ះពាល់អវិជ្ជមានរបស់វាក៏មានវត្តមានដែលជះឥទ្ធិពលមកលើអតិផរណា។

[6] Agricultural Products Pledging Scheme គឺជាគម្រោងរបស់រដ្ឋាភិបាលក្នុងការប្រមូលទិញនូវផលិតផលកសិកម្មក្នុងកម្រិតថ្លៃណាមួយ ហើយប្រជាពលរដ្ឋអាចយកផលិតផលកសិកម្មរបស់ពួកគេយកទៅលក់នៅលើទីផ្សារបានវិញនៅពេលដែលថ្លៃនៅលើទីផ្សារខ្ពស់ជាងថ្លៃដែលគេលក់ទៅឲ្យរដ្ឋាភិបាល។

ការកែប្រែលើប្រាក់បៀវត្សមន្ត្រីរាជការ និងប្រាក់ឈ្នួលពលកម្មអប្បបរមាឲ្យប្រសើរឡើងជាងមុនដែលជាហេតុឲ្យពួកគេមានលទ្ធភាពជាងមុនក្នុងការចំណាយ និងការប្រើប្រាស់ផ្ទាល់ខ្លួនមានការកើនឡើងនាំឲ្យតម្រូវការសរុបកើនឡើងតាមនោះដែរ។ មូលហេតុនេះហើយទើបមានការកើនឡើងនៃថ្លៃទំនិញ និងសេវាកម្ម។ ម្យ៉ាងវិញទៀត គម្រោង Agricultural Products Pledging Scheme បានធ្វើឲ្យតម្លៃផលិតផលកសិកម្មកើនឡើងថ្លៃ។ ដូច្នេះហើយការកើនឡើងនូវតម្រូវការ និងការរំពឹងទុកនៃអតិផរណាបានធ្វើឲ្យ Pass-through Cost របស់ថ្លៃផលិតកម្មកើនឡើង និងផ្ទេរថ្លៃទៅដល់ផលិតផលចុងក្រោយ។

- គ្រោះទឹកជំនន់ ៖ ជាធម្មតា នៅពេលដែលមានគ្រោះធម្មជាតិកើតឡើង ជាពិសេសគ្រោះទឹកជំនន់តែងតែបង្ករផលវិបាកដល់សេដ្ឋកិច្ចក្នុងប្រទេសទាំងមូល មិនថាការផលិត ឬជីវភាពរបស់ប្រជាជន។ ក្នុងឆ្នាំ ២០១១ ទឹកជំនន់បានវាយលុកពាសពេញតំបន់សេដ្ឋកិច្ចក្នុងប្រទេសថៃ និងផ្តល់ប៉ះពាល់យ៉ាងខ្លាំងដល់អតិផរណា។ ទឹកជំនន់ក៏បានសម្លាប់ប្រជាពលរដ្ឋជិត ៤០០ នាក់ និង បំផ្លិចបំផ្លាញដំណាំស្រូវរាប់លានតោន ធ្វើឲ្យសំណង់អាគាររោងចក្រជាច្រើនដូចជានៅតំបន់សហគ្រាស Bangkadee និងតំបន់រោងចក្រផ្សេងៗទៀតនៅភាគខាងកើតនៃទីក្រុងបាងកកខូចខាតនាំឲ្យរោងចក្រជាច្រើនត្រូវបង្ខំបិទទ្វារ។ បញ្ហាទឹកជំនន់នេះបានធ្វើឲ្យវិស័យកសិកម្ម និងផលិតកម្មនៅក្នុងប្រទេសថៃមានភាពទន់ខ្សោយ ដោយការផ្គត់ផ្គង់ក្នុងស្រុកធ្លាក់ចុះ ស្របពេលដែលតម្រូវការនៅតែរឹងមាំដែលជាហេតុនាំឲ្យថ្លៃទំនិញផ្សេងៗ បន្តកើនឡើងទៅមុខទៀត។ មិនត្រឹមតែប៉ុណ្ណោះ ការជួញដូរទំនិញ និងសេវាកម្ម វិស័យទេសចរណ៍ និងវិស័យដែលជាប់ពាក់ព័ន្ធផ្សេងៗទៀតក៏ធ្លាក់ក្នុងស្ថានភាពមិនល្អដែលនាំឲ្យសេដ្ឋកិច្ចមានការធ្លាក់ចុះតាមដែរ។ ទឹកជំនន់មិនត្រឹមតែធ្វើឲ្យផលិតផលកសិកម្ម និងឧស្សាហកម្មឡើងថ្លៃនោះទេ សូម្បីតែចង្វាក់ផលិតកម្ម និងការដឹកជញ្ជូនក៏ទទួលរងផលប៉ះពាល់ផងដែរ។ កត្តាទាំងនេះហើយដែលធ្វើឲ្យ Pass-through Cost មានការកើនឡើងបន្តទៀត ដែលជាហេតុនាំឲ្យអតិផរណាកើនឡើង។

### ២.១.៥ ដំណោះស្រាយរបស់រដ្ឋាភិបាលលើបញ្ហាអតិផរណា

បញ្ហាសេដ្ឋកិច្ចដែលកើតមានឡើងនៅក្នុងប្រទេស គឺទាមទារឲ្យរដ្ឋាភិបាលចូលរួមរិះរកដំណោះស្រាយក្នុងការធ្វើឲ្យសេដ្ឋកិច្ចរបស់ខ្លួនមានភាពនឹងនរនិង បន្តដំណើរឆ្ពោះទៅមុខឲ្យបានល្អប្រសើរជាងមុន។ ដូច្នេះហើយរដ្ឋាភិបាលថៃតែងតែយកចិត្តទុកដាក់ជានិច្ច នៅពេលដែលសេដ្ឋកិច្ចរបស់ពួកគេជួបប្រទះនូវបញ្ហាផ្សេងៗ ពួកគេតែងតែចូលរួមប្រតិបត្តិការជាមួយនឹងដៃគូរ

វិនិយោគ និង ពលរដ្ឋគ្រប់រូបពីបញ្ហាអតិផរណាដែលបានបកស្រាយខាងលើគឺសុទ្ធតែមានការលូក ដៃចូលរួម និងដោះស្រាយពី រដ្ឋាភិបាល។

ក្នុងករណីដែលថ្លៃដើមផលិតកម្មមានការកើនឡើង ខាងរដ្ឋាភិបាលបានកាត់បន្ថយថ្លៃដើម តាមរយៈអត្រាពន្ធលើប្រេង ដើម្បីសម្រាលឲ្យថ្លៃប្រេងក្នុងការប្រើប្រាស់មានសភាពធូរស្រាលជាង មុន រីឯខាងផលិតករវិញ ក៏អាចមានភាពធូរស្រាលក្នុងការចំណាយលើថ្លៃប្រេងក្នុងការប្រើប្រាស់ គ្រឿងម៉ាស៊ីន ក្នុងកត្តាផលិតកម្មរបស់ពួកគេ។ បើក្រឡេកមើលពីបញ្ហាទឹកជំនន់វិញ វាគឺជាសម្ពាធ មួយមកលើថ្លៃទំនិញដែលមិនអាចជៀសផុត។ ដូច្នេះរដ្ឋាភិបាលបានបង្កើតគម្រោងគ្រប់គ្រងទឹក ជំនន់ ការពារកុំឲ្យទឹកជំនន់វាយលុកក្នុងសេដ្ឋកិច្ច។ គម្រោងគ្រប់គ្រងទឹកជំនន់ត្រូវបានគេចែក ចេញជាពីរ គឺគម្រោងគ្រប់គ្រងទឹកជំនន់បន្ទាន់ និងគម្រោងគ្រប់គ្រងទឹកជំនន់រយៈពេលវែង។

- គម្រោងគ្រប់គ្រងទឹកជំនន់បន្ទាន់មានដូចជា៖
    - ការអភិវឌ្ឍលើទំនប់ទឹក និងប្រព័ន្ធបង្ហូរទឹក
    - ការអភិវឌ្ឍប្រព័ន្ធទិន្នន័យ និងប្រព័ន្ធប្រកាសអាសន្ននូវបញ្ហាទឹកជំនន់ដើម្បីឲ្យមាន ការការពារ និងប្រុងប្រយ័ត្នទុកជាមុន
    - ការអភិវឌ្ឍប្រព័ន្ធការពារទឹកជំនន់ និងប្រព័ន្ធដែលជួយសម្រាលកម្រិតទឹកជំនន់ឲ្យ ឆាប់ស្រកចុះ ជាពិសេសកន្លែងដែលទទួលរងគ្រោះទឹកជំនន់។
- គម្រោងគ្រប់គ្រងទឹកជំនន់រយៈពេលវែងមានដូចជា៖
    - ការកសាងទំនប់ទឹក និងការដាំដុះដើមឈើ
    - ការសាងសង់ទំនប់ទឹកនៅ Yom Sakaekrung, Nan, Pasak River
    - ការជួសជុលតំបន់កសិកម្មដែលទទួលការលុកលុយពីទឹកជំនន់
    - គម្រោងបញ្ចៀសទឹកជំនន់
    - ផ្ដល់នូវការព្យាករណ៍ទឹកជំនន់ និងប្រព័ន្ធប្រកាសអាសន្ន។

យោងតាមគម្រោងគ្រប់គ្រងទឹកជំនន់ទាំងពីរខាងលើ សុទ្ធតែបង្កើតឡើងក្នុងគោលបំណង ជួយស្តារសេដ្ឋកិច្ចឲ្យល្អប្រសើរ។ គម្រោងគ្រប់គ្រងទឹកជំនន់បន្ទាន់គឺបង្កើតឡើងដើម្បីជួយដោះ ស្រាយនូវបញ្ហាទឹកជំនន់ ដែលកំពុងតែកើតឡើងឲ្យបានឆាប់រហ័សភ្លាមៗដើម្បីឲ្យសេដ្ឋកិច្ចមាន សភាពប្រសើរឡើងវិញ ហើយអាចបន្ថយនូវសម្ពាធដែលធ្វើឲ្យថ្លៃកើនឡើងមានភាពធូរស្រាល ដែលធ្វើឲ្យទំនិញទូទៅមានការថយចុះមកវិញ។ ចំណែកឯគម្រោងគ្រប់គ្រងទឹកជំនន់រយៈពេល វែងគឺបង្កើតឡើងដើម្បីបង្ការមិនឲ្យមានហេតុការណ៍បែបនេះកើតឡើងនៅពេលក្រោយទៀត។

សម្រាប់ករណី Pass-through cost កើនឡើង ខាងធនាគារជាតិនៃប្រទេសថៃបានបង្កើតកម្មវិធីផ្លាស់ប្តូរព័ត៌មានគ្នាស្តីពីពាណិជ្ជកម្ម និងសេដ្ឋកិច្ចដែលមានការចូលរួមពីសហគ្រាសធំៗចំនួន ២៨២ ដើម្បីព្យាករណ៍ និងផ្លាស់ប្តូរយោបល់គ្នាក្នុងការស្វែងរកដំណោះស្រាយនានា ក្នុងការការពារថ្លៃកុំឲ្យបន្តកើនឡើង។ ម្យ៉ាងវិញទៀត សូម្បីតែខាងក្រសួងពាណិជ្ជកម្មនៅក្នុងប្រទេសថៃក៏បានធ្វើការអំពាវនាវឲ្យខាងសហគ្រាសទាំងអស់ ចូលរួមក្នុងការពន្យារការឡើងថ្លៃទំនិញរហូតដល់ចុងឆ្នាំ២០១០។ បន្ទាប់ពីគេបានសង្កេតឃើញថា សន្ទុះក្នុងការកើនឡើងថ្លៃទំនិញនៅតែអាចបន្តទៅមុខ ខាងរដ្ឋាភិបាលបានធ្វើការស្នើរសុំបន្តឲ្យខាងសហគ្រាសទាំងអស់ ចូលរួមក្នុងការពន្យារការឡើងថ្លៃទំនិញរហូតដល់ខែមិនា ឆ្នាំ២០១១។

លើសពីនេះទៅទៀត ដោយសង្កេតឃើញថា តម្រូវការសរុបនៅតែបន្តកើនឡើងបានធ្វើទាញឲ្យអតិផរណាកើនឡើងបន្តដែរ ដោយសារតែការរីកលូតលាស់នៃសេដ្ឋកិច្ចធ្វើឲ្យប្រជាជនមានលទ្ធភាពច្រើន និងប្រាក់ចំនូលជាងមុន ដូច្នេះខាងគណៈកម្មធិការគោលនយោបាយរូបិយវត្ថុខាងធនាគារជាតិរបស់ប្រទេសថៃ បានសម្រេចចិត្តក្នុងការតម្លើងអត្រាការប្រាក់ ០.២៥ ភាគរយ ពី ២.៥០ ភាគរយ ទៅ២.៧៥ ភាគរយសម្រាប់ត្រីមាសទីបី ក្នុងឆ្នាំ ២០១១ និង បន្តរតម្លើងអត្រាការប្រាក់ ០.២៥ ភាគរយ ពី ២.៧៥ ភាគរយ ទៅ ៣.០០ ភាគរយសម្រាប់ត្រីមាសទីបួន ក្នុងឆ្នាំ ២០១១។ គេរឹតបន្តឹងអត្រាការប្រាក់នេះ គឺដើម្បីកាត់បន្ថយតម្រូវការសរុបឲ្យមានការថយចុះ កុំឲ្យវាក្លាយជាសម្ពាធនាំឲ្យថ្លៃមានការកើនឡើង។

## ២.២. ស្ថានភាពអតិផរណានៃប្រទេសសឹង្ហបុរី

### ២.២.១. ស្ថានភាពទូទៅនៃប្រទេសសឹង្ហបុរី

ប្រទេសសឹង្ហបុរី គឺជាប្រទេសដ៏ស៊ីវិល័យមួយ នៅក្នុងចំណោមប្រទេសផ្សេងៗដែលជាសមាជិកអាស៊ាន។ ប្រទេសនេះជាប្រទេសដ៏តូចមួយដែលមានផ្ទៃដី ៦៤៧.៥ ម៉ែត្រការ៉េស្ថិតនៅក្នុងទ្វីបអាស៊ីអាគ្នេយ៍។ ម៉្យាងវិញទៀត ប្រទេសតូចនេះមានជនជាតិជាច្រើនដែលកំពុងរស់នៅដូចជា ម៉ាឡេស៊ី ចិន អារ៉ាប់ ឥណ្ឌា -ល-។ វាក៏ជាប្រទេសមហាសេដ្ឋកិច្ចនៅក្នុងអាស៊ីមួយ ដែលចាប់ផ្តើមរីកលូតលាស់ចាប់តាំងពីឆ្នាំ ១៩៦០ ហើយគេចាត់ទុកប្រទេសតូចមួយនេះជាប្រទេសដែលខឿនសេដ្ឋកិច្ចរឹងមាំ មានស្ថេភាពនយោបាយរឹងមាំ និង សន្តិសុខល្អ។ សឹង្ហបុរី គឺជាចំណតផែដ៏ធំជាងគេនៅអាស៊ីអាគ្នេយ៍នេះ ដែលជាហេតុនាំឲ្យប្រទេសមួយនេះអាចទទួលប្រាក់ចំណូលបានយ៉ាងខ្ពស់ និង មានភាពរឹងមាំនៅក្នុងសេដ្ឋកិច្ច។ ដូច្នេះហើយទើបគេសង្កេតឃើញថា ជីវភាពប្រជាជនគេមានភាពល្អប្រសើរ និង រស់នៅជាលក្ខណៈស្តង់ដារ។ ជាការពិតណាស់ដើម្បីឲ្យប្រទេសរីក

ចម្រើនបាន គឺទាមទារឲ្យមានការចូលរួមពីរាជរដ្ឋាភិបាល។ ក្នុងនោះរដ្ឋាភិបាលសឹង្ហបុរីក៏មិនដែលភ្លេចពីការថែរក្សាគ្រប់គ្រងលើជីវភាពពលរដ្ឋរបស់ខ្លួនដែរ គឺគេសិក្សាលើគ្រប់វិស័យ ការវិវត្តន៍នៃសេដ្ឋកិច្ច និង បញ្ហាអតិផរណាផងដែរ។ ការកើនឡើងអត្រាអតិផរណា ពិតជាជះឥទ្ធិពលលើជីវភាពប្រជាពលរដ្ឋ និងដំណើរការនៅក្នុងសេដ្ឋកិច្ចទាំងមូលតាមរយៈការស្រាវជ្រាវលើរបាយការណ៍សេដ្ឋកិច្ចសឹង្ហបុរីចាប់តាំងពីឆ្នាំ ២០១០ ដល់ ២០១៦ យើងសង្កេតឃើញថាក្នុងឆ្នាំ ២០១១ អត្រាអតិផរណា បានកើនឡើងខ្ពស់ខុសពីធម្មតា ដែលមានអត្រាជាមធ្យម ៥.២ភាគរយ លើសឆ្នាំណាណាទាំងអស់រហូតដល់បច្ចុប្បន្ននេះ។ ការកើនឡើងនៃអត្រាអតិផរណានេះ គឺព្រោះតែទទួលរងនូវឥទ្ធិពលខាងក្រៅ និង ខាងក្នុងប្រទេស។ នៅក្នុងឆ្នាំ ២០១៦ នេះបង្ហាញឃើញថា អត្រាអតិផរណារបស់ប្រទេស សឹង្ហបុរីស្ថិតនៅក្នុងកម្រិតអវិជ្ជមាន គឺ -០.៥ភាគរយ ដែលបង្ហាញថាទំនិញនិងសេវាកម្មមានការថយចុះ។ ដូច្នេះដើម្បីរក្សាស្ថេរភាពថ្លៃទំនិញ និងសេវាកម្ម និងរក្សាលំនឹងសេដ្ឋកិច្ច គឺខាងរដ្ឋាភិបាលសិង្ហបុរី (MAS. Monetary Authority of Singapore) តែងតែធ្វើរបាយការណ៍អតិផរណាប្រចាំខែ និង ធ្វើការព្យាករណ៍អត្រាអតិផរណានាពេលខាងមុខទុកមុន។

### ២.២.២. អត្រាអតិផរណាប្រចាំខែ និង ប្រចាំឆ្នាំ

តារាងទី ២.២ អតិផរណាប្រចាំខែ និង ប្រចាំឆ្នាំ

| រយៈពេល | អត្រាអតិផរណាគិតជាភាគរយ | | | | | | |
|---|---|---|---|---|---|---|---|
| | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| មករា | ០.២ | ៥.៥ | ៤.៨ | ៣.៦ | ១.៤ | -០.៤ | -០.៦ |
| កុម្ភៈ | ១.០ | ៥.០ | ៤.៦ | ៤.៩ | ០.៤ | -០.៣ | -០.៨ |
| មិនា | ១.៦ | ៥.០ | ៥.២ | ៣.៥ | ១.២ | -០.៣ | -១.០ |
| មេសា | ៣.២ | ៤.៥ | ៥.៤ | ១.៥ | ២.៥ | -០.៥ | -០.៥ |
| ឧសភា | ៣.២ | ៤.៥ | ៥.០ | ១.៦ | ២.៧ | -០.៤ | -១.៦ |
| មិថុនា | ២.៧ | ៥.២ | ៥.៣ | ១.៨ | ១.៨ | -០.៣ | -០.៧ |
| កក្កដា | ៣.១ | ៥.៤ | ៤.០ | ១.៩ | ១.២ | -០.៤ | -០.៧ |
| សីហា | ៣.៣ | ៥.៧ | ៣.៩ | ២.០ | ០.៩ | -០.៨ | -០.៣ |
| កញ្ញា | ៣.៧ | ៥.៥ | ៤.៧ | ១.៦ | ០.៦ | -០.៦ | -០.២ |
| តុលា | ៣.៥ | ៥.៤ | ៤.០ | ២.០ | ០.១ | -០.៨ | -០.២ |
| វិច្ឆកា | ៣.៨ | ៥.៧ | ៣.៦ | ២.៦ | -០.៣ | -០.៨ | -០.២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ធ្នូ | ៤.៦ | ៥.៥ | ៤.៣ | ១.៥ | -០.២ | -០.៦ | -០.២ |
| ភាគរយជាមធ្យម | ២.៨ | ៥.២ | ៤.៦ | ២.៤ | ១.០ | -០.៥ | -០.៥ |

(ប្រភព: ដកស្រង់របាយការណ៍អតិផរណារបស់ធនាគារជាតិប្រទេសសឹង្ហបុរីចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៦)

តាមរយៈតារាងអតិផរណាប្រចាំខែនិងប្រចាំឆ្នាំខាងលើបានបង្ហាញថា អតិផរណាចាប់ផ្តើមរំកិលឡើងចាប់តាំងពីខែមេសា ឆ្នាំ២០១០ រហូតដល់ ៣.២ភាគរយ ហើយចាប់ផ្តើមបន្តកើនឡើងរហូតដល់ឆ្នាំ ២០១១ ដែលអត្រាអតិផរណាជាមធ្យមនៅក្នុងឆ្នាំនោះរហូតដល់ ៥.២ភាគរយ ដែលជាអត្រាអតិបរមាចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៦។ បន្ទាប់មកចាប់ពីឆ្នាំ ២០១២ មកអត្រានៃអតិផរណាបានបន្តថយចុះបន្តិចម្តងៗ ពីមួយឆ្នាំមកមួយឆ្នាំ រហូតដល់កម្រិតអវិជ្ជមាន -០.៥ភាគរយនៅក្នុងឆ្នាំ ២០១៦ ថ្មីៗនេះ។

### ២.២.៣ មូលហេតុដែលបណ្តាលឲ្យមានអតិផរណា

តាមរយៈការសិក្សាទៅលើអតិផរណារបស់ប្រទេសសឹង្ហបុរី ចាប់តាំងពីឆ្នាំ ២០១០ រហូតដល់ឆ្នាំ ២០១៦ យើងសង្កេតឃើញថា អត្រាអតិផរណាក្នុងឆ្នាំ ២០១១ គឺមានអត្រាខ្ពស់ជាងគេក្នុងចំណោមឆ្នាំទាំងអស់ ដែលបណ្តាលមកពីកត្តាជាច្រើនក្នុងការជម្រុញឲ្យអតិផរណាកើនឡើងបន្តគ្នាចាប់តាំងពីដើមឆ្នាំ ២០១០។

ជាការពិតណាស់ ដើម្បីសិក្សាស្រាវជ្រាវក្នុងការស្វែងរកមូលហេតុដែលនាំឲ្យមានអតិផរណាក្នុងប្រទេសខ្លួន រដ្ឋាភិបាលសឹង្ហបុរី បានធ្វើរបាយការណ៍ស្តីពីអតិផរណាប្រចាំខែជារៀងរាល់ឆ្នាំនិង របាយការណ៍ម៉ាក្រូសេដ្ឋកិច្ចប្រចាំឆមាសជារៀងរាល់ឆ្នាំ។ របាយការណ៍អតិផរណារបស់ប្រទេសសឹង្ហបុរីបានរៀបរាប់អត្រាអតិផរណាប្រចាំខែ ដោយផ្អែកទៅលើសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់។ សន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ គឺជារង្វាស់មួយដ៏ល្អក្នុងការវាស់វែងថ្លៃទំនិញ និងសេវាកម្មប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់។ វាបង្ហាញពីការប្រែប្រួលថ្លៃទំនិញ និងសេវាកម្មនៅក្នុងកន្ត្រកទំនិញ ដែលទិញដោយអ្នកប្រើប្រាស់។ នៅក្នុងថ្លៃកន្ត្រកទំនិញបានរាប់បញ្ចូលថ្លៃស្នាក់នៅ ដឹកជញ្ជូន ម្ហូបអាហារ សេវាកម្ម ទំនិញពាក់ព័ន្ធនឹងប្រេង និងទំនិញផ្សេងៗទៀត និងជាគន្លឹះក្នុងការស្វែងរកមូលហេតុដែលនាំឲ្យមានអតិផរណា។

#### ២.២.៣.១. ថ្លៃមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន

ថ្លៃមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមិនរាប់បញ្ចូលថ្លៃប្រេងឥន្ទនៈបានកើនឡើងជិតដល់ ៩.០

ភាគរយនៅក្នុងត្រីមាសទីពីរក្នុងឆ្នាំ ២០១០ រហូតដល់ចុងឆ្នាំ ២០១១ ការកើនឡើងថ្លៃនៃ COE[7] (Certificate of Entitlement) ដើម្បីរឹតបន្តឹងការកើនឡើងនៃការប្រើប្រាស់យានយន្ត។ នៅពេលដែលមានការកើនឡើងនូវការប្រើប្រាស់យាន្តយន្ត ប្រាកដណាស់គឺតម្រូវឲ្យមានការសាងសង់ផ្លូវច្រើនជាងមុន ឬ ការពង្រីកផ្លូវដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍។ ដោយឡែកសម្រាប់ប្រទេសសឹង្ហបុរីជាប្រទេសដ៏តូចមួយពិតជាពិបាកណាស់ក្នុងការសាងសង់ផ្លូវបន្ថែមច្រើនទៀត។ មកដល់បច្ចុប្បន្ននេះ ផ្ទៃដីប្រហែល ១២ភាគរយត្រូវបានប្រើប្រាស់ជាផ្លូវធ្វើដំណើរ និង ១៤ភាគរយសម្រាប់ផ្ទះសម្បែង។ ដូច្នេះហើយទើបខាងរដ្ឋាភិបាលសឹង្ហបុរីបានជ្រើសរើសយក COE ជាវិធីសាស្ត្រក្នុងការគ្រប់គ្រងការកើនឡើងនៃយាន្តយន្តឲ្យនៅក្នុងកម្រិតសមស្របមួយ ដូចទៅនឹងគម្រោងអភិវឌ្ឍន៍លើការធ្វើដំណើរ និង ប្រព័ន្ធគ្រប់គ្រងចរាចរណ៍។ មូលហេតុនេះហើយដែលធ្វើឲ្យ COE ឡើងថ្លៃ នៅពេលដែលតម្រូវការក្នុងការប្រើប្រាស់យានយន្តកើនឡើង បានធ្វើឲ្យថ្លៃមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនកើនឡើង ជាហេតុនាំឲ្យអតិផរណាក្នុងប្រទេសកើនឡើងតាមនោះដែរ។

**២.២.៣.២.. ការកើនឡើងថ្លៃឈ្នួលផ្ទះ**

នៅក្នុងឆ្នាំ ២០១០ គេបានប្រមើលឃើញថា ថ្លៃឈ្នួលផ្ទះនឹងមានការកើនឡើង ដោយសារតែខ្វះខាតនូវផ្ទះជួល។ បើក្រឡេកមើលទីផ្សារផ្ទះជួល ឃើញថាអត្រាផ្ទះជួលដែលនៅទំនេរមានអត្រា ៥.២ ភាគរយ នៅក្នុងត្រីមាសទី៣ ឆ្នាំ ២០១០ បង្ហាញថាវាមានកម្រិតទាបបើប្រៀបធៀបទៅនឹងអត្រាជាមធ្យម ក្នុងរយៈពេល ១០ ឆ្នាំមុនមាន ៧.២ភាគរយ ទោះបីជាមានការកើនឡើងនៃការសាងសង់ផ្ទះជួលក៏ដោយ។ ស្របពេលជាមួយគ្នានេះដែរ កំណើនតម្រូវការជួលផ្ទះនៅតែបន្តកើនឡើង ព្រោះតែលំហូរចំនួនពលករក្រៅស្រុកកើនឡើង។ ការកើនឡើងថ្លៃឈ្នួលផ្ទះបានបន្តកើនឡើងរហូតដល់ដើមឆ្នាំ ២០១២។ ម៉្យាងវិញទៀត នៅពាក់កណ្តាលឆ្នាំ ២០១១ កិច្ចសន្យាជួលផ្ទះជាច្រើនបានដល់កាលកំនត់ដែលត្រូវធ្វើថ្មី ដូច្នេះម្ចាស់ផ្ទះបាន តម្លើងថ្លៃឈ្នួលនៅក្នុងកិច្ចសន្យាជួលផ្ទះថ្មីជាមូលហេតុនាំឲ្យថ្លៃផ្ទះកើនឡើងដែលជម្រុញឲ្យមានកំណើនអត្រាអតិផរណា។

**២.២.៣.៣.. ថ្លៃពលកម្ម**

ចាប់តាំងពីឆ្នាំ ២០១០ មក ទីផ្សារពលកម្មក្នុងប្រទេសសឹង្ហបុរីមានសភាពតូចចង្អៀត ដែលនាំឲ្យប្រាក់ឈ្នួលពលកម្មមានការកើនឡើង។ បើតាមរបាយការណ៍ទីផ្សារពលកម្មនៅក្នុងឆ្នាំ ២០១១ បានបង្ហាញ ភាពមានការងារធ្វើបានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ ២០១១ គឺលើសបីដងនៃ

[7] COE(Certificate of Entitlement) គឺជាលិខិតអនុញ្ញាតិសម្រាប់អ្នកចង់ទិញយាន្តយន្តប្រើប្រាស់គឺត្រូវធ្វើការស្នើរ ដើម្បីកាន់កាប់យាន្តយន្តផ្ទាល់ខ្លួន និង ធ្វើការប្រើប្រាស់រយៈពេល 10 ឆ្នាំ។

ឆ្នាំ ២០០៩។ ដោយសារតែសេដ្ឋកិច្ចពិភពលោករីកចម្រើន ធ្វើឲ្យវិស័យជាច្រើនបន្តកើនឡើងជាពិសេសវិស័យផលិតកម្ម និង សេវាកម្ម។

តម្រូវការលើគ្រឿងអេឡិចត្រូនិច មានការកើនឡើងបានធ្វើឲ្យកំណើនភាពមានការងារធ្វើនៅក្នុងប្រទេសសឹង្ហបុរីក្នុងរយៈពេលបីឆ្នាំនោះ។ ម្យ៉ាងវិញទៀតកំឡុងពេលសេដ្ឋកិច្ចរីកចម្រើន វិស័យទេសចរណ៍ក្នុងប្រទេសសឹង្ហបុរីក៏ចាប់ផ្ដើមរីកលូតលាស់ ដែលនាំឲ្យមានតម្រូវការបុគ្គលិកខាងបដិសណ្ឋារកិច្ចមានការកើនឡើង។ នៅក្នុងឆ្នាំ ២០១០ នេះផងដែរ ទីផ្សារការងារមានការកើនឡើងខ្លាំងមែនទែន ដែលលើកទឹកចិត្តឲ្យប្រជាជននៅក្នុងសឹង្ហបុរី ចូលបម្រើការងារជាច្រើន។ ជាលទ្ធផលអត្រាពលកម្មនៃប្រជាជនក្នុងស្រុក (LFPR-Labor Force Participation Rate) មានការកើនឡើងរហូតដល់ ៦៦.២ភាគរយ ក្នុងឆ្នាំ ២០១០ ជាអត្រាខ្ពស់បំផុតក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ តាមរយៈការកើនឡើងនូវតម្រូវការពលកម្មបានធ្វើឲ្យថ្លៃពលកម្មកើនឡើងបន្តិចម្ដងៗ ចាប់ពី ២០១០ ដល់ ២០១១ ស្ទើរតែគ្រប់វិស័យ។ ថ្វីត្បិតតែ LFPR នៅតែបន្តកើនឡើង តែលំហូរពលករក្រៅស្រុកមានការធ្លាក់ចុះជាងមុន ដោយសាររាជរដ្ឋាភិបាលបានរឹតបន្តឹងជាងមុនលើច្បាប់អន្តោប្រវេសន៍ និង ពលករក្រៅស្រុកដែលមានសមត្ថភាពទាបដែលជាហេតុនាំឲ្យមានកង្វះពលកម្ម។

### ២.២.៤ បញ្ហាប្រឈម

ជុំវិញបញ្ហាអតិផរណានៅក្នុងប្រទេសសឹង្ហបុរី គឺទទួលរងឥទ្ធិពលពីខាងក្រៅ ដែលជាហេតុនាំឲ្យអតិផរណាមានការកើនឡើង ហើយបញ្ហាប្រឈមទាំងនោះរួមមាន៖

- ការកើនឡើងថ្លៃប្រេងក្នុងទីផ្សារសកល៖ ថ្លៃប្រេងគឺមានការប្រែប្រួលឥតឈប់ឈរ ចាប់តាំងពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១២ ។ បើយោងទៅតាមតម្លៃប្រេង The West Texas Intermediate បានកើនឡើងរហូតដល់ ១១០ដុល្លា អាមេរិកក្នុងមួយបារ៉ែល នៅក្នុងខែមេសា ឆ្នាំ ២០១១ ដែលជាតួលេខខ្ពស់បំផុតចាប់តាំងពីខែសីហា ឆ្នាំ ២០០៨។ ថ្លៃប្រេងបានបន្តកើនឡើងខ្ពស់បែបនេះ បណ្ដាលមកពីជម្លោះនយោបាយក្នុងប្រទេសផលិតប្រេង។ ការបន្តភាពតានតឹងផ្នែកនយោបាយក្នុងប្រទេសផលិតប្រេងទាំងនោះ ជាពិសេសសង្គ្រាមស៊ីវិលនៅ លីប៊ី បានធ្វើឲ្យថ្លៃប្រេងពិភពលោកបន្តកើនឡើងថ្លៃដូចគ្នា។ ម្យ៉ាងវិញទៀត កំណើនប្រើប្រាស់ប្រេងពិភពលោកបានបន្តកើនឡើង ហើយប្រទេសជប៉ុន បានបង្កើនការនាំចេញប្រេងជំនួសការខូចខាត នូវកម្លាំងថាមពលនុយក្លេអែដែលបង្កដោយគ្រោះធម្មជាតិរលកយក្ស ស៊ូណាមីកាលពីថ្ងៃទី ១១ មិនា ឆ្នាំ ២០១១។ បើយោងទៅតាម

ភ្នាក់ងារថាមពលអន្តរជាតិ (The International Energy Agency ) បានបង្ហាញថា ប្រសិនបើប្រទេសជប៉ុន នឹងនាំចូលប្រេងបន្ថែម ៣៧៥,០០០ បារ៉ែលក្នុងមួយថ្ងៃ ដែលមានចំនួន ០.៥ ភាគរយនៃតម្រូវការប្រេងសរុបនៃសកលោក។ ការកើនឡើងថ្លៃប្រេងនេះ បានប៉ះពាល់ដល់រាល់ប្រភេទទំនិញ ដែលពាក់ព័ន្ធនឹងប្រេងនៅប្រទេសសឹង្ហបុរីកើនឡើងផងដែរ។ បើតាម របាយការណ៍របស់ប្រទេសសឹង្ហបុរី នៅចុងឆ្នាំ ២០១១បានបង្ហាញថា តម្លៃអគ្គិសនីក្នុងត្រីមាសទីបីក្នុងឆ្នាំ ២០១១ បានកើនឡើងដល់ ៦.៦ ភាគរយ ហើយរាល់ទំនិញពាក់ព័ន្ធនឹងប្រេងក៏បានកើនឡើងដល់០.៦ ភាគរយ ដែលជាហេតុនាំឲ្យអតិផរណាក្នុងប្រទេសសឹង្ហបុរីមានការកើនឡើងផងដែរ។

- ការកើនឡើងថ្លៃម្ហូប-អាហារពិភពលោក៖ ចាប់ពីឆ្នាំ ២០១០ មក ថ្លៃម្ហូបអាហារក្នុងស្រុករបស់ប្រទេស សឹង្ហបុរី បានកើនឡើងបន្តបន្ទាប់ក្នុងរយៈពេល ៩ ខែចុងក្រោយបន្ទាប់ពីថ្លៃមានលំនឹងក្នុងឆ្នាំ ២០០៩។ ការកើនឡើងថ្លៃម្ហូបអាហារពិភពលោក គឺបណ្តាលមកពីបញ្ហាអាកាសធាតុក្នុងប្រទេសជាច្រើន ដែលជះឥទ្ធិពលដល់ការប្រមូលទិន្នផលកសិផល។ វាត្រូវបានធ្វើឲ្យមានកង្វះខាតផ្គត់ផ្គង់ម្ហូបអាហារលើពិភពលោក។ស្របគ្នានេះដែរនៅពេលដែលការផ្គត់ផ្គង់ធ្លាក់ចុះ នោះតម្លៃនឹងកើនឡើងដែលជាហេតុនាំឲ្យអតិផរណាកើនឡើង។

### ២.២.៥ ដំណោះស្រាយរបស់រដ្ឋាភិបាលសឹង្ហបុរីលើបញ្ហាអតិផរណា

រដ្ឋាភិបាល ពិតជាមានតួនាទីសំខាន់ណាស់ក្នុងដំណើរសេដ្ឋកិច្ចក្នុងប្រទេស។ រដ្ឋាភិបាលសឹង្ហបុរី តែងតែយកចិត្តទុកដាក់គ្រប់ពេលវេលាក្នុងការត្រួតពិនិត្យរាល់ដំណើរការប្រែប្រួលនៅក្នុងសេដ្ឋកិច្ច វិបត្តិសេដ្ឋកិច្ច និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។ បញ្ហាអតិផរណា ជាបញ្ហាសំខាន់ដែលមានឥទ្ធិពលដល់ដំណើរការសេដ្ឋកិច្ចទាំងមូល និងជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសរបស់ខ្លួន។ ដូចនេះរដ្ឋាភិបាលសឹង្ហបុរី មិនដែលធ្វេសប្រហែសលើបញ្ហានេះឡើយ គឺពួកគេតែងតែតាមដានស្វែងរកឫសគល់នៃបញ្ហា និងចាត់វិធានការណ៍ដោះស្រាយភ្លាមៗ ដើម្បីទប់ទល់ទៅនឹងបញ្ហាអតិផរណាក្នុងប្រទេសរបស់ខ្លួនឲ្យបានទាន់ពេលវេលាដើម្បីអតិផរណាក្នុង ប្រទសមានស្ថិរភាព រាជរដ្ឋាភិបាលសឹង្ហបុរីត្រូវតែសង្កេតឲ្យបានជិតដល់ទៅលើការវិវត្តនៃ ថ្លៃទំនិញប្រើប្រាស់ទាំងផ្នែកទំនិញនាំចូល និងទំនិញក្នុងស្រុក ព្រមទាំងចាត់វិធានការក្នុងការដោះស្រាយបញ្ហានៃអតិផរណាឲ្យធូរស្រាលជាងមុន។

### ២.២.៥.១.. ដំណោះស្រាយអតិផរណាលើទំនិញនាំចូលៈ

១.ក្រុមទេសាភិបាលសឹង្ហបុរី (The Monetary Authority of Singapore MAS) គឺសម្រេចឲ្យរូបិយវត្ថុដុល្លារសឹង្ហបុរីកើនឡើង ដើម្បីសម្រួលឲ្យតម្លៃទំនិញ និងប្រេងពិភពលោកនាំចូលធ្លាក់ចុះ។

២. ដើម្បីឲ្យថ្លៃម្ហូបអាហារមានតម្លៃសមរម្យ, The National Environment Agency ( NEA) គឺបានប្រើប្រាស់ម៉ូដែលគ្រប់គ្រងមួយដែលអាចរក្សាលំនឹងថ្លៃ។

ឧទាហរណ៍៖ NTVC Foodfare[8] បានបង្កើតគម្រោងបង្កើតផ្សារ Bukit Panjang Hawker Center ដែលជាមិនយកប្រាក់ចំណេញជាគោល។

៣. លើកពីនេះទៅទៀត Retail Price Watch Group (RPWG) ដែលដឹកនាំដោយលោក លី អ៊ី( Lee Yi ) ដែលជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងអភិវឌ្ឍន៍ក្នុងស្រុក។ លោកតែងតែអង្កេតមើលលើការវិវត្តរបស់ថ្លៃម្ហូបអាហារ និងទំនិញប្រើប្រាស់ប្រចាំថ្ងៃយ៉ាងយកចិត្តទុកដាក់។ RPWG បានសហការណ៍ ជាមួយផ្សារទំនើប អ្នកលក់បោះដុំ អ្នកលក់រាយនានាក្នុងការចូលរួមរក្សាថ្លៃទំនិញឲ្យបានថេរ។ សមាជិករបស់ RPWG មានដូចជា NTVC Fair Price, Giant និង Sheng Siong ក៏បានចូលរួមរក្សារតម្លៃ ទំនិញផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងតម្លៃទាបដំដែល ដើម្បីជួយសម្រាលដល់ការឡើងថ្លៃទំនិញដល់អ្នកប្រើប្រាស់។

### ២.២.៥.២. ដំណោះស្រាយលើអតិផរណានៃទំនិញក្នុងស្រុក

ដើម្បីគ្រប់គ្រងរាល់ផលប៉ះពាល់នៃកង្វះខាតទីផ្សារពលកម្មក្នុងស្រុកមកលើខឿនសេដ្ឋកិច្ច រដ្ឋាភិបាលសឹង្ហបុរី បានធ្វើការជាមួយអង្គភាព និងក្រុមហ៊ុន ជាច្រើនក្នុងការបង្កើននូវផលិតភាពការងារ ទទួលបានការកើនឡើង គឺត្រូវការការចូលរួមរបស់ខាងអង្គភាព និងក្រុមហ៊ុនក្នុងការលើកទឹកចិត្តបុគ្គលិកពួកគេអភិវឌ្ឍន៍ជំនាញ ក្នុងការងាររបស់ពួកគេឲ្យប្រសើរជាងមុន។ ខាងរដ្ឋាភិបាលសឹង្ហបុរីបានបង្កើតគម្រោង Productivity and Innovation Credit ( PIC ) Scheme ដោយចាប់ដំណើរការចាប់ពីឆ្នាំ២០១០ ដល់ ២០១៦ ក្នុងគោលបំណងលើកទឹកចិត្តឲ្យសហគ្រិនមានការវិនិយោគបន្ថែមក្នុងសកម្មភាពផលិតកម្ម ដោយផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ដូចជាកាត់ពន្ធលើការទិញគ្រឿងប្រើប្រាស់អេឡិចត្រូនិច ការបង្វឹកបុគ្គលិក ការចុះឈ្មោះលើកម្មសិទ្ធបញ្ញា គម្រោង

[8] NTVC Foodfare គឺត្រូវបានបង្កើតជាអាជីវកម្មមួយខុសប្លែកពីគេដោយ Labour Movement ក្នុងឆ្នាំ ១៩៩៥ ក្នុងគោលបំណងជួយដល់ជីវភាពប្រជាជនតាមរយៈ រក្សាលំនឹងថ្លៃម្ហូបអាហារប្រចាំថ្ងៃរបស់ពួកគេ។

ឱីហ្សាញនានា និងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ។ ក្នុងគម្រោងមួយនេះឃើញថា វាបានជម្រុញឲ្យខាងសហគ្រិនចូលរួមអភិវឌ្ឍន៍សមត្ថភាព របស់បុគ្គលិកពួកគេឲប្រសើរឡើងជាងមុន។ ដូច្នេះនៅពេលដែលផលិតភាពការងាររបស់ពួកគេកើនឡើង ខាងក្រុមហ៊ុនសហគ្រាសអស់ទាំងនោះ ក៏អាចតម្លើងប្រាក់ឈ្នួលបុគ្គលិករបស់ខ្លួន ដូចនេះពួកគេ មិនចាំបាច់ផ្ទេរថ្លៃចំណាយខ្ពស់ទៅកាន់អតិថិជនប្រើប្រាស់នោះទេ។

# ជំពូកទី៣
# ស្ថានភាពអតិផរណានៃ
# ប្រទេសកម្ពុជា

# ជំពូកទី ៣៖ ស្ថានភាពអតិផរណានៃប្រទេសកម្ពុជា

## ៣.១ ស្ថានភាពទូទៅនៃប្រទេសកម្ពុជា

បន្ទាប់ពីកំណើនសេដ្ឋកិច្ចមានភាពរឹងមាំអស់រយៈពេលជាងពីទសវត្សរ៍កន្លងមក កម្ពុជាបានទទួលចំណាត់ថ្នាក់ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបគិតត្រឹមឆ្នាំ ២០១៥ ដែលមានចំណូលជាតិសរុបក្នុងមនុស្សម្នាក់ កើនឡើងដល់ ១០៧០ ដុល្លាអាមេរិក។ ការកើនឡើងសេដ្ឋកិច្ចនេះ គឺទទួលបានការគាំទ្រពីកំណើនដ៏រឹងមាំនៃការនាំចេញផលិតផលសម្លៀក បំពាក់និងស្បែកជើង កំណើនវិស័យសំណង់ និងអចលនទ្រព្យ ព្រមទាំងវិស័យទេសចរណ៍ បានរក្សានូវអត្រាកំណើនជាមធ្យមប្រមាណ ៧ភាគរយ ចន្លោះឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១៥។

ទន្ទឹមនឹងនេះដែរ សក្តានុពលសេដ្ឋកិច្ចប្រទេសកម្ពុជាជ ដែលទាក់ទាញលំហូរចូលវិនិយោគផ្ទាល់ពីបរទេស (១០.៧ភាគរយ នៃផ.ស.ស) គួបផ្សំនឹងភាពប្រសើរឡើងនៃឱនភាពនៃជញ្ជីងពាណិជ្ជកម្ម (-៧.៧ភាគរយ នៃ ផ.ស.ស) បានធ្វើឲ្យជញ្ជីងទូទាត់កម្ពុជាទទួលបានអតិរេក ( ៥.៧ភាគរយ នៃ ផ.ស.ស) ខ្ពស់ជាងឆ្នាំ ២០១៥ ( ៣.៧ភាគរយ នៃ ផ.ស.ស) ដែលចូលរួមចំណែកគរពូនទុនបម្រុងអន្តរជាតិកើនឡើង និងអាចធានាដល់ការទូទាត់ការនាំចូលទំនិញ និងសេវាបានប្រមាណ ៥ខែ។ ចំពោះស្ថានភាពថ្លៃ អត្រាអតិផរណាបានបន្តស្ថិតក្នុងកម្រិតទាបប្រមាណ ២.៩ភាគរយ ។ មូលហេតុចម្បងដែលនាំឲ្យមានអតិផរណា គឺកំណើនម្ហូបអាហារភោជនីយដ្ឋាន និង សម្លៀកបំពាក់ ដែលគាំទ្រកំណើនតម្រូវការក្នុងស្ថានភាពដែលជីវភាពប្រជាជន មានភាពប្រសើរឡើង។ គួរឲ្យកត់សម្គាល់ផងដែរថា ការសម្រេចបានកម្រិតទាបនៃអតិផរណារយៈពេលកម្លងមក បានពឹងផ្អែកមួយផ្នែកលើតម្លៃប្រេងទាបរួមនឹងការអនុវត្តគោលនយោបាយសារពើពន្ធ រូបិយវត្ថុ និង អត្រាប្តូរប្រាក់សមស្របនៅនឹងកំណើនសកម្មភាពសេដ្ឋកិច្ច។

## ៣.២. អត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ

**តារាង ៣.១ ៖ តារាងអត្រាអតិផរណាប្រចាំឆ្នាំជាភាគរយឆ្នាំលើឆ្នាំ**

| បម្រែបម្រួលភាគរយឆ្នាំលើឆ្នាំ | | | | | | | |
|---|---|---|---|---|---|---|---|
| គិតជាភាគរយ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| មករា | ៦.៩២ | ៣.៣១ | ៥.៧៧ | ១.៨៣ | ៤.៥៥ | ០.៤១ | ៣.០៥ |
| កុម្ភៈ | ៧.៣១ | ៣.៧៩ | ៥.៤២ | ១.៧៣ | ៤.៣០ | ១.៥៧ | ២.៣១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| មិនា | ៦.៦៥ | ៣.៨ | ៥.៣៥ | ០.៩៨ | ៤.៩៨ | ១.១២ | ២.៦៣ |
| មេសា | ៥.៣០ | ៥.២៤ | ៤.៧៨ | ១.០២ | ៤.៩៤ | ១.២៧ | ២.៨០ |
| ឧសភា | ៤.៤៦ | ៦.៤៩ | ២.១៩ | ២.៨២ | ៤.៥៥ | ១.០២ | ៣.០៩ |
| មិថុនា | ២.៥៨ | ៧.០៦ | ១.៨៣ | ២.៩២ | ៤.៨៥ | ០.៧០ | ៣.២៥ |
| កក្កដា | ១.៦២ | ៧.១០ | ១.២៨ | ៣.៩៦ | ៤.២៦ | ០.៨០ | ៣.០៤ |
| សីហា | ១.៧៥ | ៦.៣៧ | ២.១៨ | ៣.៣០ | ៤.១១ | ០.៨០ | ២.៩៣ |
| កញ្ញា | ១.៩៣ | ៦.៦៨ | ១.៤៤ | ៣.៧៤ | ៣.៥៨ | ០.៩៤ | ២.៨៩ |
| តុលា | ៣.៦៩ | ៥.២៥ | ១.២០ | ៤.១៨ | ២.៩០ | ១.២៨ | ៣.៣៥ |
| វិច្ឆកា | ៣.២១ | ៥.៦៧ | ១.៦២ | ៤.១២ | ២.៣៦ | ១.៩២ | ៣.៦១ |
| ធ្នូ | ៣.១៤ | ៤.៩១ | ២.៥៤ | ៤.៦៧ | ១.១៥ | ២.៥៨ | ៣.៨៩ |
| **មធ្យមភាគ** | **៤.០** | **៥.៥** | **៣.០** | **៣.០** | **៣.៩** | **១.២** | **៣.១** |

តាមការសង្កេតមើលលើអត្រាអតិផរណាឆ្នាំលើឆ្នាំជាមធ្យមប្រចាំឆ្នាំនីមួយៗ ចាប់តាំងពីឆ្នាំ ២០១០ រហូតដល់ឆ្នាំ ២០១៦ បញ្ជាក់ឃើញថា អត្រាអតិផរណាចាប់ផ្តើមកើនឡើងបន្តិចម្តងៗ ចាប់ពីឆ្នាំ២០១០ រហូតដល់ ២០១១ ដែលជាឆ្នាំដែលមានអត្រាអតិផរណាខ្ពស់ជាងគេរហូតដល់ ៥.៥ភាគរយ។ បន្ទាប់មក អត្រាអតិផរណាឆ្នាំលើឆ្នាំជាមធ្យមក្នុងឆ្នាំ២០១២ បានថយចុះត្រឹម ៣.០ ភាគរយ និងរក្សាកម្រិតដដែលនៅឆ្នាំ ២០១៣។ ក្នុងឆ្នាំ២០១៤ អត្រាអតិផរណាបានកើនឡើងខ្ពស់ជាងមុនរហូតដល់០.៩ភាគរយ ប៉ុន្តែក្នុងកម្រិតប្រសើរជាងឆ្នាំ២០១០ និង២០១១។ ស្ថានភាពអតិផរណាក្នុងឆ្នាំ២០១៥ មានភាពល្អប្រសើរធៀបនឹងឆ្នាំ២០១៤ ដោយសារការធ្លាក់ចុះនៃថ្លៃប្រេង , អត្រាអតិផរណាទាបនៅក្នុងប្រទេសនាំទំនិញចូលមកកម្ពុជា និងការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុប្រកបដោយប្រសិទ្ធភាព។ ក្នុងឆ្នាំ២០១៦ ថ្វីត្បិតតែអត្រាអតិផរណាកើនឡើង តែកើនឡើងតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច កំណើនតម្រូវការបានជម្រុញឲ្យក្រុមថ្លៃទំនិញមួយចំនួនកើនឡើង ហើយកំណើនថ្លៃទាំងនេះបានបង្កើតឲ្យមានសម្ពាធអតិផរណាមានការកើនឡើង។

## ៣.៣. ស្ថានភាពអតិផរណាប្រចាំឆ្នាំ

### ៣.៣.១ ស្ថានភាពអតិផរណាប្រចាំឆ្នាំក្នុងឆ្នាំ ២០១០




របាយការណ៍របស់មូលនិធិរបស់រូបិយវត្ថុអន្តរជាតិ (IMF) កាលពីខែមករា ឆ្នាំ ២០១១ បានបង្ហាញថានៅក្នុងឆ្នាំ ២០១០ សេដ្ឋកិច្ចសាកលលោកកើន ៥ ភាគរយ សេដ្ឋកិច្ចប្រទេសជឿនលឿនកើន ៣ ភាគរយ និងសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍អាចនឹងមានកំណើនរហូតដល់ ៧.១ ភាគរយ។ ចំពោះកំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០១០ បានវិលត្រលប់មកប្រសើរវិញ ខណៈដែលសេដ្ឋកិច្ចមានការរីកចម្រើនជាច្រើនវិស័យ ជាពិសេស ការកើនឡើងការនាំចេញផលិតផលកាត់ដេរ និង វិស័យទេសចរណ៍។ បើពិនិត្យលើចលនាអតិផរណានៅក្នុងឆ្នាំ ២០១០ ឃើញថាបម្រែបម្រួលឆ្នាំលើឆ្នាំនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និង សេវា បានបន្តកើនជាបន្តបន្ទាប់ចាប់ពីដើមឆ្នាំគឺ ៦.៩ ភាគរយ នៅខែ មករា និង រហូតដល់ ៧.៣ ភាគរយ នៅខែកុម្ភៈ ហើយបានថយចុះមកវិញបន្តិចម្តងៗដល់កម្រិតទាបបំផុតនៃឆ្នាំស្មើរនឹង ១.៦ ភាគរយនៅក្នុងខែ កក្កដា និង មានអត្រាស្មើរនឹង ៣.១ ភាគរយនាដំណាច់ឆ្នាំ។ ដោយឡែក អត្រាអតិផរណាប្រចាំមធ្យមរំកិល ១២ខែមានកម្រិត ៤ ភាគរយនៅដំណាច់ឆ្នាំ ២០១០ ធៀបនឹង -០.៧ ភាគរយនៅគ្រាដូចគ្នា ឆ្នាំ ២០០៩ និង ២៥ ភាគរយ នៅឆ្នាំ ២០០៨។

បើក្រឡេកមើលការធ្លាក់ចុះនៃអត្រាអតិផរណានៅឆ្នាំ ២០០៩ បណ្តាលជាបឋមពីឥទ្ធិពលនៃកម្រិតថ្លៃស្បៀងអាហារ និង ប្រេងឥន្ធនៈ។ នាឆ្នាំ ២០០៨ ការងើបឡើងវិញនៃអតិផរណានៅដើមឆ្នាំ ២០១០ គឺជាលទ្ធផលនៃកំណើនជាថ្មីនៃថ្លៃម្ហូបអាហារ ទំនិញ សេវាក្នុងក្រុមដឹកជញ្ជូន

ព្រមទាំងផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ។ គិតតាមបម្រែបម្រួលឆ្នាំលើឆ្នាំ នាឆ្នាំ ២០១០ នេះ ក្នុងចំណោមថ្លៃទំនិញទាំង ១២ ក្រុម មាន ១១ ក្រុមបានកើនឡើង និង ១ ក្រុមបានថយចុះ។ ក្រុមធំៗដែលចូលរួមចំណែកក្នុងកំណើនអតិផរណាជាងគេនោះ គឺក្រុមទំនិញ និងសេវាកម្មផ្សេងៗ ម្ហូបអាហារ និង ភេសជ្ជៈ មិនមែនជាតិស្រវឹង និង ការដឹកជញ្ជូន ខណៈដែលក្រុមភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់បានថយចុះ។

### ៣.៣.២. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១១




នៅក្នុងឆ្នាំ ២០១១ បើទោះជាប្រទេសកម្ពុជាបានទទួលរងគ្រោះដោយទឹកជំនន់យ៉ាងធ្ងន់ធ្ងរក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាបានកើនក្នុងអត្រាប្រចាំឆ្នាំ ៧.១ភាគរយ ធៀបនឹង ៦ភាគរយ ក្នុងឆ្នាំ ២០១០។ រីឯសម្ពាធអតិផរណាក្នុងឆ្នាំ ២០១១ នេះដែរស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបានដោយមានអត្រាមធ្យមប្រចាំឆ្នាំត្រឹម ៥.៥ ភាគរយ។ ថ្លៃទំនិញទូទៅនៅលើទីផ្សារក្នុងស្រុកនៃប្រទេសកម្ពុជាបានរងសម្ពាធខ្ពស់ជាងឆ្នាំកន្លងទៅ។ កត្តាជាច្រើនរួមទាំងគ្រោះទឹកជំនន់ដែលធ្វើឲ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ក្នុងស្រុក បានរួមចំណែកដល់ការកើនឡើងនៃអត្រាអតិផរណានាឆ្នាំនេះ។ ចំពោះកត្តាក្រៅប្រទេស កម្រិតអតិផរណាខ្ពស់នៃបណ្តាប្រទេសនានាក្នុងតំបន់ដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗជាមួយប្រទេសកម្ពុជា និងការកើនឡើងថ្លៃនៃប្រេងឥន្ធនៈ និង ស្បៀងអាហារនៅលើទីផ្សារពិភពលោក ក៏មានឥទ្ធិពលគួរឲ្យកត់សម្គាល់ផងដែរមកលើថ្លៃទំនិញ និង សេវាក្នុងស្រុក។

បើពិនិត្យលើបម្រែបម្រួលឆ្នាំលើឆ្នាំឃើញថា នាដំណាច់ឆ្នាំ ២០១១ នេះ អតិផរណាមានអត្រា ៤.៩ ភាគរយ ខ្ពស់ជាងឆ្នាំ ២០១០ ដែលមានកម្រិតត្រឹម ៣.១ ភាគរយ និងទាបជាងឆ្នាំ

២០០៩ ដែលមានអត្រា ៥.៣ ភាគរយ ចលនាកើនឡើងនៃអត្រាអតិផរណាឆ្នាំលើឆ្នាំ ឆ្លុះបញ្ចាំង ដោយការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួន រួមមានក្រុម ទំនិញនិងសេវាកម្មផ្សេងៗ ភោជនីយដ្ឋាន ការដឹកជញ្ជូន ម្ហូបអាហារ និង ភេសជ្ជៈ មិនមែនជាតិស្រវឹង សម្លៀកបំពាក់និងស្បែកជើង គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និង ការថែទាំផ្ទះជាប្រចាំ ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ន និងប្រេងឥន្ធនៈដទៃទៀត ការសិក្សា និងភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់។ ទន្ទឹមនឹងនោះ សន្ទស្សន៍ថ្លៃក្រុមទំនិញដែលបានថយចុះរួមមានក្រុម សុខាភិបាល ការកម្សាន្ត និង វប្បធម៌ និង គមនាគមន៍។

### ៣.៣.៣. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១២




កាលពីខែ មេសា ឆ្នាំ ២០១២ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករណ៍ថានៅឆ្នាំ ២០១២ នេះ សេដ្ឋកិច្ចសកលស្ថិតនៅក្នុងសភាពគួរឲ្យព្រួយបារម្ភ មានអត្រាកំណើនទាបជាងឆ្នាំ ២០១១ បន្តិចនឹងអាចឈានទៅរកសង្វេបកម្មសេដ្ឋកិច្ច (Recession) ដោយសារប្រទេសអភិវឌ្ឍន៍ធំៗ នៅប្រឈមបញ្ហានិកម្មភាពខ្ពស់ និងការធ្លាក់ចុះតម្រូវការអ្នកប្រើប្រាស់ ប្រទេសខ្លះនៅតំបន់អាស៊ីប្រឈមនឹងសម្ពាធអតិផរណាខ្ពស់។ ទោះបីជាសេដ្ឋកិច្ចពិភពលោកស្ថិតនៅក្នុងស្ថានភាពមិនប្រាកដប្រជា និងមានហានិភ័យខ្ពស់ ដែលបង្ករការគំរាមគំហែងដល់កំណើនសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចនៅតំបន់អាស៊ីក៏ដោយ ក៏ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជាអាចរក្សាបានស្ថេរភាពល្អប្រសើរ ដោយសម្រេចបានកំណើន ៧ ភាគរយ ធៀបនឹង ៧.១ ភាគរយនៅឆ្នាំ ២០១១ និង ៦ ភាគរយនៅឆ្នាំ ២០១០។ ជាមួយគ្នានេះ អត្រាអតិផរណាឆ្នាំលើឆ្នាំបានធ្លាក់ចុះដល់ជិត ២ ភាគរយ ធៀបនឹង ៤.៩ ភាគរយនៅឆ្នាំ ២០១១។ បើធៀបនឹងឆ្នាំកន្លងទៅ អត្រាអតិផរណានៅឆ្នាំ

២០១២ នេះបានថយចុះគួរឲ្យកត់សម្គាល់។ ការថយចុះនេះបណ្ដាលមកពីការធ្លាក់ចុះនៃអត្រាអតិផរណានៅបណ្ដាប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗ កំណើនទាបនៃថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ គួបផ្សំនឹងកំណើនផលិតកម្មក្នុងស្រុក។ ទន្ទឹងនេះ ការរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុសមស្រប ក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាកម្រិតថ្លៃឲ្យនៅទាបផងដែរ។

ជាក់ស្ដែង អត្រាអតិផរណាឆ្នាំលើឆ្នាំមានកម្រិតទាបសមរម្យត្រឹម ២.៥ ភាគរយ ធៀបនឹង ៤.៩ ភាគរយ និង ៣.១ ភាគរយ នៅឆ្នាំ ២០១១ និងឆ្នាំ ២០១០ រៀងគ្នា។ ចលនាថយចុះនៃអត្រាអតិផរណាឆ្នាំលើឆ្នាំឆ្លុះបញ្ចាំងដោយការថយចុះនៃសន្ទស្សន៍ថ្លៃទំនិញក្រុមមួយ ចំនួនខណៈក្រុមខ្លះទៀតមានការកើនឡើងក្នុងកម្រិតទាបជាងឆ្នាំមុន ជាពិសេស ម្ហូបអាហារ និង ភេសជ្ជៈ ដែលកើនតែ ២.៤ ភាគរយ និងការដឹកជញ្ជូនតែ ០.៩ ភាគរយប៉ុណ្ណោះ ធៀបនឹងឆ្នាំមុនដែលមានកំណើន ៦.២ ភាគរយ និង ៦.៣ ភាគរយរៀងគ្នា។

### ៣.៣.៤. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៣




នៅឆ្នាំ ២០១៣ នេះ កំណើនសេដ្ឋកិច្ចសកលបន្តក្នុងល្បឿនយឺត ដោយសារការថយចុះកំណើនសេដ្ឋកិច្ចប្រទេសកំពុងងើបឡើង និង ប្រទេសកំពុងអភិវឌ្ឍន៍ ទោះបីជាកំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ត្រូវបានពង្រឹងជាលំដាប់ក៏ដោយ។ ដោយឡែកសេដ្ឋកិច្ចអាស៊ីនៅបន្តជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចពិភពលោក ថ្វីបើកំណើនមានល្បឿនទាបជាងឆ្នាំកន្លងទៅបន្តិចក៏ដោយ។ ចំពោះកម្ពុជាវិញ ទោះបីជាបានទទួលរងនូវផលប៉ះពាល់ពីគ្រោះទឹកជំនន់ និងប្រឈមនូវហានិភ័យនៃការធ្លាក់ចុះកំណើនសេដ្ឋកិច្ច ក្នុងតំបន់ និង សកលលោកក៏ដោយ សេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនរឹងមាំ ដែលគាំទ្រដោយការអភិវឌ្ឍន៍ប្រកបកោយចីរភាពនៃវិស័យកសិកម្ម ការរីក

ចម្រើនគួរឲ្យកត់សម្គាល់នៃវិស័យទេសចរណ៍ ភាពរឹងមាំនៃវិស័យកាត់ដេរសម្លៀកបំពាក់ និងការដើបឡើងជាលំដាប់នៃវិស័យសំណង់។ ជាក់ស្តែងអត្រាអតិផរណាត្រូវបានគ្រប់គ្រងឲ្យស្ថិតក្នុងកម្រិតទាបប្រមាណ ៣ ភាគរយ និងត្រូវបានតាមដានយ៉ាងយកចិត្តទុកដាក់ ជាពិសេសក្នុងអំឡុងពេលដែលកម្ពុជារៀបចំការបោះឆ្នោតសកលឆ្នាំ ២០១៣ គ្រោះទឹកជំនន់ និង កំពុងពង្រីកប្រសិទ្ធិភាពក្នុងការប្រមូលចំណូលពន្ធរបស់រាជរដ្ឋាភិបាល ដែលជាទូទៅអាចមានសម្ពាធលើសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់។

និន្នាការនៃអត្រាអតិផរណារួមឆ្នាំលើឆ្នាំ បានថយចុះគួរឲ្យកត់សម្គាល់ចាប់ពីដើមឆ្នាំ ២០១២ រហូតដល់ដើមឆ្នាំ ២០១៣ ដោយសារការធ្លាក់ចុះនៃសន្ទស្សន៍ថ្លៃខែលើខែ ចាប់ពីខែមេសា រហូតដល់ខែ កញ្ញា។ នៅចុងឆ្នាំ ២០១៣ នេះ អត្រាអតិផរណារួមឆ្នាំលើឆ្នាំមានកម្រិត ៤.៧ ភាគរយ ធៀបនឹង ២.៥ ភាគរយ នៅក្នុងគ្រាដូចគ្នាឆ្នាំ ២០១២។ បើពិនិត្យលើធាតុនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឃើញថាអត្រាបម្រែបម្រួលឆ្នាំលើឆ្នាំនៃសមាសភាពមួយចំនួនបានកើនឡើងនៅក្នុងឆ្នាំ ២០១៣។ នៅអំឡុងពេលដើមឆ្នាំសន្ទស្សន៍ថ្លៃការកម្សាន្ត និងវប្បធម៌បានកើនឡើងខ្ពស់ជាងគេ បន្ទាប់មកក្រុមសម្លៀកបំពាក់ និង ស្បែកជើង ក្រុមម្ហូបអារហារ និង ភេសជ្ជៈមិនមែនជាតិស្រវឹង និង ក្រុមភោជនីយដ្ឋាន។ នៅពាក់កណ្តាលឆ្នាំ សន្ទស្សន៍ថ្លៃក្រុមសុខាភិបាលបានកើនឡើងគួរឲ្យកត់សម្គាល់ ចំណែកឯនៅចុងឆ្នាំ សន្ទស្សន៍ថ្លៃឆ្នាំលើឆ្នាំនៃសមាសភាពរបស់សន្ទស្សន៍ថ្លៃទំនិញទាំងអស់មានស្ថិរភាពដោយសារបម្រែបម្រួលសន្ទស្សន៍ថ្លៃខែលើខែបានថយចុះចាប់ពីខែកក្កដាមក លើកលែងតែក្រុមសុខាភិបាល។ ការថយចុះកំណើននៃថ្លៃម្ហូបអារហារក្នុងស្រុកក្រោយគ្រោះទឹកជំនន់ក្នុងឆ្នាំនេះ និងការថយចុះកំណើននៃថ្លៃម្ហូបអារហារសកលនាពេលថ្មីៗនេះ គឺជាសញ្ញាវិជ្ជមានដែលអាចនឹងធ្វើឲ្យអត្រាអតិផរណារបស់កម្ពុជាសម្រាប់ឆ្នាំ ២០១៤ ថយចុះមកកម្រិតទាបជាងឆ្នាំ ២០១៣។

### ៣.៣.៥. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៤

អតិផរណារួមបានថយចុះជាបន្តបន្ទាប់ចាប់ពីខែកក្កដាមក ហើយមានកម្រិត ១,១ភាគរយ នៅចុងឆ្នាំ ២០១៤ នេះ ទាបជាងអតិផរណាឆ្នាំ ២០១៣ (៤,៦ភាគរយ)។ គួរកត់សម្គាល់ថា អតិផរណាឆ្នាំ២០១៤បានថយចុះជាងការរំពឹងទុក (៣,៥ភាគរយ)។ ម្យ៉ាងវិញទៀត ក្នុងអំឡុងឆមាសទី១ អតិផរណារួមឆ្នាំលើឆ្នាំ មានកម្រិតជាមធ្យមប្រមាណ៤,៧ភាគរយ ដោយបានកើនឡើងដល់កម្រិតខ្ពស់បំផុតត្រឹម៤,៩ភាគរយ នៅខែមីនា ដែលបណ្តាលមកពីការកើនឡើងថ្លៃក្រុមម្ហូបអាហារ ក្រុមផ្ទះសម្បែង និងក្រុមសង្ហារឹម។ ប៉ុន្តែនៅឆមាសទី២ អតិផរណាបានបន្ថយល្បឿន

កំណើនមកវិញមកកម្រិតមធ្យមប្រមាណ៣ភាគរយ និងបានថយចុះដល់កម្រិតទាបបំផុតប្រចាំឆ្នាំត្រឹម ១,១%នៅខែធ្នូដោយសារការថយចុះនៃកំណើនថ្លៃក្រុមទំនិញជាច្រើន ជាពិសេសក្រុមម្ហូបអាហារ ក្រុមផ្ទះសម្បែង ក្រុមសុខាភិបាល និងក្រុមដឹកជញ្ជូន។ កត្តាចម្បងដែលធ្វើឲ្យក្រុមទំនិញទាំងនេះថយកំណើនថ្លៃមាន៖ ការធ្លាក់ចុះនៃថ្លៃប្រេងឆៅ និងម្ហូបអាហារសកល និងការថមថយនៃអត្រាអតិផរណានៃប្រទេសដៃគូនាំចូលទំនិញមកកម្ពុជា (ប្រទេសចិន ថៃ និងវៀតណាម)។

អតិផរណាខែលើខែនៅបន្តស្ថិតក្នុងកម្រិតទាប និងបានប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ ពោលគឺបានកើនជាមធ្យមប្រមាណ០,១ភាគរយ នៅឆ្នាំ២០១៤ ក្នុងនោះមានអត្រាមធ្យម ០,៣៦ ភាគរយ ក្នុងឆមាសទី១ និង -០,១៧ភាគរយ ក្នុងឆមាសទី២។ កម្រិតអត្រាទាបនេះបានរួមចំណែកបន្ថយសម្ពាធលើអតិផរណារួមឆ្នាំលើឆ្នាំឲ្យស្ថិតនៅទាប។




ក្រុមម្ហូបអាហារនៅបន្តរួមចំណែកធំជាងគេនៅក្នុងអតិផរណារួម និងបានរក្សាអត្រាកំណើនជាមធ្យមប្រមាណ៥%ក្នុងឆ្នាំ២០១៤ ដោយសារការផ្គត់ផ្គង់ក្នុងស្រុកនៅមានកម្រិតមិនទាន់អាចផ្គត់ផ្គង់គ្រប់គ្រាន់តាមតម្រូវការ ហើយនៅបន្តពឹងផ្អែកខ្លាំងលើការនាំចូលទំនិញ ជាពិសេសក្រុមសាច់ និងបន្លែពីប្រទេសថៃ និងវៀតណាម។ ជាក់ស្តែងក្នុងអត្រាអតិផរណារួម ក្រុមម្ហូបអាហារបានរួមចំណែក ១,៨% ក្រុមភោជនីយដ្ឋាន០,៣% ក្រុមសង្ហារឹម ០,២% និងក្រុមទំនិញផ្សេងៗ -០,៧%។ ចំណែកឯក្រុមដឹកជញ្ជូនបានចូលរួមចំណែកបន្ទាបអតិផរណារួមដោយសារថ្លៃប្រេងសាំង និងម៉ាស៊ូតបានថយចុះជាបន្តបន្ទាប់ចាប់ពីខែសីហាមក។

### ៣.៣.៦. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៥

ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៥ មានភាពល្អប្រសើរធៀបនឹងឆ្នាំ២០១៤ដោយសារការធ្លាក់ចុះនៃថ្លៃប្រេង អត្រាអតិផរណាទាបនៅក្នុងប្រទេសនាំទំនិញចូលមកកម្ពុជា និងការគ្រប់គ្រង

ការផ្គត់ផ្គង់រូបិយវត្ថុប្រកបដោយប្រសិទ្ធភាព។ នៅក្នុង២០១៥នេះ អតិផរណារួមគិតជាមធ្យមមានកម្រិតទាបត្រឹម១,២%ប៉ុណ្ណោះធៀបនឹងឆ្នាំ២០១៤ (៣,៩%) នឹងទាបជាងការរំពឹងទុករបស់រាជរដ្ឋាភិបាល (៣%)។

បើពិនិត្យមើលពីការប្រែប្រួលក្នុងឆ្នាំ២០១៥នេះ អត្រាអតិផរណារួមឆ្នាំលើឆ្នាំបានប្រែប្រួលក្នុងកម្រិតទាបទៅតាមកត្តារដូវកាល។ នៅខែមករា អតិផរណារួមបានថយចុះដល់០,៤% ប៉ុន្តែនៅខែកុម្ភៈបានកើនឡើងបន្តិចមកវិញដល់១,៦%ដោយសារការកើនឡើងនៃតម្រូវការប្រើប្រាស់ក្នុងស្រុក ជាពិសេសក្រុមម្ហូបអាហារនៅក្នុងពិធីចូលឆ្នាំប្រពៃណីផ្សេងៗ ខណៈដែលក្រុមដឹកជញ្ជូនបានចូលរួមបន្ទាបអត្រាអតិផរណា។ ចាប់ពីខែមីនាដល់ខែកញ្ញា អត្រាអតិផរណាមានស្ថិរភាពជាមធ្យមប្រមាណ១%ប៉ុណ្ណោះ។ ដោយឡែកនៅក្នុងត្រីមាសទី៤ អតិផរណារួមបានកើនពី១,៣%នៅខែតុលាដល់២,៦%នៅខែធ្នូ (តាមការប៉ាន់ស្មាន) ដែលបណ្តាលមកពីកំណើនតម្រូវការក្នុងរដូវកាលបុណ្យប្រពៃណីជាតិធំៗ និងបុណ្យចូលឆ្នាំសកល។




ការថយចុះនៃថ្លៃប្រេងកម្ពុជាបណ្តាលមកពីការធ្លាក់ថ្លៃប្រេងពិភពលោកដោយសារកម្ពុជាជាប្រទេសនាំចូលប្រេងសុទ្ធ។ នៅឆមាសទី១ តម្លៃប្រេងធម្មតាជាមធ្យមមានតម្លៃ៤.១០៨រៀលក្នុងមួយលីត្រ (ប្រមាណ១ដុល្លារអាមេរិក) បន្ទាបមកនៅឆមាសទី២ ថ្លៃប្រេងសាំងបានថយចុះមក ៣.៧៣៣ រៀលក្នុងមួយលីត្រ (ប្រមាណ០,៩ដុល្លារអាមេរិក)។ ជាមធ្យម តម្លៃប្រេងនៅកម្ពុជាបានធ្លាក់ចុះ ២៣ភាគរយ (ឆ្នាំលើឆ្នាំ)។

ម្យ៉ាងវិញទៀត អតិផរណាទាបនៅក្នុងបណ្តាប្រទេសនាំចូលមកកម្ពុជាបានរួមចំណែកបន្ទាបអតិផរណាកម្ពុជា។ ជាក់ស្តែងអតិផរណាកែតម្រូវដែលបង្ហាញពីឥទ្ធិពលនាំចូលមកកម្ពុជាមានកម្រិតជាមធ្យមត្រឹម -០.២ភាគរយ ប៉ុណ្ណោះដោយសារប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម បាតថៃ និងដុល្លារតៃវ៉ាន់ គួបផ្សំនឹងអត្រាអតិផរណាទាបរបស់ប្រទេសថៃ និង

តែវ៉ាន់ដែលបានថយចុះដល់កម្រិត -០,៩ភាគរយ និង -០,៣ភាគរយ រៀងគ្នា។ មូលហេតុចម្បងនៃការថយចុះនៃអត្រាអតិផរណារបស់ប្រទេសទាំងនោះបណ្តាលមកពីការថយចុះថ្លៃម្ហូបអាហារ និងជាពិសេសថ្លៃថាមពល។

ជារួមអត្រាអតិផរណាស្ថិតក្នុងកម្រិតទាបដោយសារការថយចុះនៃថ្លៃប្រេង សម្ពាធទាបនៃអតិផរណានាំចូល និងជាពិសេសប្រសិទ្ធភាពនៃការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុដោយធនាគារជាតិនៃកម្ពុជា ទោះបីជាសន្ទុះកំណើនសកម្មសេដ្ឋកិច្ចក្នុងស្រុកបានបន្តជម្រុញតម្រូវការឲ្យកើនឡើងហើយបានបង្កើតជាសម្ពាធអតិផរណាក្នុងឆ្នាំ២០១៥នេះក្តី។

### ៣.៣.៧. ស្ថានភាពអតិផរណាក្នុងឆ្នាំ ២០១៦

អតិផរណាខែលើខែបន្តស្ថិតក្នុងកម្រិតទាបដោយជាមធ្យមមានអត្រាត្រឹម ០,២ភាគរយ ប្រហាក់ប្រហែលនឹងឆ្នាំ២០១៥។ អតិផរណាខែលើខែបានប្រែប្រួលបន្តិចបន្តួចតាមកត្តារដូវកាល ដោយបានកើនឡើងខ្ពស់បន្តិចនៅខែកុម្ភៈ (០,៤ភាគរយ) និងមេសា (១,៤ភាគរយ) ដោយសារកំណើនថ្លៃក្រុមម្ហូបអាហារក្នុងអំឡុងពេលចូលឆ្នាំប្រពៃណីចិន វៀតណាម នឹងខ្មែរ ប៉ុន្តែសម្រាប់ខែផ្សេងៗទៀត ជាពិសេសនៅ៣ខែចុងឆ្នាំ ថ្លៃក្រុមម្ហូបអាហារ ក្រុមដឹកជញ្ជូន និងក្រុមផ្ទះសម្បែងមានកំណើនទាបដែលធ្វើឲ្យអត្រាអតិផរណាមាកកម្រិតត្រឹម០,១ភាគរយ ប៉ុណ្ណោះ។ ជារួមអត្រាអតិផរណាខែលើខែបន្តស្ថិតក្នុងកម្រិតទាបដែលមិនបង្កជាសម្ពាធខ្លាំងធ្វើឲ្យអតិផរណាឆ្នាំលើឆ្នាំកើនឡើងខ្ពស់ឡើយ។




អត្រាអតិផរណាឆ្នាំលើឆ្នាំបានកើនឡើងវិញបន្តិចដោយមានកម្រិតជាមធ្យមប្រមាណ២,៩ភាគរយ ធៀបនឹងឆ្នាំ២០១៥ (១,២ភាគរយ) ប៉ុន្តែទាបជាងឆ្នាំ២០១៤ (៣,៩ភាគរយ) ក្នុងនោះនៅ

ឆមាសទី១ ឆ្នាំ២០១៦ អតិផរណាមានកម្រិតមធ្យម ២,៨ភាគរយ ខ្ពស់ជាងគ្រាដូចគ្នានៅឆ្នាំ២០១៥ ( ១ភាគរយ) បន្ទាប់មកនៅក្នុងឆមាសទី២ មានអត្រា២,៩ភាគរយ ខ្ពស់ជាងគ្រាដូចគ្នានៅឆ្នាំ ២០១៥ (១,៩ភាគរយ)។ ការកើនឡើងនៃអត្រាអតិផរណាឆ្នាំ២០១៦ជាចម្បងបណ្តាលមកពី កំណើនថ្លៃក្រុមម្ហូបអាហារ (៥ភាគរយ) ក្រុមសម្លៀកបំពាក់ (៤,២ភាគរយ) និងក្រុមភោជនីយដ្ឋាន (៣,៦ភាគរយ)។ អតិផរណាក្នុងក្រុមទាំងនេះបានឆ្លុះបញ្ចាំងពីកំណើនតម្រូវការរបស់អ្នកប្រើប្រាស់ ខណៈដែលអត្រាអតិផរណារបស់ប្រទេសជាដៃគូផ្គត់ផ្គង់ទំនិញនាំចូលសំខាន់ៗរបស់កម្ពុជាមាន កម្រិតទាប។ ទោះបី ជាយ៉ាងនេះក៏ដោយថ្លៃក្រុមដឹកជញ្ជូន និងការប្រើប្រាស់ក្នុងផ្ទះសម្បែងមាន កំណើនមធ្យមទាបដោយសារការថមថយនៃថ្លៃប្រេងសាំង និងថាមពលនៅកម្ពុជា ហើយក្រុមទាំង ពីរនេះក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយអតិផរណារួមឲ្យស្ថិតក្នុងកម្រិតទាបផង ដែរ។

ជារួមអតិផរណានៅឆ្នាំ២០១៦ បន្តមានកម្រិតទាបស្របតាមការប៉ាន់ស្មានក្នុងក្របខ័ណ្ឌ គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងបានអំណោយផលដល់ការលើកស្ទួយសកម្មភាព ផលិតកម្ម និងពាណិជ្ជកម្មក្នុងស្រុក ព្រមទាំងបានរួមចំណែកដ៏សំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូ សេដ្ឋកិច្ច។

## ៣.៤. កត្តាជះឥទ្ធិពលមកលើអតិផរណាក្នុងប្រទេសកម្ពុជា

### ៣.៤.១ កត្តាខាងក្រៅដែលជះឥទ្ធិពលមកលើអតិផរណាកម្ពុជា

#### ៣.៤.១.១. ថ្លៃប្រេងនៅពិភពលោក

ចាប់តាំងពីដើមឆ្នាំ រហូតដល់ត្រឹមត្រីមាសទី៣ ក្នុងឆ្នាំ២០០៩ ទោះបីសេដ្ឋកិច្ចពិភពលោក ទទួលរងនូវកំណើនអវិជ្ជមានក៏ដោយក្តី ថ្លៃប្រេងឥន្ធនៈលើទីផ្សារពិភពលោកមាននិន្នាការកើន ឡើងជាបន្តបន្ទាប់រហូតដល់ខែមេសាថ្មីៗនេះ។ ការនេះធ្វើថ្លៃប្រេងឥន្ធនៈក្នុងស្រុកកើនឡើងជា លំដាប់ដែរ ដូចជា ថ្លៃប្រេងសាំងដែលកើនពី ៤០៥០ រៀលក្នុងមួយលីត្រនាខែមករា ឆ្នាំ២០០៩ ដល់ ៤៤០០ រៀលក្នុងមួយលីត្រនាខែមេសា ឆ្នាំ ២០១០ ឬ ៨.៦ភាគរយ ហើយក្រុមទំនិញជា ឧស្ម័ន ឥន្ធនៈ និងសេវាដឹកជញ្ជូនជារួមកើនឡើងប្រមាណ ១៩ភាគរយ ដែលក្នុងនោះសេវាដឹក ជញ្ជូនមានកំណើន ៣ភាគរយ ធៀបនឹងខែមេសា ឆ្នាំមុន។ ម្យ៉ាងវិញទៀត ការឡើងថ្លៃប្រេងពិភព លោកនៅតែបន្តដល់ឆ្នាំ២០១១ ដោយសារសេដ្ឋកិច្ចពិភពលោកកំពុងងើបឡើងវិញ តម្រូវការ ប្រេងឥន្ធនៈរបស់ សហរដ្ឋអាមេរិក និងចិន ព្រមទាំងបញ្ហាអស្ថិរភាពផ្នែកនយោបាយនៃប្រទេសនាំ ចេញប្រេងធំៗមួយចំនួន ដូចជា នីស្សេរីយ៉ា លីប៊ី និងអារ៉ាប៊ីសាវឌីត និងការធ្លាក់ថ្លៃប្រាក់ដុល្លារ

អាមេរិក បានធ្វើឲ្យថ្លៃប្រេង និង ម្ហូបអាហារក្នុងពិភពលោកកើនឡើងជាបន្តបន្ទាប់ គិតមកដល់ខែកុម្ភៈ ឆ្នាំ ២០១១ នេះ។ ការណ៍នេះ បានធ្វើឲ្យថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារក្នុងស្រុកមានកំណើនឆ្នាំលើឆ្នាំប្រមាណ ១៩% និង ៣.៩% ក្នុងខែកុម្ភៈ ឆ្នាំ ២០១១ នេះ ធៀបនឹង ៣២.៧% និង ៨.៦% នាខែដូចគ្នា ឆ្នាំ ២០១០ រៀងគ្នាផងដែរ។ ទន្ទឹមនឹងនេះ ថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិនៅក្នុងខែមេសា ឆ្នាំ២០១២ ស្មើរនឹង ០.៨៩ដុល្លារអាមេរិកក្នុង១លីត្រ ខណៈថ្លៃប្រេងឥន្ធនៈក្នុងស្រុកស្មើរនឹង ១.៣៩ដុល្លារអាមេរិកក្នុង១លីត្រ។

គួរកត់សម្គាល់ថាទោះបីជាថ្លៃប្រេងឆៅអន្តរជាតិបានថយចុះ ប៉ុន្តែថ្លៃប្រេងឥន្ធនៈក្នុងកម្ពុជាមិនទាន់ថយចុះភ្លាមៗ ហើយនៅមានតម្លៃខ្ពស់ដដែល។ ទាំងនេះ គឺជាកាតាលីករក្នុងការជម្រុញថ្លៃផលិតកម្ម ថ្លៃទំនិញនិងសេវាបានកើនឡើងនៅលើទីផ្សារនៅក្នុងស្រុកនាពេលនោះ។ ដោយឡែកក្នុងឆ្នាំ២០១៤ ថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិក៏បានថយចុះជាលំដាប់ ជាពិសេសក្នុងឆមាសទី២ បន្ទាប់ពីបានកើនដល់កម្រិតខ្ពស់បំផុតប្រចាំឆ្នាំនៅខែមិថុនា។ ថ្លៃប្រេងឆៅបានធ្លាក់ចុះដល់ ០,៣៩ដុល្លារអាមេរិកក្នុង១លីត្រ ពោលគឺធ្លាក់ចុះ៤៥%ឆ្នាំលើឆ្នាំ ទាបជាងឆ្នាំ២០១៣ (៦,៩%) ដោយសារការកើនឡើងខ្លាំងនៃផលិតកម្មប្រេងឆៅ ជាពិសេសនៅប្រទេសលីប៊ី និងប្រទេស ផលិតប្រេង (OPEC) ខណៈដែលកំណើនតម្រូវការបានថមថយស្របតាមការថយចុះនៃសន្ទុះកំណើនសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន គួបផ្សំនឹងការឡើងថ្លៃប្រាក់ដុល្លារអាមេរិក។ ទន្ទឹមនឹងនេះ ថ្លៃប្រេងសាំងនៅកម្ពុជាវិញក៏បានថយចុះជាបន្តបន្ទាប់ចាប់ពី៥.៣៥០រៀលក្នុង១លីត្រនៅខែកក្កដាមកដល់៤.៤០០រៀលនៅខែធ្នូ ពោលគឺបានថយចុះ ៥,៨ភាគរយ ឆ្នាំលើឆ្នាំធៀបនឹងខែធ្នូឆ្នាំ២០១៣។

សរុបមក ការឡើងចុះនៃប្រេងឆៅពិភពលោកបានបង្ហាញពីផលវិជ្ជមាននិងអវិជ្ជមានមកលើថ្លៃប្រេងសាំង និងថ្លៃទំនិញផ្សេងៗនៅកម្ពុជា ដូចជា ថ្លៃភ្នូរាស់ ដាំដុះ និង ដឹកជញ្ជូន។ល។ និងបានរួមចំណែកយ៉ាងសំខាន់បង្កើន និងបន្ថយសម្ពាធអតិផរណានៅក្នុងកម្ពុជា។

### ៣.៤.១.២.. អតិផរណានៃប្រទេសនាំចូលទំនិញមកកម្ពុជា

កត្តាថ្លៃទំនិញសំខាន់មួយទៀត គឺជាអតិផរណាដែលកើតចេញពីថ្លៃទំនិញនាំចូលពីប្រទេសជិតខាងវៀតណាម និង ថៃ ដូចជាថ្លៃស្បៀងអារហារ សម្ភារៈនិងគ្រឿងសំណង់ជាដើម។ ក្នុងរយៈពេល ៦ខែ ចុងក្រោយនាឆ្នាំ២០១០ អត្រាអតិផរណានៃប្រទេសដៃគូពាណិជ្ជកម្មសំខាន់ទាំងពីរបានបង្កើនល្បឿនគួរឲ្យកត់សម្គាល់ ជាពិសេសប្រទេសវៀតណាមដែលអាចជាមូលហេតុមួយផ្នែកនៃកំណើនល្បឿនអត្រាអតិផរណារបស់ប្រទេសកម្ពុជា។ សម្ពាធអតិផរណាប្រចាំឆ្នាំនៅ

ប្រទេសថៃបានថយល្បឿនបន្តិច ជាលើកទី២ មកកម្រិត ២.៩ភាគរយ ក្នុងខែកុម្ភៈ ឆ្នាំ ២០១១ នេះ បន្ទាប់ពីបានបង្កើនល្បឿនរយៈពេលពីរខែ នៅចុងឆ្នាំ ២០១០ ខណៈដែលសម្ពាធអតិផរណា នៅប្រទេសវៀតណាម និងចិន មាននិន្នាការកើនឡើងជាបន្តបន្ទាប់ដល់ កម្រិត ១២.៣ភាគរយ និង ៤.៩ភាគរយ រៀងគ្នា។ ការកើនឡើងនៃ អតិផរណារបស់ប្រទេសវៀតណាម និងចិន បូករួមជាមួយ បម្រែបម្រួលនៃអត្រាប្តូរប្រាក់របស់ចិន និងវៀតណាម បានចូលរួមចំណែកមួយផ្នែកក្នុង កំណើន អតិផរណារបស់កម្ពុជា ក្នុងឆ្នាំ ២០១១ នេះផងដែរ។ លើសពីនេះទៅទៀត បម្រែបម្រួលអត្រាប្តូរប្រាក់នៃប្រទេសដៃគូធៀបនឹងប្រាក់ដុល្លារ ព្រមទាំងប្រាក់រៀលក៏មានឥទ្ធិពលដ៏ចម្បងដែរលើថ្លៃទំនិញ និងអតិផរណាក្នុងស្រុកផងដែរ។

ជារួម ការឡើងថ្លៃទំនិញនៅកម្ពុជា គឺបណ្តាលមកពីការនាំចូលទំនិញពីប្រទេសជិតខាង មានន័យថា បើអតិផរណានៅប្រទេសជិតខាងកើនឡើងនឹងជះឥទ្ធិពលដល់ប្រទេសកម្ពុជាដែរ។

### ៣.៤.២. កត្តាក្នុងស្រុកដែលជះឥទ្ធិពលមកលើអតិផរណាកម្ពុជា

#### ៣.៤.២.១.កត្តាធម្មជាតិ

ជាការពិតណាស់ការកើនឡើងនូវអតិផរណាក៏អាចបណ្តាលមកពីគ្រោះធម្មជាតិជា ច្រើនផងដែរដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រញ្ជួយដី ខ្យល់ព្យុះ។ល។ នៅក្នុង ប្រទេសកម្ពុជា គ្រោះទឹកជំនន់គឺជាកត្តាធម្មជាតិមួយយ៉ាងចំបងដែលធ្វើឲ្យរាជរដ្ឋាភិបាល និងប្រជាជនមានការកង្វល់ខ្លាំងទៅលើបញ្ហានេះ។ ភ្លៀងធ្លាក់ខ្លាំងបានហូរកាត់ទន្លេមេគង្គ យ៉ាងលើសលប់ចាប់តាំងពីសប្តាហ៍ទី២នៃខែ សីហា ក្នុងឆ្នាំ២០១១ បានជះឥទ្ធិពលទៅលើខេត្តទាំង១៨ក្នុងចំណោមខេត្តទាំង ២៤ នៃប្រទេសកម្ពុជា។ វាបានបំផ្លិចបំផ្លាញភោគផលដំណាំជាច្រើនដូចជា ស្រូវ បន្លែ ផ្លែឈើ ផ្សេងៗរួមទាំងបរាសិតដូចជា គោ ក្របី ជ្រូក ។ល។ លើសពីនេះទឹកជំនន់ នេះបានធ្វើឲ្យខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា ដូចជា ស្ពាន ផ្លូវថ្នល់ សាលារៀន ផ្ទះសំបែងរបស់ប្រជាជន ហើយបានកំពុងតែជះឥទ្ធិពលទៅលើប្រជាជនជាង ១.២លាននាក់ផងដែរ។ សេចក្តីរាយការណ៍បានបង្ហាញថាមនុស្ស ២៤៧នាក់បានស្លាប់នៅ ក្នុងគ្រោះទឹកជំនន់នេះ។ ដីពោរពេញទៅដោយទឹកអស់រយៈពេលជាច្រើនខែ ហើយទើបតែស្រកទៅវិញនៅក្នុងខែធ្នូ។ ដោយសារតែគ្រោះទឹកជំនន់នេះបានធ្វើឲ្យ ទំនិញជាច្រើនចាប់ផ្តើមឡើងថ្លៃដោយសារវត្ថុធាតុដើមសំរាប់ផលិតត្រូវបានខូចខាត គ្មានទំនិញសំរាប់ផ្គត់ផ្គង់ ជាហេតុធ្វើឲ្យមានអតិផរណាកើនឡើងយ៉ាងខ្លាំងនៅកំឡុងពេលនោះ។

### ៣.៤.២.២.កត្តាតម្រូវការនិងរូបិយវត្ថុ

សភាពប្រសើរឡើងនៃទិដ្ឋភាពសេដ្ឋកិច្ចសកលលោក រួមទាំង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា បានចូលរួមបង្កើនទំនុកចិត្តវិស័យឯកជន មកលើប្រព័ន្ធធនាគារ ហើយបានចូលរួមចំនែកធ្វើឲ្យការអភិវឌ្ឍន៍រូបិយវត្ថុក្នុងប្រទេសមានសន្ទុះឡើងវិញ ជាបណ្តើរៗ ខណៈ សូចនាកររូបិយវត្ថុដូចខាងក្រោមៈ

អត្រាកំណើនរូបិយវត្ថុទូទៅ (M2) ឆ្នាំលើឆ្នាំ នាខែ មេសា ឆ្នាំ ២០១០ នេះ ស្មើ ៣៨ភាគរយ ដែលជាកម្រិតដូចគ្នា នាខែមិនា កន្លងទៅ ។ រូបិយវត្ថុទូទៅនេះធ្លាប់មានកំណើន ត្រឹមតែ ៣ ភាគរយ ប៉ុណ្ណោះ នាខែ មេសា ឆ្នាំ ២០០៩ និងមានកំណើន រហូតដល់ ៥៧ភាគរយ នាខែដូចគ្នា ឆ្នាំ ២០០៨ ។ ប្រភពចម្បងនៃកំណើន ក្នុងខែមេសា ឆ្នាំ២០១០ នេះគឺ ប្រាក់បញ្ញើជារូបិយប័ណ្ណ ដែលមានកំណើនដល់ ៤០ភាគរយ ហើយបានរួមចំណែក ៣២ភាគរយ ទៅក្នុងរូបិយវត្ថុទូទៅ (M2) 38ភាគរយ នោះ។ ទន្ទឹមនេះដែរ រូបិយវត្ថុក្នុងចរាចរបានកើនឡើង ២២ភាគរយ ហើយបានចូលរួម ៤ភាគរយ ប៉ុណ្ណោះនៃកំណើនរូបិយវត្ថុទូទៅ។ សូមកត់សម្គាល់ថា អត្រាកំណើន មធ្យមនៃរូបិយវត្ថុ (M2) និងរូបិយវត្ថុក្នុងចរាចរ ក្នុងអំឡុងឆ្នាំ ២០០៦-២០០៩ ស្មើនឹង ៣២ភាគរយ និង ២២ ភាគរយ រៀងគ្នា។ ដូច្នេះ អត្រាកំណើនរូបិយវត្ថុទូទៅ៣៨ភាគរយនិងអត្រាកំណើនរូបិយវត្ថុក្នុងចរាចរ ២៣ភាគរយ គឺជាអត្រាកំណើនមួយសមរម្យដែលអាចរក្សាហានិភ័យ អត្រាអតិផរណាស្ថិតក្នុងកម្រិតមួយទាប ខណៈថ្លៃ ប្រេងពិភពលោកមានការថយចុះនាពេលថ្មីៗនេះ។

## ៣.៥. ផលប៉ះពាល់នៃអតិផរណា

### ៣.៥.១.ផលប៉ះពាល់ទៅលើបុគ្គលិកធ្វើការតាមរោងចក្រ

អតិផរណាបានផ្តល់ផលប៉ះពាលដល់អ្នកដែលមានចំណូលទាប។ ជាក់ស្តែង អ្នកស្រីគង់ វិសាលអាយុ ២៥ឆ្នាំជាកម្មករកាត់ដេររោងចក្រម្នាក់នៅភ្នំពេញបាន និយាយថា "ការកើនឡើងនៃអតិផរណាបានធ្វើឲ្យជីវភាពរស់នៅរបស់គាត់ធ្លាក់ចុះយ៉ាងខ្លាំង។" ជាលទ្ធផលនៅ ពេលនេះអ្នកស្រីបានចាប់ផ្តើមហូបតិចជាងមុន និងផ្ញើរប្រាក់ទៅផ្ទះតិចជាងមុន ពី៥០០០០ ដល់ ៨០០០០ រៀល ប្រៀបធៀបទៅនឹង ១០០០០០រៀល មុនពេលដែលគ្រឿងម្ហូបអាហារចាប់ផ្តើម ឡើងថ្លៃ។ លើសពីនេះទៅទៀត អ្នកស្រីចាប់ផ្តើមខ្ចីប្រាក់គេនៅពេលខ្វះប្រាក់ដើម្បីបំពេញអោយ បានដល់ដាច់ខែ។ នៅពេលដែលបានសួរថា តើអ្នកស្រីបានធូរស្រាលជាងមួយទន្ទឹមនឹងការតម្លើង ប្រាក់ខែ ៦ដុល្លារ ប្រៀបធៀបទៅនឹងជីវភាពរបស់អ្នកស្រី មុនពេលមានអតិផរណាខ្ពស់អ្នកស្រីបាន និយាយថា "ទេ" ដោយសារអ្វីៗឡើងថ្លៃច្រើនពេក។ របស់ខ្លះឡើងថ្លៃពីរដង ខ្លះទៀតឡើងថ្លៃ ដល់ទៅបីដង។

ដូច្នេះការតម្លើងប្រាក់ខែ ៦ដុល្លារមិនអាចទប់ទល់នឹងឥទ្ធិពលនៃការឡើងថ្លៃទេ។ អ្នកស្រីបាន បន្ថែមទៀតថា"ពេលនេះម្តាយរបស់គាត់ចង់ឲ្យគាត់ឈប់ធ្វើការ និងត្រលប់ទៅផ្ទះវិញ ដោយសារប្រាក់សន្សំរបស់គាត់ មិនអាចទ្រទ្រង់ ការរស់នៅនិងការធ្វើការងារនៅក្នុងរាជធានីទេ"។

### ៣.៥.២.ផលប៉ះពាល់ទៅលើកុមារ សិស្ស និស្សិត

កូនចៅរបស់អ្នករងផលប៉ះពាល់ទាំងនោះទំនងជានឹង ត្រូវរងឥទ្ធិពលបណ្តាលឲ្យមានភាពក្រីក្រខ្លាំងនិង យូរអង្វែងនៃការឡើងថ្លៃអាហារ។ ជាមួយការកាត់បន្ថយការបរិភោគអាហារ កង្វះអាហារូបត្ថម្ភតាំងពីនៅកុមារ និងនាំឲ្យពួកគេមាន សុខភាពខ្សោយសមត្ថភាពបញ្ញាទាប ការសិក្សាតិច និងប្រាក់ចំណូលទាបក្នុងជីវិត។ កុមារអាចត្រូវបានដកចេញពីសាលារៀនដើម្បី ជាវិធីមួយនៃយុត្តិសាស្ត្រ របស់មាតាបិតាពួក គេក្នុងការដោះស្រាយការឡើងថ្លៃអាហារ។ ហើយគួរឲ្យស្តាយដែលគេដឹងតាមបទពិសោធន៍ កន្លងមកថា កុមារដែលបានដកចេញពីសាលារៀននៅពេលមានការលំបាក កម្រត្រលប់ទៅ រៀនវិញណាស់ហើយគ្រួសារអាចជួបការលំបាកខ្លាំងក្នុងការកសាងឡើងវិញនូវទ្រព្យដែលជីវភាពពួកគេអាស្រ័យលើ។

### ៣.៥.៣.ផលប៉ះពាល់ទៅលើមន្ត្រីរាជការដែលមានប្រាក់បៀវត្ស

ប្រាក់បៀវត្ស គឺជាប្រាក់ថ្លៃឈ្នួល ពលកម្ម ដែលបុគ្គលិករឺ កម្មករទទួលបានជាប្រចាំក្នុងអំឡុងពេលដែលគេកំពុងបំពេញការងារនៅតាម គ្រឹះស្ថាន រឺក្រុមហ៊ុនណាមួយ។ ចំពោះមន្ត្រីរាជការដែលមានប្រាក់បៀវត្ស នៅពេលដែលមាន អតិផរណាកើតឡើង វាជម្រុញឲ្យគ្រួសារចំណាយបន្ថែមទៀតហេតុនេះវាធ្វើឲ្យការសន្សំធ្លាក់ចុះ។ ប្រាក់បៀវត្សរបស់ពួកគេមិនអាចទប់ទល់នូវការ ចំណាយប្រចាំថ្ងៃបានទៀតឡើយ ដោយសារទំនិញមានតម្លៃកើនឡើង នៅពេលមាន អតិផរណាកើតឡើង។

## ៣.៦. ដំណោះស្រាយរបស់រដ្ឋាភិបាលលើបញ្ហាអតិផរណា

ជាបឋម រាជរដ្ឋាភិបាលកម្ពុជាបានដាក់នូវវិធានការរយៈពេលខ្លី សំដៅកាត់បន្ថយឥទ្ធិពលនៃអតិផរណា ជាងការប្រឆាំង អតិផរណាដោយផ្ទាល់។វិធានការទាំងនោះរួមមាន៖

- **តម្លើងប្រាក់បៀវត្សមូលដ្ឋាន២០%ដល់មន្ត្រីរាជការ និងតម្លើងប្រាក់ខែគោលដល់កម្មកររោងចក្រ៖** ដោយមានការកើនឡើងអតិផរណារ រដ្ឋាភិបាលបានសម្រេចតម្លើងប្រាក់បៀវត្សដល់មន្ត្រីរាជការ និងតម្លើងប្រាក់ខែគោលដល់កម្មកររោងចក្រ ដើម្បីជាយន្តការទប់ទល់នៃការកើនឡើងនៃអតិផរណាកុំឲ្យអំណាចទិញរបស់ពួកគេថយចុះ។រហូតមកដល់ឆ្នាំ២០១៦ រដ្ឋាភិបាលបានសម្រេចតម្លើងប្រាក់ខែកម្មករ ១៤០ដុល្លារ សម្រាប់ការចំណាយទៅលើ

បញ្ហាអតិផរណា សុខភាព និង បញ្ហាផ្សេងទៀតបាន។

- **ការកាត់បន្ថយសារពើពន្ធសម្រាប់វិស័យកសិកម្ម៖**នៅក្នុងគោលនយោបាយសារពើពន្ធ នាយករដ្ឋមន្ត្រីបានប្រកាសកាត់បន្ថយនូវពន្ធគយលើការនាំចូលផលិតផលកសិកម្ម និង កសិឧស្សាហកម្ម។ រាជរដ្ឋាភិបាលបានទទួលខុសត្រូវ ថវិការដែលបានមកពីពន្ធនៃតំលៃ បន្ថែមលើផលិតផលទាំងនេះ ដោយអោយរួចពន្ធទាំងស្រុងនូវការនាំចូលវត្ថុធាតុដើម ប្លាស្ទិចនិងលោហធាតុ ព្រមទាំងកាត់បន្ថយពី ៣៥ភាគរយ មក ៧ភាគរយ សំរាប់ពន្ធគយ លើការនាំចូលផលិតផលគីមីសរីរាង្គ។ លោក កង ចាន់ដារ៉ារ័ត្ន អ្នកសេដ្ឋកិច្ចនិងជាប្រធាន វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍កម្ពុជាបានបញ្ជាក់ថា "ពិតជាមានការយកចិត្តទុកដាក់លើពន្ធនាំចូល ឧបករណ៍កសិកម្ម និងវត្ថុធាតុ ដើមសម្រាប់កសិកម្ម។" លោកសង្ឃឹមថា ទាំងនេះនឹងជួយ សម្រួលដល់ការងារ របស់កសិករ។ ពួកគេនឹងបានឯករាជ្យជាងមុន និងអាចលក់ ផលិតផលខ្លួនក្នុងតម្លៃថោកជាងមុន។ អ្នកសេដ្ឋកិច្ចរូបនេះមានប្រសាសន៍បន្ថែមទៀតថា ការលើកទឹកចិត្តដល់ការផលិតក្នុងប្រទេស កម្ពុជាបានបង្ហាញពីទំនួលខុសត្រូវរបស់ រដ្ឋាភិបាលក៏ដូចជាប្រទេសផ្តល់ជំនួយដែរ។ ការនាំចេញអង្ករបស់កម្ពុជាអាចជួយធ្វើ អោយទីផ្សារពិភពលោកមានតុល្យភាព។ ប៉ុន្តែ លទ្ធផលដែលសង្ឃឹមទុកនឹងមិនកើតមាន ឡើងភ្លាមៗនោះទេ ព្រោះអតិផរណាបណ្តាលមក ពីតម្លៃប្រេងឥន្ធនៈ ដែលចេះតែឡើងថ្លៃ ចាប់ពីឆ្នាំ២០០៣ មកដល់បច្ចុប្បន្ននិងនៅ តែបន្តឡើង ថ្លៃ និងបណ្តាលពីតម្លៃផលិតផល កសិកម្មដែលការផលិតមិនមានការកើនឡើងនោះទេ។
- **ការឧបត្ថម្ភលើការនាំចូលប្រេង និងថាមពលអគ្គីសនី៖** ដើម្បីកុំឲ្យការឡើងថ្លៃប្រេងខ្ពស់ យ៉ាងនេះដែលធ្វើឲ្យថ្លៃទំនិញផ្សេងៗទៀតឡើងបន្តគ្នា បណ្តាលឲ្យមានអតិផរណាកាន់តែ ខ្ពស់នោះ រាជរដ្ឋាភិបាលបានផ្តល់ឧបត្ថម្ភប្រេង (ដោយកំណត់នូវតម្លៃរដ្ឋបាលទាបសម្រាប់ ការគណនានៃពន្ធអាករនាំចូល)។ រដ្ឋាភិបាលក៏បានរក្សាពន្ធអគ្គីសនីនៅកម្រិតដូចគ្នា ដោយឧបត្ថម្ភធនដោយផ្ទាល់ដល់ក្រុមហ៊ុនអគ្គីសនីកម្ពុជា ( EDC) ដែលផ្តល់សេវាផ្គត់ផ្គង់ ថាមពលដ៏ចម្បង។

# ជំពូកទី៤
# ការពិភាក្សាវិភាគទៅលើលទ្ធផលនៃរបកគំហើញ

# ជំពូកទី ៤៖ ការពិភាក្សា វិភាគទៅលើលទ្ធផលនៃរបកគំហើញ

## ៤.១. អំពីសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

### ៤.១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៃក្រុមនីមួយៗក្នុងប្រទេសសឹង្ហបុរី

#### ៤.១.១.១. សន្ទស្សន៍ថ្លៃម្ហូបអាហារ

ក្រាហ្វិក ៤.១ សន្ទស្សន៍ថ្លៃម្ហូបអាហារ




យោងតាមទិន្នន័យ ដែលប្រមូលបានបង្ហាញឲ្យឃើញថាថ្លៃម្ហូបអារហារនៃប្រទេសសឹង្ហបុរីមានការប្រែប្រួលក្នុងកម្រិតតិចតួច ចាប់តាំងពីឆ្នាំ ២០១០ រហូតដល់ឆ្នាំ ២០១៦។ តាមរយៈខ្សែកោងបង្ហាញថាជារៀងរាល់ដើមឆ្នាំនីមួយៗ ថ្លៃម្ហូបអាហារមានការកើនឡើងបន្តិចបន្តួច។ ការកើនឡើងបែបនេះ ក៏ព្រោះថ្លៃម្ហូបអាហារក្នុងការសែននាឱកាសចូលឆ្នាំចិនដែលកើនឡើងខ្ពស់ជាងពេលធម្មតា។ បន្ទាប់ពីចូលឆ្នាំចិន បានបញ្ចប់ តម្លៃម្ហូបអាហារបានធ្លាក់ចុះមកកម្រិតធម្មតា និងបន្តឡើងចុះតិចតួច (ថេរ) រហូតដល់ចុងឆ្នាំនីមួយៗ។

#### ៤.១.១.២.សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គិសនី ឥន្ធនៈ

តាមក្រាហ្វិក ៤.២ ខាងក្រោម យើងសង្កេតឃើញថាសន្ទស្សន៍ថ្លៃនេះ គឺចាប់កើនឡើងបន្តិចម្តងៗ រហូតដល់ដើមឆ្នាំ ២០១២ ហើយធ្លាក់ចុះរហូតដល់ឆ្នាំ ២០១៦។ ការកើនឡើងថ្លៃទាំងនោះក៏ដោយសារតែការកើនឡើងនូវតម្លៃប្រេងសកលលោក។ ម្យ៉ាងទៀតបើតម្លៃ ផ្ទះសម្បែងមានការកើនចាប់តាំងពីឆ្នាំ ២០១០ ដោយសារតែការខ្វះខាតនូវផ្ទះជួល ដើម្បីឆ្លើយតបនឹងតម្រូវការជួលផ្ទះពីពលករក្រៅស្រុក។ មិនត្រឹមតែប៉ុណ្ណោះ នៅពាក់កណ្តាលឆ្នាំ ២០១១ កិច្ចសន្យាជួលផ្ទះជាច្រើនត្រូវដល់កាលកំនត់ធ្វើថ្មី។ ដូច្នេះហើយទើបចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០១១ ដល់ដើមឆ្នាំ

២០១២ សន្ទស្សន៍ថ្លៃ ផ្ទះសម្បែង ទឹក អគ្គិសនី ឥន្ទនៈ មានការកើនឡើងអតិបរមា។

**ក្រាហ្វិក ៤.២៖សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គសនី ឥន្ទនៈ**




### ៤.១.១.៣. សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និង ស្បែកជើង

**ក្រាហ្វិក ៤.៣៖សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និង ស្បែកជើង**




សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និង ស្បែកជើង ចន្លោះពីឆ្នាំ ២០១០ រហូតដល់ឆ្នាំ ២០១៦ មានការប្រែប្រួលឡើងចុះឥតឈប់ឈរ។ ការឡើងចុះបែបនេះគឺប្រែប្រួលទៅតាមរដូវកាលដូចជា មានការកើនឡើងនាដើមឆ្នាំនីមួយៗ ក្នុងកំឡុងពេលចូលឆ្នាំចិន ដែលពលរដ្ឋភាគច្រើនទិញសម្លៀកបំពាក់ថ្មី សម្រាប់ចូលឆ្នាំ ហើយបើក្រឡេកការធ្លាក់ចុះវិញ គឺក្នុងកំឡុងពេលដែលហាងភាគច្រើនលក់បញ្ចុះតម្លៃព្រមៗគ្នា។

### ៤.១.១.៤. សន្ទស្សន៍ថ្លៃដឹកជញ្ជូន

ក្រាហ្វិក ៤.៤៖សន្ទស្សន៍ថ្លៃដឹកជញ្ជូន




តាមក្រាហ្វិក ៤.៤ បានបង្ហាញចាប់តាំងពីដើមឆ្នាំ ២០១០ ដល់ដើមឆ្នាំ ២០១៣ សន្ទស្សន៍ថ្លៃដឹកជញ្ជូនគឺស្ថិតនៅក្នុងកម្រិតវិជ្ជមាន ហើយចាប់ពីពាក់កណ្តាលឆ្នាំ ២០១៣ ដល់ចុងឆ្នាំ ២០១៦ គឺធ្លាក់ចុះក្នុងកម្រិតអវិជ្ជមាន។ នៅដើមឆ្នាំ ២០១១ សន្ទស្សន៍ថ្លៃដឹកជញ្ជូនមានការកើនឡើងខ្ពស់បំផុត ក៏ព្រោះតែការតម្លើងថ្លៃខ្ពស់នេះ COE វិធីសាស្ត្ររបស់រដ្ឋាភិបាលថ្មីក្នុងការគ្រប់គ្រងនៃកំណើនយានយន្ត។

### ៤.១.១.៥.. សន្ទស្សន៍ថ្លៃគមនាគមន៍

ក្រាហ្វិក ៤.៥៖សន្ទស្សន៍ថ្លៃគមនាគមន៍



ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១៦ សន្ទស្សន៍ថ្លៃគមនាគមន៍ស្ថិតនៅក្នុងអត្រាក្រោម ០ ការកើនឡើងថ្លៃវិជ្ជមានគឺស្ថិតនៅក្នុងចុងឆ្នាំ ២០១០ ដើមឆ្នាំ ២០១១ ពាក់កណ្តាលឆ្នាំ២០១២ កើនឡើងខ្លាំងបំផុតក្នុងឆ្នាំ ២០១៥ និងកើនឡើងនាដើមឆ្នាំ ២០១៦។ វាបង្ហាញថាថ្លៃគមនាគមន៍គឺស្ថិតក្នុងតម្លៃទាបសមរម្យ។

### ៤.១.១.៦.សន្ទស្សន៍ថ្លៃអប់រំ

យោងទៅតាមខ្សែក្រាបក្នុងក្រាហ្វិក ៤.៦ បង្ហាញថាក្នុងដើមឆ្នាំ ២០១១ មានការកើនឡើងអតិផរណាចន្លោះឆ្នាំ ២០១០ ដល់ ២០១៦ ការឡើងចុះនៃថ្លៃអប់រំប្រែប្រួលក្នុងកម្រិតតិចតួច មិនដូចឆ្នាំ ២០១១ នោះទេ។ ការកើនឡើងក្នុងឆ្នាំ ២០១១ ក៏ព្រោះតែការឡើងថ្លៃពលកម្មរបស់បុគ្គលិកនៅក្នុងសាលាជាពិសេសលោកគ្រូ និង អ្នកគ្រូ។

**ក្រាហ្វិក ៤.៦៖សន្ទស្សន៍ថ្លៃអប់រំ**




### ៤.១.១.៧.សន្ទស្សន៍ថ្លៃសុខាភិបាល

តាមក្រាហ្វិកខាងក្រោមនេះបង្ហាញថា សន្ទស្សន៍ថ្លៃសុខាភិបាលបានកើនឡើងចាប់ពីដើមឆ្នាំ ២០១០ ដល់ដើមឆ្នាំ ២០១១ ហើយធ្លាក់ចុះនៅពាក់កណ្តាលឆ្នាំ ២០១១ និងផ្តើមកើនឡើងវិញនៅដើមឆ្នាំ ២០១២ ដល់ចំណុចខ្ពស់បំផុតនៅចុងឆ្នាំ ២០១២ និងបន្តធ្លាក់ចុះមកវិញនៅដើមឆ្នាំ ២០១៣ រហូតដល់ចុងឆ្នាំ ២០១៥។ នៅដើមឆ្នាំ ២០១៦ យើងឃើញថា សន្ទស្សន៍ថ្លៃសុខាភិបាលបានកើនឡើងបន្តិច ម្តងៗ។

**ក្រាហ្វិក ៤.៧៖សន្ទស្សន៍ថ្លៃសុខាភិបាល**




### ៤.១.១.៨.ទំនិញ ឬ សេវាកម្មផ្សេងៗ

**ក្រាហ្វិក ៤.៨៖សន្ទស្សន៍ថ្លៃទំនិញ ឬ សេវាកម្មផ្សេងៗ**




តាមក្រាហ្វិក ៤.៨ បង្ហាញឲ្យយើងឃើញថា សន្ទស្សន៍ថ្លៃទំនិញ ឬ សេវាកម្មផ្សេងៗមានការប្រែប្រួលឡើងចុះពីមួយឆ្នាំទៅមួយឆ្នាំក៏ពិតមែន តែនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ហើយចាប់ពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ ២០១៦ មានការថយចុះសន្ទស្សន៍ថ្លៃទំនិញ ដោយសារតែអតិផរណារបស់ប្រទេសដែលនាំទំនិញចូលសឹង្ហបុរីមានការថយចុះ ព្រមទាំងការលើកទឹកចិត្តឲ្យខាងសហគ្រិន ក្នុងស្រុកចាប់ផ្តើមបង្កើតម៉ាកផលិតផលផ្ទាល់ខ្លួនដើម្បីជួយទប់ស្កាត់ការឡើងថ្លៃទំនិញនាំចូល។

## ៤.១.២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៃក្រុមនីមួយៗក្នុងប្រទេសកម្ពុជា

### ៤.១.២.១. សន្ទស្សន៍ថ្លៃម្ហូបអាហារមិនមានជាតិស្រវឹង

ក្រាហ្វិក ៤.៩៖ សន្ទស្សន៍ថ្លៃម្ហូបអាហារមិនមានជាតិស្រវឹង




យោងតាមទិន្នន័យដែលទទួលបាន បង្ហាញឲ្យឃើញថា ថ្លៃម្ហូបអាហាមិនមានជាតិស្រឹង មានការកើនឡើងខ្ពស់នៅដើមឆ្នាំ ២០១០ និងពាកកណ្ដាលឆ្នាំ ២០១១ ហើយធ្លាក់ចុះខ្លាំងនៅចុងឆ្នាំ២០១២។ បន្ទាប់មកចាប់ពីឆ្នាំ ២០១៣ ថ្លៃម្ហូបអាហារបានឡើងចុះរហូតដល់ឆ្នាំ ២០១៦ ដូចដែលបានបង្ហាញនូក្នុងក្រាហ្វិក។ ការកើនឡើងខ្ពស់បំផុតនៃសន្ទស្សន៍ថ្លៃម្ហូបអាហារនិងភេជ្ជៈមិនមានជាតិស្រវឹង នៅក្នុងឆ្នាំ ២០១០ ដែលជាមេក្រុមមានមេគុណខ្ពស់បំផុតនោះ ជាចម្បងបណ្ដាលមកពីការកើនឡើងនៃថ្លៃសាច់ជ្រូក ២២.៧ភាគរយ សាច់គោ ១៦.២ភាគរយ ប្រេងឆា និងខ្លាញ់ ១០.៩ភាគរយ បន្លែ ៩.៥ភាគរយ សាច់ទា ៧.៩ភាគរយ សាច់កែច្នៃ ក្នុងស្រុក ៦.៦ភាគរយ និងផ្លែឈើ ៣.៦ភាគរយ ។ ការកើនឡើងខ្លាំងនេះ បណ្ដាលមកពីវិបត្តិសេដ្ឋកិច្ចដែលមានឥទ្ធពលមកលើប្រទេសយើង ធ្វើឲ្យថ្លៃម្ហូបអាហារមានការកើនឡើងផងដែរ។

### ៤.១.២.២.សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់

តាមការខ្សែរកោងក្រាហ្វិក ៤.១០បានបង្ហាញថា ចាប់ពីដើមឆ្នាំ ២០១០ ដល់ឆ្នាំ ២០១១មក ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ មានការធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់ឆ្នាំ ២០១២ មកដល់ឆ្នាំ ២០១៦ មានសន្ទស្សន៍កើនឡើងវិញយ៉ាងខ្ពស់។ ការកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ ២០១៦ នេះ គឺបណ្ដាលមកពីការបង្កើនពន្ធអាករពិសេសទៅលើផលិតផលទាំងស្រុងនោះ ដែលជាហេតុនាំឲ្យ

សន្ទស្សន៍ថ្លៃនេះ កើនឡើងរហូតដល់ ១១.៥ភាគរយ ក្នុងខែមករា ឆ្នាំ ២០១៦។

**ក្រាហ្វិក ៤.១០ សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់**




**៤.១.២.៣. សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និងស្បែកជើង**

**ក្រាហ្វិក ៤.១១៖ សន្ទស្សន៍ថ្លៃសម្លៀកបំពាក់ និងស្បែកជើង**




សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើងក៏មិនខុសគ្នាប៉ុន្មានដែរ គឺមានការឡើងចុះដូចគ្នាទៅតាមរដូវកាលនៃឆ្នាំនីមួយៗ ពីព្រោះតម្រូវការលើផលិតផលទាំងនេះទៅតាម ពេលវេលា និងរដូវកាលមុណ្យទាន ហើយវាមិនមែនជាផលិតផលចាំបាច់ក្នុងការទ្រទ្រង់ជីវភាព ដែលជាហេតុធ្វើឲ្យថ្លៃមិនសូវមានការប្រែប្រួលខ្លាំង។

**៤.១.២.៤.សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គិសនី ឥន្ធនៈ**

បើយោងទៅតាមក្រាហ្វិក៤.១១ ខាងលើ បានបង្ហាញថាថ្លៃផ្ទះសម្បែង ទឹក អគ្គិសនី ឥន្ធនៈ គឺមានការប្រែប្រួលឡើងចុះទៅតាមថ្លៃប្រេងលើសកលលោក និងការឡើងថ្លៃទំនិញនាំចូល ដែលជាហេតុធ្វើឲ្យថ្លៃនេះមានបម្រែបម្រួល។

**ក្រាហ្វិក ៤.១២៖ សន្ទស្សន៍ថ្លៃផ្ទះសម្បែង ទឹក អគ្គិសនី ឥន្ធនៈ**




### ៤.១.២.៥.សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ

យោងតាមក្រាហ្វិកខាងលើ សន្ទស្សន៍មានការឡើងចុះជាមធ្យម ដល់៤ លើកលេងតែនៅឆ្នាំ២០១៤ និងដើមឆ្នាំ ២០១៦ តែប៉ុណ្ណោះដែលមានការកើនឡើងអតិបរមា។

**ក្រាហ្វិក ៤.១៣៖ សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់គ្រួសារ និងការថែទាំផ្ទះជាប្រចាំ**




### ៤.១.២.៦.សន្ទស្សន៍ថ្លៃសុខាភិបាល

សន្ទស្សន៍ថ្លៃសុខាភិបាល មានការកើនឡើងយ៉ាងខ្លាំងគួឲ្យកត់សម្គាល់នៅក្នុងពាក់កណ្តាលឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៤។ ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១៦ អត្រាសន្ទស្សន៍ថ្លៃសុខាភិបាលមានការប្រែប្រួលតិចតួច។

**ក្រាហ្វិក ៤.១៤៖ សន្ទស្សន៍ថ្លៃសុខាភិបាល**




### ៤.១.២.៧.សន្ទស្សន៍ថ្លៃដឹកជញ្ជូន

នៅឆ្នាំ ២០១០ សន្ទស្សន៍ថ្លៃដឹកជញ្ជូនមានការកើនឡើងខ្ពស់ គឺជាសទ្ធផលនៃការកើនឡើងថ្លៃប្រេងម៉ាស៊ូត ១៥.៤% ប្រេងសាំង ១១.0% និងសេវាកម្មដឹកជញ្ជូន ៦.១% បន្ទាប់ពីមានការធ្លាក់ចុះ នៅពាក់កណ្តាលឆ្នាំ ២០១០ និងចាប់ផ្តើមកើនឡើងវិញចាប់ពីឆ្នាំ២០១១ រហូតដល់ឆ្នាំ ២០១២ បន្ទាប់មកវិញចាបផ្តើមធ្លាក់ចុះក្នុងពាក់កណ្តាលឆ្នាំ ២០១២ និងបន្តធ្លាកចុះរហូតដល់ចុងឆ្នាំ ២០១៦។

**ក្រាហ្វិក ៤.១៥ សន្ទស្សន៍ថ្លៃដឹកជញ្ជូន**



### ៤.១.២.៨.សន្ទស្សន៍ថ្លៃគមនាគមន៍

**ក្រាហ្វិក ៤.១៦ សន្ទស្សន៍ថ្លៃគមនាគមន៍**




ចាប់ពីឆ្នាំ ២០១០ ដល់ ២០១៦ តម្លៃគមនាគមន៍ភាពច្រើនស្ថិតនៅកម្រិតអវិជ្ជមាន វាបានបញ្ជាក់ថាថ្លៃគមនាគមន៍ មានការថយចុះបន្តគ្នា។ ការថយចុះនេះ គឺបណ្តាលពីការប្រកួតប្រជែងនៃក្រុមហ៊ុន ផ្តល់សេវាទូរស័ព្ទបានបង្កើននូវកម្មវិធីប្រម៉ូសិនជាច្រើន ដើម្បីផ្តល់ជូនអតិថិជនរបស់ពួកគេ ដែលជាហេតុធ្វើឲ្យថ្លៃប្រែប្រួលឥតឈប់ឈរ។

### ៤.១.២.៩.សន្ទស្សន៍ថ្លៃការកម្សាន្ត នឹងវប្បធម៌

**ក្រាហ្វិក៤.១៧ សន្ទស្សន៍ថ្លៃការកម្សាន្ត នឹងវប្បធម៌**




ដល់ឆ្នាំ២០១៦ ថ្វីត្បិតតែចន្លោះឆ្នាំនឹង មានការធ្លាក់ចុះ តែនៅតែខ្ពស់ជាងឆ្នាំ២០១០ និង ២០១១។ យើងឃើញថាប្រជាជនយើងបានចំណាយពេលវេលាដើម្បីកំសាន្ត និងលំហែកាយនៅពេលទំនេរពីការងារ និងការសិក្សា បានច្រើនជាងពីពេលមុនៗ។

### ៤.១.២.១០ សន្ទស្សន៍ថ្លៃអប់រំ

**ក្រាហ្វិក៤.១៨៖ សន្ទស្សន៍ថ្លៃអប់រំ**




ក្រាហ្វិកខាងលើនេះបង្ហាញពីការវិវត្តន៍នៃសន្ទស្សន៍ថ្លៃអប់រំ។ យើងឃើញថាសន្ទស្សន៍ថ្លៃមានការធ្លាក់ចុះខ្លាំងនៅឆ្នាំ ២០១១ ហើយកើនឡើងបន្តិចម្តងៗ ដល់ពាក់កណ្តាលឆ្នាំ២០១៤។ យោងទៅតាមគោលនយោបាយឈ្នះៗរបស់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ន គឺពង្រឹងការអប់រំនៅប្រទេសកម្ពុជាឲ្យមានកម្រិតតាន់តែល្អប្រសើរឡើង។ យើងឃើញថាកំណើននៃសាលារៀននៅក្នុងប្រទេសយើងបានកើនជាលំដាប់ ជាពិសេសនៅតាម ស្រុកនានាទូទាំងប្រទេស ដើម្បីបម្រើឲ្យសេវាសាធារណៈរបស់ប្រជាពលរដ្ឋ និងដើម្បីលើកកម្ពស់កម្រិតអប់រំរបស់ប្រជាជន ដែលនេះជាការកាត់បន្ថយនូវអក្ខរភាពដើម្បីឈានទៅដល់ការកាត់បន្ថយភាពក្រីក្ររបស់ដ្ឋាភិបាល។

### ៤.១.២.១១ សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន

**ក្រាហ្វិក៤.១៩៖ សន្ទស្សន៍ថ្លៃភោជនីយដ្ឋាន**



បើមើលតាមលើក្រាហ្វិក ៤.១៩ គឺសន្ទស្សន៍ថ្លៃភោជនីដ្ឋាន មានការកើនឡើងខ្ពស់ក្នុងពាក់កណ្តាលឆ្នាំ ២០១១ ដោយសារតែកំណើនថ្លៃនៃក្រុមត្រី ក្រុមសាច់ និងទំនិញផ្សេងៗទៀត។

### ៤.១.២.១២ សន្ទស្សន៍ថ្លៃទំនិញ ឬសេវាកម្មផ្សេងៗ

**ក្រាហ្វិក៤.២០ សន្ទស្សន៍ថ្លៃទំនិញ ឬសេវាកម្មផ្សេងៗ**




តាមក្រាហ្វិក៤.២០ យើងឃើញថាចន្លោះពីឆ្នាំ ២០១០ ដល់ ២០១១ សន្ទស្សន៍ថ្លៃទំនិញ ឬសេវាកម្មផ្សេងៗ នៅខ្ពស់ថេរ ហើយចាប់ពីដើមឆ្នាំ ២០១២ បានធ្លាក់ចុះដោយថ្លៃទំនិញនាំចូលមានការធ្លាក់ចុះ ធ្វើឲ្យសន្ទស្សន៍ថ្លៃមានការធ្លាក់ចុះតាមផងដែរ។

